# ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨

## ការប្រឆាំងការជួញដូរមនុស្សនៅកម្ពុជាមិនបានប្រសើរឡើង

https://khmer.voanews.com/ 29 មិថុនា 2018 ម៉ែន គឹមសេង

ក្រសួងការបរទេសរបស់សហរដ្ឋអាមេរិកទទួលស្គាល់ស្ថានភាពជួញដូរមនុស្សនៅកម្ពុជា ដែលមានលក្ខណៈប្រសើរជាងមុន ដោយដាក់ប្រទេសកម្ពុជាក្នុងចំណាត់ថ្នាក់ទី២ (Tier 2) នៅក្នុងរបាយការណ៍ស្តីពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សឆ្នាំ២០១៨នេះ ឬ Trafficking in Persons Report។ ប្រទេសកម្ពុជានៅតែជាប្រភព ជាកន្លែងឆ្លងកាត់និងជាទីដៅនៃការកេងប្រវ័ញ្ចផ្លូវភេទនិងធ្វើការដោយបង្ខំលើបុរស ស្ត្រីនិងកុមារក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ។

វ៉ាស៊ីនតោន៖ ការទប់ស្កាត់ការជួញដូរមនុស្សនៅប្រទេសកម្ពុជាមិនមានស្ថានភាពប្រសើរឡើងទេក្នុងរយៈពេលបីឆ្នាំជាប់ៗគ្នាចាប់តាំងពីឆ្នាំ២០១៦មកដោយស្ថិតនៅចំណាត់ថ្នាក់ទី២ដដែល ហើយអំពើពុករលួយនៅបន្តរាំងដល់ការអនុវត្តច្បាប់ ការដាក់ទោសជនល្មើសនិងការផ្តល់សេវាដល់ជនរងគ្រោះ។ របាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ២០១៨ ដែលចេញផ្សាយដោយក្រសួងការបរទេសសហរដ្ឋអាមេរិកកាលពីថ្ងៃព្រហស្បតិ៍បានបញ្ជាក់បន្ថែមថា៖ «រដ្ឋាភិបាលកម្ពុជាមិនបំពេញបានតាមស្តង់ដាអប្បបរមាសម្រាប់លុបបំបាត់ការជួញដូរមនុស្សទេ ប៉ុន្តែបានខិតខំប្រឹងប្រែងទប់ស្កាត់ច្រើនដែរ»។ រដ្ឋាភិបាលកម្ពុជាបានបង្ហាញកិច្ចខិតខំប្រឹងប្រែងតាមរយៈការកាត់ទោសឈ្មួញ ធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋរងគ្រោះពីការជួញដូរទៅបរទេស និងពង្រឹងកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយពីការកេងប្រវ័ញ្ចផ្លូវភេទកុមារជាដើម។ ប៉ុន្តែប្រទេសកម្ពុជានៅតែជាប្រភព ជាកន្លែងឆ្លងកាត់និងជាទីដៅនៃការកេងប្រវ័ញ្ចផ្លូវភេទនិងធ្វើការដោយបង្ខំលើបុរស ស្ត្រីនិងកុមារក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ។ ពលរដ្ឋកម្ពុជាមានក្មេងនិងចាស់បានទៅធ្វើការនៅប្រទេសដទៃក្នុងតំបន់និងមានការកើនឡើងខ្លាំងនៅតំបន់មជ្ឈិមបូព៌ាដោយត្រូវធ្វើការធ្ងន់ធ្ងរដោយបង្ខំនៅលើទូកនេសាទ ផ្នែកកសិកម្ម សំណង់ រោងចក្រនិងការងារតាមផ្ទះហើយពួកគេខ្លះរងគ្រោះផ្លូវភេទ។

ក្នុងឆ្នាំ២០១៧ មានជនរងគ្រោះកម្ពុជាចំនួន៩៨៦នាក់ត្រូវបានក្រសួងការបរទេសកម្ពុជាជួយធ្វើមាតុភូមិនិវត្តន៍ដែលភាគច្រើនមកពីប្រទេសម៉ាឡេស៊ី ថៃ វៀតណាមនិងចិន។ ចំនួននេះច្រើនជាងឆ្នាំ២០១៦ដែលមានតែ៨១៥នាក់ប៉ុណ្ណោះ។ រីឯក្រសួងសង្គមកិច្ចបានជួយធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋកម្ពុជាចំនួន២៤៣នាក់ដែរ។ នេះបើតាមការបញ្ជាក់ក្នុងរបាយការណ៍។ ក្រសួងការបរទេសសហរដ្ឋអាមេរិកបានបញ្ជាក់ថា «ក្នុងពេលដែលរដ្ឋាភិបាលនៅមិនទាន់មានវិធានការត្រួតពិនិត្យនិងទទួលខុសត្រូវឱ្យបានគ្រប់គ្រាន់ក្រុមឈ្មួញទុច្ចរិតបានបង្ខំឱ្យបុរស ស្ត្រី និងកុមារនៅទូទាំងប្រទេសធ្វើការធ្ងន់ធ្ងរដើម្បីសង បំណុលហើយពួកគេទទួលបានអន្តរាគមន៍តិចតួចប៉ុណ្ណោះពីអាជ្ញាធរមានសមត្ថកិច្ចហើយជួនកាលអាជ្ញាធរជាអ្នកបើកដៃឱ្យផងដែរ»។ បុរសកម្ពុជាគឺជាអ្នកត្រូវការសេវាផ្លូវភេទកុមារដ៏ធំជាងគេបំផុតហើយក៏មានក្រុមបុរសមកពីប្រទេសដទៃទៀតនៅអាស៊ីនិងអឺរ៉ុប សហរដ្ឋអាមេរិក អូស្ត្រាលី និងអាហ្វ្រិកខាងត្បូងធ្វើដំណើរទៅកម្ពុជាដើម្បីស្វែងរកសេវាផ្លូវភេទកុមារផងដែរ។ នេះបើតាមការបញ្ជាក់របស់របាយការណ៍៕

## មន្ត្រីរដ្ឋាភិបាល៖ កិច្ចប្រឹងប្រែងប្រឆាំងការជួញដូរមនុស្សនឹងបន្ត ទោះជាកម្ពុជាទទួលលំដាប់ថ្នាក់មិនល្អ

https://khmer.voanews.com/ 29 មិថុនា 2017 ហ៊ុល រស្មី

ក្រសួងការបរទេសសហរដ្ឋអាមេរិក កាលពីព្រឹកថ្ងៃអង្គារកន្លងទៅ បានចេញរបាយការណ៍ស្តីពីការជួញដូរមនុស្ស ដោយបានបង្ហាញថា ប្រទេសកម្ពុជាស្ថិតនៅក្នុងលំដាប់ថ្នាក់ទីពីរក្នុងបញ្ជីប្រឆាំងការជួញដូរមនុស្សសម្រាប់ឆ្នាំ២០១៧ដែលមិនមានអ្វីប្រែប្រួល ប្រសើរជាងឆ្នាំមុននោះទេ។

ភ្នំពេញ៖ មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលកម្ពុជាទទួលបន្ទុកប្រឆាំងសកម្មភាពជួញដូរ កាលថ្ងៃពុធនេះ បានទទួលស្គាល់ការរកឃើញរបស់សហរដ្ឋអាមេរិកអំពីស្ថានភាពប្រឆាំងការជួញដូរមនុស្សរបស់កម្ពុជាដែលនៅខ្វះខាត តែទោះជា

យ៉ាងណាក្រុមមន្ត្រីបានថ្លែងការពារថា រដ្ឋាភិបាលកម្ពុជាធ្វើការប្រឹងប្រែងទប់ស្កាត់សកម្មភាពជួញដូរមនុស្ស ដែលជាមុខជំនួញរកចំណូលបានច្រើនសម្រាប់ក្រុមជនទុច្ចរិត ហើយពិបាកនឹងទប់ស្កាត់នោះ។

ក្រសួងការបរទេសសហរដ្ឋអាមេរិក កាលពីព្រឹកថ្ងៃអង្គារកន្លងទៅ បានចេញរបាយការណ៍ស្តីពីការជួញដូរមនុស្ស ដោយបានបង្ហាញថា ប្រទេសកម្ពុជាស្ថិតនៅក្នុងលំដាប់ថ្នាក់ទីពីរក្នុងបញ្ជីប្រឆាំងការជួញដូរមនុស្សសម្រាប់ឆ្នាំ២០១៧ដែលមិនមានអ្វីប្រែប្រួល ប្រសើរជាងឆ្នាំមុននោះទេ។ របាយការណ៍នោះបានឲ្យដឹងថា កម្ពុជាបានបន្តស្ថិតនៅក្នុងលំដាប់ថ្នាក់ទីពីរ ដោយសារតែរដ្ឋាភិបាលកម្ពុជាមិនបានបំពេញតាមនិយាមអប្បបរមាក្នុងការលុបបំបាត់ការជួញដូរមនុស្សទេ ដូចជាការមិនស៊ើបអង្កេត ឬយកមកកាត់ទោសក្រុមមន្ត្រី ដែលពាក់ព័ន្ធនឹងបទល្មើសជាដើម។ អ្នកស្រីជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិបង្ក្រាបការជួញដូរមនុស្ស និងផ្លូវភេទលើស្ត្រី និងកុមារ មានប្រសាសន៍ប្រាប់ VOA នៅថ្ងៃពុធនេះថា ការវាយតម្លៃរបស់សហរដ្ឋអាមេរិក ជាកិច្ចការត្រឹមត្រូវមួយ តែអ្នកស្រីថា រដ្ឋាភិបាលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការប្រឆាំងសកម្មភាពជួញដូរមនុស្សនេះ។ «អ្វីដែលជាកិច្ចខិតខំប្រឹងប្រែងរបស់យើង យើងពិតជាទទួលដឹងថា យើងប្រឹងប្រែងខ្លាំងណាស់។ ប៉ុន្តែទន្ទឹមនឹងហ្នឹង យើងក៏ទទួលស្គាល់ដែលថា មិនទាន់សុក្រិត្យគ្រប់រឿងទេ ដែលយើងនៅខំប្រឹងប្រែងបន្តទៀត ពីព្រោះករណីថ្មី ចេះតែកើតមាន ហើយក្នុងនោះ យើងក៏នឹងរិះរកនីតិវិធីថ្មីសម្រាប់ការឆ្លើយតប ដោយសារថាវាមិនអាចធ្វើឲ្យការងារហ្នឹង វាបាត់ស្ងាត់ក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណឹងបានទេ ចា៎»។ របាយការណ៍ដដែលរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក បានឲ្យដឹងទៀតថា ការជួញដូរកម្លាំងពលកម្មជនជាតិខ្មែរនៅបរទេសនៅបន្តមាន ដោយសារតែមន្ត្រីការងារមិនបានត្រួតពិនិត្យទីភ្នាក់ងារជ្រើសរើសពលករឱ្យបានដិតដល់ ហើយដោយសារតែទីភ្នាក់ងារទាំងនោះលក់សិទ្ធិបន្តទៅឱ្យមេខ្យល់ជាដើម។ ក្រសួងការបរទេសសហរដ្ឋអាមេរិកបានស្នើឱ្យរដ្ឋាភិបាលកម្ពុជាបង្កើនសេវាជួយជនរងគ្រោះបុរស ជាពិសេសក្រុមដែលត្រូវគេកេងប្រវ័ញ្ចនៅលើទូកនេសាទ ហើយកម្ពុជាគួរតែផ្តល់ធនធានបន្ថែមទៀតជួយដល់ជនរងគ្រោះកម្ពុជានៅក្រៅប្រទេសតាមរយៈបេសកកម្មការទូតនៅក្រៅប្រទេស និងប្រទេសដែលកម្ពុជាមិនមានស្ថានបេសកកម្មការទូត។

អ្នកស្រីជូ ប៊ុនអេងបានបញ្ជាក់ថា សកម្មភាពជួញដូរមនុស្ស នាពេលបច្ចុប្បន្ននេះ មានច្រើនរូបភាព រួមមានការណ៍ដែលពលករត្រូវបានគេកេងប្រវ័ញ្ច ដោយការបញ្ជូនឲ្យទៅធ្វើជាកម្មករលើទូកនេសាទ ការធ្វើការនៅតាមផ្ទះកសិដ្ឋាន ឬក៏រោងចក្រឧស្សាហកម្មជាដើម។ អ្នកស្រីបានឲ្យដឹងទៀតថា រដ្ឋាភិបាលបានបង្កើនការគាំទ្រខាងច្បាប់ដល់ជនរងគ្រោះ ដើម្បីទទួលបានយុត្តិធម៌ពីការកេងប្រវ័ញ្ច និងការរំលោភបំពាននានា។ «យើងក៏បានផ្តោតទៅលើក្រុមដែលរងគ្រោះចា៎ ដែលពេលដែលគាត់ត្រឡប់មកស្រុកវិញ ឬមួយក៏គាត់ប្រឈមនឹង គេហៅថា រំលោភបំពានផ្សេងៗ គឺយើងបានផ្តល់នូវជំនួយផ្នែកច្បាប់ ក៏ដូចជាផ្តល់នូវកិច្ចការពារ ការសង្គ្រោះ ឬមួយក៏សហការជាមួយនឹងប្រទេសគោលដៅ ដើម្បីស្វែងរកភាពយុត្តិធម៌ជូនគាត់ ដោយមានពេលខ្លះ គាត់ក៏បានទទួលសំណង គាត់ក៏បាន គេហៅថា ដាក់ពាក្យដើម្បីប្តឹង ដែលធ្វើឲ្យយើងបន្តកិច្ចស្រាវជ្រាវ ហើយក៏មានការបង្ក្រាបជាបន្តបន្ទាប់ដែរ»។ អ្នកស្រីជូ ប៊ុនអេង បានបន្ថែមថា មន្ត្រីស្ថានទូតកម្ពុជាមិនអាចស៊ើបអង្កេតដោយខ្លួនឯងដើម្បីរកប្រភពនៃក្រុមឈ្មួញដែលរកស៊ីការជួញដូរពលរដ្ឋកម្ពុជា ក្នុងប្រទេសដែលមានស្ថានទូតកម្ពុជាប្រចាំនៅនោះទេ។ អ្នកស្រីថា ការប្រឆាំងសកម្មភាពជួញដូរមនុស្សតម្រូវឲ្យមានកិច្ចសហការជាមួយប្រទេសគោលដៅ ព្រោះអាជ្ញាធរដែលមានសមត្ថកិច្ចក្នុងប្រទេសគោលដៅទាំងនោះ អាចមានព័ត៌មានច្រើនទាក់ទិនបណ្តាញក្រុមរកស៊ីជួញដូរមនុស្ស។

យ៉ាងណាក្តី ក្រសួងការបរទេសសហរដ្ឋអាមេរិកបានទទួលស្គាល់ពីការប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជាតាមរយៈការកាត់ទោសជនល្មើសជួញដូរមនុស្សមួយចំនួនក្នុងយ៉ាងច្រើន ហើយបានផ្តល់ថវិកាបន្ថែមទៀតដល់គណៈកម្មាធិការជាតិប្រឆាំងនឹងការជួញដូរមនុស្ស និងបង្កើតនូវផែនការសកម្មភាពជាតិសម្រាប់ទប់ស្កាត់រាល់ទម្រង់នៃការជួញ

ជួញដូរមនុស្ស។ ក្នុងឆ្នាំ២០១៦កន្លងមកនេះ រដ្ឋាភិបាលកម្ពុជាបាននាំយកជនល្មើសមកកាត់ទោសបានចំនួន៥៣នាក់ ដែលមានចំនួនធ្លាក់ចុះបន្តិច បើប្រៀបធៀបនឹងឆ្នាំ២០១៥ ដែលមានចំនួន៦៩នាក់។

លោកសុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា បានប្រាប់ VOA ថា រដ្ឋាភិបាលកម្ពុជាទទួលយកការរកឃើញរបស់សហរដ្ឋអាមេរិកពាក់ព័ន្ធនឹងការជួញដូរ តែបានស្នើឲ្យភាគីសហរដ្ឋអាមេរិកជួយកម្ពុជាដើម្បីលុបបំបាត់សកម្មភាពជួញដូរមនុស្សក្នុងប្រទេស។ «ជួញដូរមនុស្សហ្នឹង ឲ្យអាមេរិកជួយចាប់ផង។ អាហ្នឹងយើងមានឃុបឃិត មានបន្លំឯណាជាមួយ? យើងកំពុងតែចាត់វិធានការរាល់ថ្ងៃ ចាត់វិធានការហ្នឹងគឺថា មានបានលទ្ធផលគគោកគគរជីហើយ អីចឹងទេ បើអាមេរិកមានលទ្ធភាពជួយផង អាហ្នឹងសុំជួយមក ដើម្បីកុំឲ្យវាមានបញ្ហាជួញដូរមនុស្សនៅកម្ពុជាទៀត»។

របាយការណ៍ស្ដីពីការប្រឆាំងការជួញដូរមនុស្សបានផ្ដល់អនុសាសន៍មួយចំនួនដល់រដ្ឋាភិបាលកម្ពុជា ក្នុងការជួយជនរងគ្រោះ ក៏ដូចជាបង្កើនសេវាដែលមានស្រាប់សម្រាប់ជួយជនរងគ្រោះដែលជាបុរស។ អនុសាសន៍សំខាន់ៗនោះរួមមាន អាជ្ញាធរកម្ពុជាត្រូវតែកាត់ទោសជនដែលប្រព្រឹត្តបទល្មើសទាំងឡាយពាក់ព័ន្ធការជួញដូរមនុស្ស ហើយផ្ដល់អំណាចដល់ការប្រើប្រាស់បច្ចេកទេសស៊ើបអង្កេតដោយសម្ងាត់ក្នុងការអនុវត្តច្បាប់ប្រឆាំងការជួញដូរ និងការបង្កើតនីតិវិធីជាប្រព័ន្ធ ហើយបែងចែកធនធាន ដើម្បីជួយពលរដ្ឋកម្ពុជារងគ្រោះ តាមបេសកកម្មការទូតនៅបរទេស និងក្នុងប្រទេសទាំងឡាយណា ដែលមិនមានតំណាងការទូតកម្ពុជានៅទីនោះ។

ស.រ.អា.បានព្រមានផ្អាកជំនួយ ឬដាក់ទណ្ឌកម្មប្រទេសមួយចំនួន ដែលមានកម្រិតទាបជាងលំដាប់ទី២ និងធ្លាក់ដល់កម្រិតទី៣ ដែលមានន័យថា ជាប្រទេសមានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ គ្មានការប្រឹងប្រែងទប់ស្កាត់អំពើជួញដូរមនុស្ស គ្មានការដាក់ទោសទណ្ឌជនល្មើស និងគ្មានការស៊ើបអង្កេតស្រាវជ្រាវរកជនល្មើសជាដើម៕

## ស្ថានទូតកម្ពុជានៅចិន និងម៉ាឡេស៊ី អន្តរាគមន៍ជួយពលរដ្ឋខ្មែរ ១៤នាក់ឲ្យត្រឡប់មកស្រុកកំណើតវិញ

http://www.freshnewsasia.com/ 2018-07-02

**(ភ្នំពេញ)៖** ស្ថានទូតរបស់កម្ពុជាប្រចាំនៅប្រទេសចិន និងម៉ាឡេស៊ី បានអន្តាគមន៍ជួយប្រជាពលរដ្ឋខ្មែរ ១៤នាក់ ឲ្យត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីពួកគេចាញ់បោកមេខ្យល់ទៅរៀបការ និងធ្វើការដោយខុសច្បាប់។ យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់ក្រសួងការបរទេសកម្ពុជា បានឲ្យដឹងនៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨នេះថា ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី ដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរចំនួន៩នាក់ មកពីខេត្តកំពង់ធំ ក្រចេះ តាកែវ បាត់ដំបង និងរាជធានីភ្នំពេញ។ ក្នុងនោះពលករមានចំនួន ៣នាក់ និងពលការិនី៤នាក់ ដែលបានទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី និង២នាក់ជាកុមារ (ជាកូនរបស់ពលការិនីម្នាក់)។ ចំពោះករណីនេះ ស្ថានទូតបានចេញលិខិតបើកផ្លូវ និងសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ហើយពលរដ្ឋខ្មែរទាំង៩នាក់នោះបានមកដល់កម្ពុជាវិញជាបន្តបន្ទាប់ចន្លោះពីថ្ងៃទី ២៣ ដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ ។

ដោយឡែកករណីទី២ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសចិន បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ចិន អន្តរាគមន៍ជួយសង្គ្រោះ និងរៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរចំនួន ៥នាក់ មកពីខេត្តកំពង់ចាម តាកែវ និងព្រៃវែង ដោយក្នុងនោះ ៤នាក់ជាស្ត្រីរងគ្រោះដែលមេខ្យល់នាំធ្វើដំណើរពីកម្ពុជាទៅរៀបការដោយខុសច្បាប់នៅក្នុងប្រទេសចិន និង ១នាក់ទៀតជាកុមារ ជាកូនរបស់ស្ត្រីរងគ្រោះម្នាក់។

ស្ថានទូត បានផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគ ព្រមទាំងរៀបចំឯកសារធ្វើដំណើរដល់ពលរដ្ឋខ្មែរទាំង៥នាក់ ហើយពួកគេបានមកដល់កម្ពុជាវិញ នៅយប់ថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ២០១៨៕

## និយោជក,មិនធ្វើប្រកាន់សង្គមអោយត្រូវមានទោសទាំងផាកពិន័យនិងជាប់ឃុំ

http://www.khmerlabour.com/ 01-07-2018

**#បទកំណត់ទោសចំពោះនិយោជកមិនធ្វើប្រកាន់សង្គមអោយពលករ**

•និយោជកដែលមិនដំណើរការធ្វើប្រកាន់សង្គមអោយពលករ ឬបង់ប្រាក់ប្រកាន់សង្គមមិនគ្រប់ចំនួននៃរយៈពេលកំណត់។

*ត្រូវមានទោសជាប់ពន្ធនាគារមិនលើសពី06ខែ និងផាកពិន័យជាប្រាក់មិនលើសពី20.000បាត ឬទាំងជាប់ពន្ធនាគារទាំងផាក់ពិន័យជាប្រាក់។

*និយោជកត្រូវបង់ប្រាក់បន្ថែមអត្រា02%លើអត្រាប្រាក់ក្នុងមួយខែតាមចំនួនប្រាក់ដែលនិយោជកមិនបានបង់ឬតាមចំនួនប្រាក់ដែលនិយោជកបង់មិនទាន់គ្រប់។

## ការងារប្រាំប្រភេទមិនចាំបាច់ធ្វើប្រកាន់សង្គម

http://www.khmerlabour.com/ KhmerLabour July 2, 2018

ពលករខ្មែរដែលចូលមកធ្វើការក្នុងប្រទេសថៃតាមរយៈអនុសារណៈយោគយល់គ្នារវាងភាគីថៃ និងភាគីកម្ពុជា (MOU) ដោយមិនចាំបាច់ធ្វើប្រកាន់សង្គម មានការងារចំនួន 05 ប្រភេទដូចខាងក្រោម÷

1-ការងារកសិកម្ម

2-ការងារមេផ្ទះ

3-ការងារចិញ្ចឹមសត្វ

4-ការងារនេសាទ

5-ការងារលក់ដូរ

# ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨

## ពលករខ្មែរនៅថៃស្នើអន្តរាគមន៍ដល់ពួកគេដែលខ្វះក្រដាសស្នាមកំពុងលាក់ខ្លួននៅប្រទេសថៃ

https://khmer.voanews.com/ ដោយ មាន ឫទ្ធិ 2018-07-02

ពលករខ្មែរនៅប្រទេសថៃ អំពាវនាវឲ្យអាជ្ញាធររបបលោក ហ៊ុន សែន ជួយអន្តរាគមន៍ដល់ពលករខ្មែរខ្វះក្រដាសស្នាម ហើយកំពុងលាក់ខ្លួននៅប្រទេសថៃ ខណៈអាជ្ញាធរថៃចាប់ផ្តើមរឹតបន្តឹងក្រឹត្យច្បាប់ការងារថ្មីចាប់ពីថ្ងៃទី១ កក្កដា នេះតទៅ។

ពលករខ្មែរម្នាក់ឈ្មោះ សុខ ទី ធ្វើការនៅខេត្តអយុធ្យា ប្រទេសថៃ បានថ្លែងប្រាប់អាស៊ីសេរី កាលពីយប់ថ្ងៃទី១ ខែកក្កដា ថា នៅខេត្តដែលលោកកំពុងបំពេញការងារនេះ នៅមិនទាន់ឃើញមានអាជ្ញាធរ ឬទាហានថៃ ចុះមកត្រួតពិនិត្យនៅឡើយទេ។ លោកថា ខាងអ្នកគ្រប់គ្រងកន្លែងដែលលោកធ្វើការ បានជូនដំណឹងរួចហើយដល់ពលករទាំងអស់ ឲ្យដឹងថា ចាប់ពីថ្ងៃទី១ កក្កដា នេះទៅ នឹងមានការចុះត្រួតពិនិត្យគ្រប់ទីកន្លែង។ ក៏ប៉ុន្តែ លោកថា មិត្តភក្តិរបស់លោក ឲ្យលោកដឹងថា នៅខេត្តបុទុមថានី ឯណោះវិញ មានការចុះត្រួតពិនិត្យ និងឆែកឆេរនៅតាមរោងចក្រមួយចំនួនជាបណ្តើរៗហើយ៖ «ខ្ញុំទើបតែបានដំណឹងពីមិត្តភក្តិដែលធ្វើការនៅរោងចក្របុទុមថានី គឺគាត់បានប្រាប់

មកថា មានអាជ្ញាធរចុះត្រួតពិនិត្យ និងចាប់ខ្លួនពលករខ្មែរខុសច្បាប់បាន៨នាក់។ ហើយនៅកន្លែងខ្ញុំ ក៏មានដែរ ដែលបងប្អូនខ្មែរ ចំនួន១៤នាក់ដែលមិនអាចតច្បាប់ការងារបាន គឺគាត់ចុះទៅខ្មែរ ដើម្បីទៅបន្តវីសា ហើយនឹងទៅធ្វើច្បាប់ការងារចូលមកសាជាថ្មី»។ លោកបន្ត ពលករខ្មែរទាំង១៤រូបនោះ បានចាកចេញទៅប្រទេសកម្ពុជាវិញ មួយថ្ងៃមុនថ្ងៃទី១ កក្កដា ដែលអាជ្ញាធរថៃចាប់ផ្តើមរឹតបន្តឹងករណីពលករធ្វើការនៅប្រទេសថៃដោយខុសច្បាប់នេះ ដោយសារតែកន្លែងធ្វើការរបស់ពួកគេ មិនអាចទុកពួកគេឲ្យនៅធ្វើការបន្តបានទេ ដោយតម្រូវឲ្យពួកគាត់ត្រលប់ទៅស្រុកខ្មែរវិញ មួយរយៈសិន ដើម្បីឲ្យពួកគេធ្វើឯកសារស្របច្បាប់ឡើងវិញ៖ «ខ្ញុំបានតាមដាននូវព័ត៌មានពីក្រសួងការងារថៃ គេថាប្រហែលជា បងប្អូនទាំងខ្មែរ ទាំងឡាវ និងទាំងមីយ៉ាន់ម៉ាគឺទាំងអស់នៅសល់ជាង៥ម៉ឺននាក់ទៀត ដែលបន្តច្បាប់ការងារមិនទាន់បាន»។

ចំណែកឯពលករខ្មែរម្នាក់ទៀតឈ្មោះ ក្រាញ់ តារូ ដែលកំពុងធ្វើការនៅទីក្រុងបាងកក ប្រទេសថៃ បានឲ្យអាស៊ីសេរី ដឹងកាលពីថ្ងៃទី១ កក្កដា នេះថា បច្ចុប្បន្ននេះ អាជ្ញាថៃ ចាប់ផ្តើមចុះគោះទ្វារតាមផ្ទះ ហើយថាប្រសិនបើមិនស្របច្បាប់ គឺពួកគេធ្វើការចាប់ខ្លួនតែម្តង៖ «បាទ! ថ្ងៃមុនគឺចូលមកគោះដល់ផ្ទះខ្ញុំហ្នឹងឯង។ ចូលមកថតមកអី ប៉ុន្តែខ្ញុំស្របច្បាប់អស់ហើយ អត់បានធ្វើអីទេ។ ថ្ងៃទី១នេះអត់ទាន់មានទេ តែកន្លែងខ្ញុំគឺមកពីម្សិលម៉ិញនេះឯង មកចូលដល់ផ្ទះខ្ញុំហ្នឹងឯង»។ លោកថា មកទល់ពេលនេះ ពលករដែលមិនទាន់ស្របច្បាប់ គឺនៅមានចំនួនច្រើន ហើយខ្លះទៀតបានវិលត្រលប់ទៅផ្ទះវិញដោយសារតែពួកគេមានការភ័យខ្លាចការចាប់ខ្លួនពីអាជ្ញាធរថៃ៖ «ម្សិលមិញ គឺមាន...ត្រូវជាអ្នកភូមិខ្ញុំហ្នឹងគេចុះទៅពីរបីនាក់ដែរ គឺខ្លាចដែរ ព្រោះអីបើសិនជាអាជ្ញាធរថៃចាប់បាន គឺផាកពិន័យបើមិនចង់ជាប់គុក គឺត្រូវបង់ចាប់ពី៥ពាន់ ដល់៥ម៉ឺនបាតឯណោះ..! ខ្លះសម្ងំលាក់ខ្លួនរង់ចាំឲ្យគេធ្វើច្បាប់ថ្មី»។

ពលករដដែល សំណូមពរដល់អាជ្ញាធរកម្ពុជាអង្វរករដល់អាជ្ញាធរថៃឲ្យពន្យារពេលផ្តល់ភាពស្របច្បាប់ដល់ពលករដែលគ្មានក្រដាសស្នាមនេះជាបន្តទៅទៀត ដោយសារតែនៅមានពលករដែលមិនទាន់ស្របច្បាប់នេះច្រើនទៀត៖ «សូមឲ្យរាជរដ្ឋាភិបាល សំណូមពរដល់អាជ្ញាធរថៃផង ឲ្យថៃបើបន្តធ្វើការងារផ្តល់ភាពស្របច្បាប់នេះបន្តទៅទៀត ព្រោះអីពលករដែលខុសច្បាប់ គឺមានច្រើនណាស់។ ឥឡូវនេះ កំពុងតែលាក់ខ្លួនយ៉ាងសកម្ម។ អាណិតពួកគាត់ផងបាទ! បើសិនជាគាត់មានលុយគឺគាត់ មិនចំណាកស្រុកទេ។ គឺគាត់អត់ខ្លាំង»។

ពលករម្នាក់ទៀត ដែលនិយាយសុំមិនបញ្ចេញឈ្មោះ ថ្លែងប្រាប់អាស៊ីសេរី ស្នើឲ្យអាជ្ញាធរខ្មែរ មើលឃើញពីភាពលំបាករបស់ពលករខ្មែរទាំងនេះ ដោយបើកធ្វើលិខិតឆ្លងដែនក្នុងតម្លៃទាបជាងបច្ចុប្បន្ននេះ ព្រោះពួកគេជួបការលំបាកខ្លាំង៖ «ខ្ញុំសំណូមពរទៅរាជរដ្ឋាភិបាលខ្មែរយើងហ្នឹង ពាក្យយ៉ាងខ្លីទេ ដែលថា គឺសូមសំណូមពរថា ឲ្យគាត់ជួយមើលពលករចំណាកស្រុក ដូចជាខ្មែរយើងផង ឲ្យគាត់ជួយសម្រួលមួយវគ្គនេះ។ ចង់ឲ្យគាត់សម្រួលថា ឲ្យពលករយើងទៅធ្វើប៉ាស្ព័រហ្នឹង ធ្វើម៉េចកុំឲ្យ គិតលុយពីគាត់ហ្នឹង សុំឲ្យគាត់ធ្វើ ដូចថា ពលករយើងសព្វថ្ងៃ កំពុងតែជាប់លុយអង្គការអីចឹង។ ដល់អ៊ីចឹងទៅ ទៅវិញក៏ទៅអត់កើត។ អត់មានលុយ ដល់អ៊ីចឹងទៅ បើសិនជាធ្វើប៉ាស្ព័រក៏អត់មានលុយដែរ ហើយបើសិនជាយើងនៅ គេចាប់យើងបញ្ជូនទៅវិញ។ អ៊ីញ្ចឹងវាអត់មានជម្រើស។ អ៊ីញ្ចឹងចង់ឲ្យរដ្ឋាភិបាលយើងធ្វើប៉ាស្ព័រឲ្យដោយមិនគិតច្បាប់»។ សំណូមពរនឹងការលើកឡើងរបស់ពលករខ្មែរទាំងប៉ុន្មានរូបនេះ គឺខណៈអាជ្ញាធរថៃ ចាប់ផ្តើមបង្ក្រាបពលករចំណាកស្រុកខុសច្បាប់ចាប់ពីថ្ងៃអាទិត្រទី១ កក្កដា នេះ។

កាសែត ឌឹណេសិន (The Nation) ចេញផ្សាយកាលពីថ្ងៃទី១ កក្កដា បានស្រង់សំដីរបស់ប្រធាននគរបាលអន្តោប្រវេសន្តតំបន់៦ ឧត្តមសេនីយ៍យេសសាដា យ៉ៃស៊ូន (Jessada Yaisoon) ដែលបានអោយដឹងថា ការបង្ក្រាបពលករចំណាកស្រុកខុសច្បាប់ មកពីប្រទេសឡាវ ភូមា និងកម្ពុជា នៅថ្ងៃអាទិត្យ ទី១ កក្កដានេះ បន្ទាប់ពីឱសានវាទនៃការចុះឈ្មោះអោយស្របច្បាប់បានផុតកំណត់កាលពីថ្ងៃសៅរ៍ ទី៣០ មិថុនា។ ជនចំណាកស្រុកទាំងឡាយណា ដែលមិនបានចុះបញ្ជីនឹងត្រូវពិន័យជាប្រាក់ចំនួនប្រាំពាន់បាត (៥.០០០) ទៅប្រាំម៉ឺនបាត

(៥០.០០០) មុននឹងនិរទេសចេញពីប្រទេសថៃ ព្រមទាំងហាមមិនអោយធ្វើការនៅក្នុងប្រទេសថៃរយៈពេល២ឆ្នាំទៀតផង។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្លាប់ឲ្យដឹងថា គិតត្រឹមចុងខែឧសភា កម្ពុជា និងថៃ បានរួមគ្នាផ្តល់ភាពស្របច្បាប់ដល់ពលករចំណាកស្រុកខ្មែរបានជាង ៣សែននាក់ហើយ ក្នុងចំណោមពលករខ្មែរជាង ៤សែននាក់ ដែលកំពុងធ្វើការងារខុសច្បាប់ ឬគ្មានឯកសារនៅក្នុងប្រទេសថៃ ហើយថា ពលករចំណាកស្រុកខ្មែរ ដែលកំពុងធ្វើការដោយគ្មានឯកសារស្របច្បាប់ក្នុងប្រទេសថៃ ពីមុនមកនេះ ឥឡូវនេះបានទទួលភាពស្របច្បាប់ជិតអស់ហើយ។

អាជ្ញាធរថៃក្រោមការដឹកនាំដោយរបបយោធារបស់នាយករដ្ឋមន្ត្រី លោក ប្រាយុទ្ធ ចាន់អូចា បានរឹតបន្តឹងបញ្ហាជនអន្តោប្រវេសន៍ខុសច្បាប់ ដោយបានចេញក្រឹត្យច្បាប់ថ្មី ដែលតម្រូវឲ្យមានការពិន័យ និងដាក់ទណ្ឌកម្មយ៉ាងតឹងរ៉ឹងបំផុតចំពោះករណីនេះ និងបានទុកពេលវេលាឲ្យកម្ពុជាផ្តល់ភាពស្របច្បាប់ដល់ពលករចំណាកស្រុករបស់ខ្លួន ឲ្យបានចប់សព្វគ្រប់ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ មុននឹងក្រឹត្យច្បាប់ថ្មីនេះ មានសុពលភាពចាប់ផ្តើមអនុវត្តជាផ្លូវការ ចាប់ពីថ្ងៃទី០១ កក្កដា នេះតទៅ។ បច្ចុប្បន្ន មានពលករចំណាកស្រុកខ្មែរចំនួនជាង ១លាន ៦ម៉ឺននាក់ កំពុងធ្វើការស្របច្បាប់នៅប្រទេសថៃ៕

## ពលករខ្មែរធ្វើការខុសច្បាប់កំពុងភ័យខ្លាចបន្ទាប់ពីឱសានវាទរបស់ថៃរឹតបន្តឹងច្បាប់ពលករ

https://khmer.voanews.com/ វ៉ែន សុមេធ 2018-07-02

ពលករខ្មែរដែលធ្វើការនៅប្រទេសថៃខុសច្បាប់មួយចំនួន កំពុងតែភ័យខ្លាចអាជ្ញាធរថៃចាប់បញ្ជូនពួកគេត្រឡប់ទៅស្រុកកំណើតវិញ ហើយធ្វើឲ្យគ្មានការងារធ្វើរកប្រាក់ដោះស្រាយជីវភាពប្រចាំថ្ងៃ។ ការភ័យខ្លាចនេះដោយសារតែដល់ថ្ងៃឱសានវាទ ដែលក្រសួងការងារថៃចាប់ផ្តើមអនុវត្តន៍ច្បាប់លើពលករទាំងឡាយណាដែលធ្វើការងារខុសច្បាប់នៅក្នុងប្រទេសថៃ។

ក្រោយពីដល់ថ្ងៃកំណត់ឱសានវាទរបស់ក្រសួងការងារថៃ ដោយចាប់ពីថ្ងៃទី១ កក្កដាមក ពលករធ្វើការខុសច្បាប់នៅតំបន់ខ្លះ ចាប់ផ្តើមរត់គេចខ្លួនស្ងាត់ពីកន្លែងធ្វើការ ដោយមិនហ៊ានប្រថុយធ្វើការដូចពេលមុននោះឡើយ។ ពលករធ្វើការងារនៅប្រទេសថៃសុំមិនឲ្យបញ្ចេញឈ្មោះម្នាក់ ឲ្យដឹងនៅព្រឹកថ្ងៃទី២ កក្កដា ថា នៅក្បែរកន្លែងដែលពួកគាត់ធ្វើការនៅតំបន់មាត់សមុទ្រភាគខាងកើតប្រទេសថៃ មានពលករខ្មែរប្រមាណ៧០នាក់ ដែលធ្វើការខុសច្បាប់នោះ ពួកគាត់បាននាំគ្នារត់គេចខ្លួនស្ងាត់ពីកន្លែងការងារនៅយប់ថ្ងៃ៣០ មិថុនា។ ពលកររូបនេះអះអាងទៀតថា ការរត់គេចខ្លួននេះដោយសារពួកគាត់ភ័យខ្លាចសមត្ថកិច្ចថៃ ចុះឆែកឆេរចាប់ពួកគេផ្តន្ទាទោសតាមច្បាប់ការងារថៃ មុននឹងបញ្ជូនពួកគេត្រឡប់ទៅកម្ពុជាវិញ៖ «ហើយក៏វេទនាណាស់ ព្រោះពេលប៉ូលិសចុះចាប់ គឺពួកគាត់រត់ពួនទៅ ដូច្នេះវាវេទនា ណាស់ការរស់នៅស្រុកគេគ្មានឯកសារត្រឹមត្រូវនោះ។ កាលដែលខ្ញុំធ្វើការខុសច្បាប់ក៏ខ្ញុំដូចគ្នាដែរ ខ្ញុំធ្លាប់ឆ្លងកាត់បានជាខ្ញុំប្រាប់ពួកគាត់ ខ្ញុំធ្លាប់ធ្វើការឲ្យគេ ហើយថៅកែមិនឲ្យលុយក៏មានដែរ ដោយសារតែគ្មានឯកសារហើយខ្ញុំក៏មិនហ៊ានតវ៉ាជាមួយគេដែរ»។

ចំណែកពលការិនី ធ្វើការនៅប្រទេសថៃម្នាក់ទៀតអះអាងថា រូបគេបានចូលមកប្រទេសថៃតាមច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ហើយបានធ្វើការងារខុសច្បាប់ប្រហែល៦ខែហើយ។ ពលការិនីរូបនេះបន្ថែមទៀតថា ចាប់ពីថ្ងៃទី១ កក្កដា ខ្លួនមានការភ័យខ្លាចយ៉ាងខ្លាំង ព្រោះខ្លាចសមត្ថកិច្ចថៃចាប់បញ្ជូនត្រឡប់ទៅស្រុកកំណើតវិញ ហើយធ្វើឲ្យមិនមានការងារធ្វើដើម្បីរកប្រាក់ចំណូលដោះស្រាយជីវភាពគ្រួសារបាន៖ «យើងជាអ្នកក្រខ្សត់យើងមកធ្វើការលក់កម្លាំងដើម្បីរកលុយ ដល់ពេលយើងអត់មានលុយធ្វើលិខិតឆ្លងដែនយើងរស់នៅពិបាកនៅស្រុកគេដោយត្រូវគេចាប់ចង និងចាប់បញ្ជូនយើងទៅផ្ទះវិញ។ បើយើងអត់យើងគ្មានអ្នកជួយទោះបីជាយើងនៅផ្ទះក៏គ្មាន

អ្នកជួយ ដូច្នេះមានតែយើងធ្វើការងារដើម្បីរកលុយទៅចិញ្ចឹមជីវិត ដល់ពេលគេចាប់យើងពិបាកណាស់ ព្រោះជីវភាពក្រីក្រគ្មានការងារធ្វើ ទោះបីជាខ្ញុំទៅខ្មែរក៏គ្មានអ្នកជំនួយខ្ញុំដែរ»។

ថ្មីៗនេះ ស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក បានជូនដំណឹងដល់ពលករនៅប្រទេសថៃដោយបានបញ្ជាក់ថា ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៨ តទៅ អាជ្ញាធរថៃនឹងចាប់ផ្តើមអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងការធ្វើការរបស់ពលករបរទេស ដោយមិនអនុញ្ញាតអោយពលករខុសច្បាប់នៅក្នុងប្រទេសថៃបន្តទៀតនោះឡើយ ហើយប្រសិនបើពលករធ្វើការខុសច្បាប់នឹងទទួលទោសតាមផ្លូវច្បាប់។ ស្ថានទូតខ្មែរ ឲ្យដឹងទៀតថា ដូច្នោះខាងស្ថានទូតបានរៀបចំចេញលិខិតធ្វើដំណើរបណ្តោះអាសន្ន (Laissez-Passer) ជូនដល់ពលករដែលមិនមានឯកសារធ្វើការនៅក្នុងប្រទេសថៃ អាចធ្វើដំណើរត្រឡប់ទៅប្រទេសកម្ពុជាវិញបាន។ ស្ថានទូតក៏បានអំពាវនាវឲ្យពលករទាំងអស់ អនុវត្តតាមការជូនដំណឹងរបស់ស្ថានទូត ដើម្បីជៀសវាងបញ្ហាផ្សេងៗដែលអាចកើតមានឡើងនៅក្នុងកំឡុងពេលការអនុវត្តនេះ។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធមនុស្សអាដហុក (Adhoc) ប្រចាំខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា មានប្រសាសន៍ថា លិខិតធ្វើដំណើរដែលចេញដោយស្ថានទូតនេះ គ្រាន់តែជាការដោះស្រាយរយៈពេលខ្លី ដើម្បីសម្រួលដល់ពលករបានត្រឡប់ទៅចូលរួមបោះឆ្នោតនៅថ្ងៃទី២៩ កក្កដា ប៉ុណ្ណោះ។ លោក ស៊ុំ ច័ន្ទគា អះអាងទៀតថា ការធ្វើបែបនេះ មិនមែនជាដំណោះស្រាយសមស្របនោះទេ ព្រោះពលករអាចប្រឈមនឹងទទួលទោសតាមច្បាប់របស់ប្រទេសថៃនៅថ្ងៃក្រោយទៀត ដោយសារតែពួកគេគ្មានការងារនៅក្នុងស្រុក ហើយពួកគាត់ចាំបាច់ត្រូវធ្វើចំណាកស្រុកទាំងប្រថុយប្រថានបន្តទៀត៖ «ព្រោះពលករទាំងអស់ដែលនៅប្រទេសថៃនឹងភាគច្រើនពួកគាត់មិនពេញចិត្តទៅលើបក្សណាដែលធ្វើបាប ឬវាយដំច្រំធាក់ប្រជាពលរដ្ឋ ពួកគាត់នៅខាងក្រៅមិនពេញចិត្តទេ ព្រោះដោយសារតែពួកគាត់ឃើញប្រទេសគេយកចិត្តទុកដាក់លើពលករគេ ដូច្នេះបានជាការជួយរបស់មន្ត្រីខ្មែរនេះ មិនមែនជាការជួយយូរអង្វែងទេ ដែលជួយឲ្យពលករផុតទុក្ខពីការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ ហើយគាត់ត្រឡប់មកវិញនឹងត្រូវធ្វើលិខិតធ្វើអីត្រូវចំណាយលុយច្រើន ហើយសព្វថ្ងៃនឹងដំណាំកសិផលរបស់កសិករគ្មានទីផ្សារ ធ្វើឲ្យពលរដ្ឋជំពាក់ធនាគារគ្មានលុយសង»។

ច្បាប់របស់ក្រសួងការងារថៃ ដែលបានចាប់អនុវត្តន៍ពីថ្ងៃទី១ កក្កដានោះ គឺពលករដែលធ្វើការមិនមានប័ណ្ណអនុញ្ញាតការងារ ឬធ្វើការក្រៅពីសិទ្ធិដែលអាចធ្វើបាន នឹងត្រូវទទួលការផាកពិន័យពី ៥ពាន់បាត (៥.០០០) ទៅ៥ម៉ឺនបាត (៥០,០០០) ឬប្រមាណពី ១៧០ទៅ ១.៧០០ដុល្លារអាមេរិក ហើយពលករនឹងត្រូវបញ្ជូនត្រឡប់ទៅប្រទេសកំណើតវិញ ហើយហាមឃាត់មិនឱ្យធ្វើការនៅប្រទេសថៃ រយៈពេល ២ឆ្នាំ ដោយគិតចាប់ពីថ្ងៃទទួលពិន័យ។ ចំណែក និយោជកដែលប្រើប្រាស់ពលករខុសច្បាប់ នឹងត្រូវទទួលពិន័យពី ១ម៉ឺន (១០,០០០) ទៅ ១០ម៉ឺនបាត (១០០,០០០)ឬប្រមាណពី៣០០ទៅ៣ពាន់ដុល្លារអាមេរិក ក្នុងពលករម្នាក់ ហើយករណីនិយោជកប្រព្រឹត្តកំហុសដដែល នឹងត្រូវទទួលទោស ជាប់ពន្ធនាគារ ១ឆ្នាំ ឬពិន័យជាទឹកប្រាក់ ពី៥ម៉ឺនទៅ ២០ម៉ឺនបាត ឬប្រមាណពី១.៥០០ ទៅជាង៦.០០០ដុល្លារ ក្នុងពលករម្នាក់ និងហាមមិនឱ្យជួលពលករបរទេសរយៈពេល៣ឆ្នាំ។

ចំណែកពលករដែលមានបំណងចង់ទៅធ្វើការនៅប្រទេសថៃ នៅក្រោយពីថ្ងៃទី១កក្កដានោះ គឺត្រូវទៅធ្វើការតាមរយៈក្រុមហ៊ុនដែលនាំពលករស្របច្បាប់ ដែលក្រសួងការងារកម្ពុជា-ថៃ បានឯកភាពគ្នា តាមរយៈការចុះអនុស្សរណៈ(MOU) ប៉ុណ្ណោះ។ សព្វថ្ងៃពលរដ្ឋខ្មែរដែលធ្វើការនៅប្រទេសថៃទាំងស្របច្បាប់ និងខុសច្បាប់មានប្រមាណ១លាននាក់។ លោក ស៊ុំ ច័ន្ទគា ឲ្យដឹងថា ចាប់ពីថ្ងៃទី១ កក្កដាមក ស្ថានភាពនៅតាមព្រំដែនក្នុងខេត្ត

បន្ទាយមានជ័យ មានសភាពស្ងប់ស្ងាត់ជាធម្មតា ដោយពុំមានការចាប់បញ្ជូនពលករត្រឡប់មកកម្ពុជាច្រើនដែលបណ្តាលឲ្យមានការរាំងស្ទះនៅច្រកព្រំដែន ឬជាការព្រួយបារម្ភអារម្មណ៍នោះទេ៕

## ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨

## លោក អូស្មាន ហាស្សាន់៖ ពលការនី កែន ចន្ថា ដែលចាញ់បោកមេខ្យល់៤ឆ្នាំ ទៅធ្វើការនៅអារ៉ាប៊ីសាអូឌីត ត្រូវបានសង្គ្រោះឲ្យត្រឡប់មកកម្ពុជាវិញ

http://nokorwatnews.com/ 04-07-2018

ភ្នំពេញ៖ លោក អូស្មាន ហាស្សាន់ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តល់កិច្ចអន្តរាគមន៍ ដល់ពលការនី កែន ចន្ថា ដែលបានចាញ់បោកមេខ្យល់ បានបញ្ជូននាងទៅបម្រើការងារដោយ ខុសច្បាប់ នៅអារ៉ាប៊ីសាអូឌីត អស់រយៈពេលជាង៤ឆ្នាំ ។ ការផ្តល់កិច្ចអន្តរាគមន៍នេះ ឆ្លើយតបនឹង ការទទួចស្នើសុំជំនួយពី ពលការនីខាងលើ តាមបណ្តាញសង្គមហ្វេសប៊ុក ដែលបានរៀបរាប់ពីដំណើរដើមទង នៃការដែលខ្លួនត្រូវបានចាញ់បោកមេខ្យល់មកធ្វើជា ពលការនីបម្រើការងារផ្ទះនៅអារ៉ាប៊ីសាអូឌីត ដោយរងការកេងប្រវញ្ចកម្លាំងពលកម្ម ការធ្វើទុក្ខបុកម្នេញពីថៅកែ និង ការមិនផ្តល់ប្រាក់បៀវត្សជាដើម ។

យោងតាញសង្គមហ្វេសប៊ុកផ្ទាល់របស់ លោក អូស្មាន ហាស្សាន់ ដែលបានបង្ហោះ កាលពីរសៀលថ្ងៃទី០៣ កក្កដា ២០១៨ ភ្ជាប់ជាមួយនឹងរូបភាពរបស់ ពលការនីរងគ្រោះខាងលើ ដែលមានទឹកមុខរីករាយ ខណៈកំពុងនៅលើយន្តហោះធ្វើដំណើរពីទីក្រុងជុដះ ប្រទេសអារ៉ាប៊ីសាអូឌីត ឆ្ពោះមកកាន់ទីក្រុងបាងកក ដើម្បីបន្តដំណើរ ត្រឡប់មកកម្ពុជា ដែលនឹងមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញនៅព្រឹកថ្ងៃទី ០៤ កក្កដា ២០១៨ នេះ ។ នៅលើគេហទំព័រហ្វេសប៊ុករបស់លោក អូស្មាន ហាស្សាន់ បានសរសេរថា៖ ពលការនីខ្មែរ ឈ្មោះ កែន ចន្ថា មានទីលំនៅកំណើត ភូមិវត្តបូព៌ ឃុំសៀមរាប ស្រុក សៀមរាប ខេត្ត សៀមរាប ដែលបានទៅធ្វើការងារបំរើតាមផ្ទះនៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត រយៈជាង ៤ ឆ្នាំដោយចាញ់បោក ពួកមេខ្យល់ បានសុំឲ្យខ្ញុំ និង ក្នុងនាមរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជួយ រំដោះនាង មក កម្ពុជាវិញនោះ នឹងមកដល់កម្ពុជានៅព្រឹកថ្ងៃទី ០៤ .០៧ .២០១៨ វេលាម៉ោង ៩.៣០នាទីព្រឹក តាមជើងយន្តហោះ បាងកក PG – នេះជានារី រងគ្រោះ ទី៤ ហើយដែលខ្ញុំបាន ដោះស្រាយឲ្យបានវិលត្រឡប់មកកម្ពុជាវិញនោះ ដោយសារតែនៅប្រទេសអារ៉ាប់នោះ មិនទាន់មាន ស្ថានទូត ឬ ស្ថានកុងស៊ុល រាល់ការដោះស្រាយ បញ្ហាផ្សេងៗ មានការលំបាក យឺតយ៉ាវដែលលើកទី ១ខ្ញុំ បានសហការនឹងទូត យើង ប្រចាំនៅ គុយវ៉ែតផង អេហ្ស៊ីបផង ឯលើក ទី ២,៣,៤ សហការនឹងទូតយើង ប្រចាំនៅអេហ្ស៊ីប -ត្រឡប់មកវិញនេះពលការនី មិនទទួលបាន ប្រាក់ខែពីថៅកែទី១នោះទេ តែបានពីថៅកែទី២ ។

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ នឹង សហការជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីចាត់វិធានការទៅតាមផ្លូវច្បាប់ លើជនខិលខូច ជាមេខ្យល់នោះដែរ ៕ សំរិត

## ត្រៀមបញ្ជូនពលករខុសច្បាប់ចំនួន 22 នាក់ទៅតុលាការ

http://www.khmerlabour.com/ ប្រភព Khmerlabour 03-07-2018

យោងតាមប្រសាសន៍របស់លោក អនុរ៉ាត ទុត្យារ៉ាត់អគ្គនាយកដ្ឋាននៃក្រសួងការងារថៃ បានមានប្រសាសន៍កាលពីថ្ងៃទី02 ខែកក្កដា ឆ្នាំ2018 ម្សិលមិញនេះបានអោយដឹងអាជ្ញាធរថៃត្រៀមបញ្ជូនខ្លួនពលករខុសច្បាប់ចំនួន 22នាក់ ទៅតុលាការដើម្បីចាត់ការតាមផ្លូវច្បាប់រួចបញ្ជូនអោយទៅប្រទេសរបស់គេវិញបន្ទាប់ពីកម្លាំងសមត្ថកិច្ចចម្រុះថៃបានបើកយុទ្ធនាការបង្រ្កាបពលករខុសច្បាប់លើកដំបូងកាលថ្ងៃទី01 ខែកក្កដាកន្លងទៅតាមនិតិវិធីច្បាប់គ្រប់គ្រងពលករបរទេសឆ្នាំ2018។

គួរបញ្ជាក់ផងដែរថាចាប់ពីថ្ងៃទី01 ខែកក្កដា ឆ្នាំ2018 ប្រសិនបើរកឃើញពលករបរទេសណា ដែលធ្វើការមិនមានប័ណ្ណអនុញ្ញាតការងារ ឬធ្វើការក្រៅពីសិទ្ធិដែលអាចធ្វើបាន នឹងត្រូវទទួលការផាកពិន័យជាទឹកប្រាក់ចាប់ពី ៥,០០០បាត ទៅ ៥០,០០០បាត ហើយនៅពេលពលករបរទេសបង់ប្រាក់ពិន័យហើយ ពលករនោះនឹងត្រូវបញ្ជូនត្រឡប់មកប្រទេសកំណើតវិញ ដោយហាមមិនឱ្យសុំធ្វើការនៅប្រទេសថៃ រយៈពេល២ ឆ្នាំ គិតចាប់ពីថ្ងៃទទួលការផាកពិន័យ។ ចំណែក និយោជកណាដែលប្រើប្រាស់ពលករបរទេសដែលមិនមានប័ណ្ណអនុញ្ញាតការងារ នឹងត្រូវទទួលការពិន័យជាទឹកប្រាក់ ពី ១០,០០០ ទៅ ១០០,០០០បាត ក្នុងពលករម្នាក់ ហើយបើនិយោជកនោះ ប្រព្រឹត្តកំហុសដដែល នឹងត្រូវទទួលទោស ដាក់ពន្ធធនាគារ ចំនួន ១ឆ្នាំ ឬពិន័យជាទឹកប្រាក់ ពី ៥០,០០០បាត ទៅ ២០០,០០០បាត ក្នុងពលករម្នាក់ និងបញ្ឈប់មិនឱ្យជួលពលករបរទេសរយៈពេល ៣ឆ្នាំ។ បើសិនជាពលករបរទេសទាំង៣ សញ្ជាតិដែលមានបំណងចង់មកធ្វើការនៅក្នុងប្រទេសថៃ គឺត្រូវតែចូលមកធ្វើការតាមរយៈអនុស្សរណៈនៃការយោគយល់គ្នា MOUតែប៉ុណ្ណោះ។ ប្រភពពី÷matichon

## ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨

## ក្រសួងការងារនឹងសហការជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីចាត់វិធានការលើជនខិលខូចជាមេខ្យល់នាំពលការនីដោយខុសច្បាប់ទៅបម្រើការងារនៅអារ៉ាប៊ីសាអូឌីត

http://www.cen.com.kh/archives/ July 4, 2018

ភ្នំពេញ ៖ មន្ត្រីជាន់ខ្ពស់ក្រសួងការងារ ថ្លែងនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្នុងឱកាសដែលអញ្ជើញទទួលការវិលត្រឡប់មកដល់កម្ពុជាវិញរបស់ពលការនី កែន ចន្ថា ដែលរងគ្រោះដោយការចាញ់បោកមេខ្យល់បញ្ជូនទៅធ្វើការដោយខុសច្បាប់ នៅអារ៉ាប៊ីសាអូឌីតអស់រយៈពេលជាង៤ឆ្នាំ លោក អ៊ូស្មាន ហាស្សាន់ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ថា៖ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីចាត់វិធានការទៅតាមផ្លូវច្បាប់ ទៅលើជនខិលខូចជាមេខ្យល់ ដែលនាំពលការនី កែន ចន្ថា ទៅបម្រើការងារជាស្ត្រីមេផ្ទះនៅអារ៉ាប៊ីសាអូឌីត ហើយព្រមានទៅកាន់ភ្នាក់ងារ រឺមេខ្យល់ផ្សេងៗទៀត ដែលបាននិងកំពុងមានសកម្មភាពដូចគ្នា ត្រូវបញ្ឈប់ជាបន្ទាន់ ហើយត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ រាល់ពលការនីដែលខ្លួនបានបញ្ជូនទៅក្រៅប្រទេសដោយខុស ច្បាប់ ។ លោកបានបញ្ជាក់បែបនេះនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីថ្ងៃពុធ ៧រោច ខែបឋមាសាឍ ឆ្នាំចសំរឹទ្ធិស័កព.ស២៥៦២ត្រូវនិងថ្ងៃទី០៤ កកដ្ឋា ឆ្នាំ២០១៨ ។

ពលការនី កែន ចន្ថា បានប្រាប់ទាំងទឹកភ្នែក ពីទុក្ខលំបាករបស់ខ្លួនគ្រប់បែបយ៉ាង ក្នុងកំឡុងពេលជាងបួនឆ្នាំមកនេះ ខ្លួនត្រូវបានថៅកែធ្វើទុក្ខបុកម្នេញ គ្រប់រូបភាព កេងប្រវ័ញ្ចកម្លាំងពលកម្ម ការមិនផ្តល់ប្រាក់បៀវត្ស និងការហូបចុកមិនបានគ្រប់គ្រាន់ ហើយខ្លួនត្រូវបានគេបញ្ជូនទៅ មប្រើការងារ មេផ្ទះពីថៅកែមួយទៅ ថៅកែមួយ ហើយរហូតដល់ថៅកែទី៤ ទើបខ្លួនទទួលបានការងារល្អ មានប្រាក់បៀវត្ស និង ការបម្រើកការងារទៅតាមពេលវេលាសម្រាក់ ។ ទោះបីយ៉ាងណា ពលការនី កែន ចន្ថា បានអំពាវនាវ ដល់ពលករ ពលការនីខ្មែរទាំងឡាយ ដែលមានបំណងចង់ទៅធ្វើការនៅក្រៅប្រទេស សូមពិនិត្យមើល និង ស៊ើបសួរពីប្រវត្តិរបស់ភ្នាក់ងារ នោះអោយបានច្បាស់លាស់ ជាពិសេសត្រូវអញ្ជើញទៅតាមក្រុមហ៊ុនស្របច្បាប់ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ ដើម្បីសុវត្ថិភាព ការទំនួលខុសត្រូវខ្ពស់ពីក្រុមហ៊ុនទាំងក្នុង និងក្រៅប្រទេស ជាគោលដៅ ក៏ដូចជាការទទួលដឹងលឺពីអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេស នោះ ផងដែរ។ ពលការនី កែន ចន្ថា បានថ្លែងអំណរគុណ ដល់ប្រមុខរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់សម្តេចអគ្គមហា សេនាបតីតេជោ ហ៊ុន សែន និងថ្លែងអំណរគុណដល់ថ្នាក់ដឹក នាំក្រសួងពាក់ព័ន្ធដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ដែលតែងតែចេញមុខដោះស្រាយបញ្ហាកង្វល់ផ្សេងៗរបស់ប្រជាពលរដ្ឋ ។

លោក អ៊ូស្មាន ហាស្សាន់ បានបញ្ជាក់ថា៖ ពលការនីខ្មែរ ឈ្មោះ កែន ចន្ថា មានទីលំនៅកំណើត ភូមិវត្តបូព៌ ឃុំសៀម រាប ស្រុកសៀមរាប ខេត្តសៀមរាប ដែលបានទៅធ្វើការងារបំរើតាមផ្ទះនៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត រយៈជាង ៤ ឆ្នាំដោយចាញ់បោក ពួកមេខ្យល់ បានសុំអោយខ្ញុំ និងក្នុងនាមរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោកខិតខំព្យាយាមទំនាក់ទំនងគ្រប់បែបយ៉ាង ដើម្បីជួយរំដោះនាង មក កម្ពុជាវិញ បន្ទាប់បានទទួល

ដំណឹងតាមរយៈបណ្ដាញសង្គមហ្វេសប៊ុក ប្រមាណជាង១ខែមកនេះ ។ ហើយដែលខ្ញុំបានដោះ ស្រាយអោយបានវិលត្រឡប់មកកម្ពុជាវិញ មានការឃើតយ៉ាវនេះ ដោយសារតែ នៅប្រទេសអារ៉ាប់នោះ មិនទាន់មាន ស្ថានទូត ឬស្ថានកុងស៊ុលសម្រាប់ទំនាក់ទំនងនិង ដើម្បីដោះស្រាយ បញ្ហាផ្សេងៗ ចំពោះពលការិនី ដែលទៅធ្វើការងារនៅទីនោះមានការលំបាកឃើតយ៉ាវ។ហើយនេះជានារីរង គ្រោះ ទី៤ហើយដែលខ្ញុំបានជួយដោះស្រាយអោយបានវិលត្រឡប់មកកម្ពុជាវិញ ៕ ដោយៈ បញ្ញាស័ក្តិ

## ថៃជួយពលករខ្មែរជាង20នាក់លើទូកនេសាទ

https://www.facebook.com/matemohachunnews/ សារព័ត៌មានមតិមហាជន 04-07-2018

បន្ទាយមានជ័យ៖ ប្រាប់អ្នកយកព័ត៌មាននៅឯមជ្ឈមណ្ឌលសំចតនៃក្រសួងសង្គមកិច្ចអតីតយុវជន និង យុវនិតិសម្បហៅកាត់ថា(កសយក) នៅក្រុងប៉ោយប៉ែតខណៈពេលដែលភាគីថៃធ្វើមាតុភូមិនិវត្តន៍ក្មេងស្រី3នាក់តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតនៅព្រឹកថ្ងៃទី4 កក្កដា 2018 ប្រធានមជ្ឈមណ្ឌលសំចតប្រាប់ថាមានពលករខ្មែររងគ្រោះលើទូកនេសាទ 26នាក់ ដែលគេលក់កម្លាំងពលកម្មនៅខេត្តរ៉ាក់យ៉ង ត្រូវបានសមត្ថកិច្ចថៃជួយសង្គ្រោះហើយអាចនិងបញ្ជូនត្រឡប់វិញតាមរយៈក្រសួងសង្គមកិច្ចខ្មែរថៃ នាពេលខាងមុខឆាប់ៗនេះ។ លោកស្រី ឈា ម៉ានិត ប្រធានមជ្ឈមណ្ឌលសំចតបន្តថា ជនរងគ្រោះកម្ពុជាដែលត្រូវបានភាគីថៃធ្វើមាតុភូមិត្រឡប់តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត6ខែ ដើមឆ្នាំ2018 មានចំនួន3លើក ស្មើនិង15នាក់។ ដោយឡែកកាលពីឆ្នាំ2017 មានចំនួន48នាក់ ហើយថាជនរងគ្រោះភាគច្រើនគេយកទៅឲ្យសុំទាន និងលក់ផ្កាលើទឹកដីថៃ ហើយត្រូវភាគីថៃជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ។ ដោយមានការយកចិត្តទុកដាក់ពីក្រសួងសង្គមកិច្ច ពិសេសរាជរដ្ឋាភិបាលជនរងគ្រោះទាំងនោះត្រូវបានអង្គការដៃគូរនៅក្នុងខេត្ត និងរាជធានីភ្នំពេញទទួលយកទៅស្នាក់នៅ និងរៀនជំនាញផ្សេងៗ ដើម្បីមានអនាគតល្អទៀតផង៕ ដោយសារុនកញ្ញា

## ត្រឹម3ថ្ងៃអាជ្ញាធរថៃបង្ក្រាបពលករធ្វើការខុសច្បាប់ប្រមាណ100នាក់និងថៅកែ20នាក់

http://www.khmerlabour.com/ ប្រភព Khmerlabour 03-07-2018

ត្រឹមរយៈពេល3ថ្ងៃអាជ្ញាធរថៃបង្ក្រាបពលករធ្វើការខុសច្បាប់ប្រមាណ100នាក់ និងថៅកែ20នាក់។ យោងតាមរបាយការណ៍របស់ក្រសួងការងារថៃ កាលពីថ្ងៃទី04 ខែកក្កដា ឆ្នាំ2018នេះ បានអោយដឹងថា ចាប់តាំងពីថ្ងៃទី01ដល់ថ្ងៃទី03 កក្កដា បន្ទាប់ពីបិទមជ្ឈមណ្ឌលផ្តល់សេវាកម្មOSS កន្លងផុតទៅបីថ្ងៃ កម្លាំងអាជ្ញាធរក្រសួងការងារថៃធ្វើការឃាត់ខ្លួនបានពលករបរទេសធ្វើការខុសច្បាប់ចំនួន100នាក់ ព្រមទាំងនិយោជក20នាក់។ តាមការបញ្ជាក់របស់សមត្ថកិច្ចពលករដែលត្រូវឃាត់ខ្លួនភាគច្រើនជាពលករភូមា។

## និយោជកដែលមានកម្មករ/ពលករចាប់ពី១នាក់ឡើងទៅ ត្រូវនាំកម្មករ/ពលករចុះឈ្មោះចូលធានាសន្តិសុខសង្គមក្នុងរយៈពេល៣០ថ្ងៃ

https://www.facebook.com/កម្មករឆ្លងដែន 04-07-2018

និយោជកដែលមានកម្មករ/ពលករចាប់ពី១នាក់ឡើងទៅ ត្រូវនាំកម្មករ/ពលករចុះឈ្មោះចូលធានាសន្តិសុខសង្គមក្នុងរយៈពេល៣០ថ្ងៃ។ ហើយកាត់ឈ្មោះចេញពីធានាសន្តិសុខសង្គមនៅពេលដែលកម្មករ/ពលករចេញពីការងារក្នុងរយៈពេល15ថ្ងៃនៃខែបន្ទាប់។ និយោជកមានចេតនាមិននាំកម្មករ/ពលករចុះឈ្មោះចូលធានាសន្តិសុខសង្គមតាមដែលច្បាប់បានកំណត់មានទោសជាប់ពន្ធនាគារមិនលើសពី៦ខែឬផាកពិន័យមិនលើស២០,០០០បាត។ និយោជកមិនបង់លុយចូលគណនីធានាសង្គមទាំងចំណែករបស់ខ្លួនឯងនិងចំណែករបស់កម្មករ/ពលករ ឬបង់មិន

គ្រប់តាមដែលច្បាប់បានកំណត់ និយោជកត្រូវបង់បន្ថែម២%/ខែនៃប្រាក់ដែលមិនបានបង់ឬនៃប្រាក់ដែលបង់មិនគ្រប់។ "ចែកគ្នាមើលបងប្អូនកុំអោយគេកុហកយើងបាន"

## ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៨

## នគរបាលនាយកដ្ឋានប្រឆាំងបទល្មើសជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ចុះបង្ក្រាបទីតាំងធ្វើសរសៃបែបខ្មែរបុរាណ « បាតដៃលាភសំណាង » ឃាត់ខ្លួនមនុស្សប្រុសស្រីចំនួន១០នាក់

http://nokorwatnews.com/ ថ្ងៃទី ៥ ខែកក្កដា ឆ្នាំ ២០១៨

ភ្នំពេញ៖ កម្លាំងនគរបាលនាយកដ្ឋានប្រឆាំងបទល្មើសជួញដូរមនុស្ស និងការពារអនិតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានដឹកនាំកម្លាំងជាច្រើននាក់ ចុះបង្ក្រាបទីតាំងហាងធ្វើសរសៃបែបខ្មែរបុរាណ « បាតដៃលាភសំណាង » ឃាត់ខ្លួនមនុស្សប្រុសស្រីចំនួន១០នាក់ ពាក់ព័ន្ធករណីបង្កាប់បម្រើសេវាផ្លូវភេទកាលពីវេលាម៉ោង៧យប់ថ្ងៃ៥ ខែកក្កដា ឆ្នាំ២០១៨ ស្ថិតនៅផ្ទះលេខ៥៦A តាមបណ្តោយផ្លូវ១៤៦ ក្នុងសង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ការបង្ក្រាបខាងលើនេះដែរមានការសម្របសម្រួលដោយលោក គល ប៊ុន ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញដឹកនាំដោយ លោកឧត្តមសេនីយ៍ទោ សំបូរ ម៉ាណ្ណារិទ្ធ អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនិតិជន រួមទាំងកម្លាំងមានសមត្ថកិច្ចមូលដ្ឋានបានឃាត់ខ្លួនមេការ២នាក់និង មនុស្សប្រុសស្រីពាក់ព័ន្ធករណីបង្កាប់បម្រើសេវាផ្លូវភេទ ។ ក្នុងនោះដែរ ជាលិទ្ធផល កម្លាំងសមត្ថកិច្ចធ្វើការឃាត់ខ្លួនម្ចាស់ទីតាំងខាងលើ ដកហូតបានស្រោមអនាម័យមួយចំនួនធំ ។ និងបានរំដោះជួយសង្គ្រោះដល់ក្មេងស្រី៤នាក់ ជាបន្តបន្ទាប់ផងដែរ ។

បច្ចុប្បន្នជនសង្ស័យជាម្ចាស់ទីតាំងខាងលើ រួមនិងជនរងគ្រោះ សរុបទាំងអស់៩នាក់ ត្រូវបានសមត្ថកិច្ចនាំខ្លួនមកកាន់នាយកដ្ឋានប្រឆាំងបទល្មើសជួញដូរមនុស្ស និងការពារអនិតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីកសាងសំណុំរឿងបញ្ជូនខ្លួនតុលាការចាត់ការតាមផ្លូវច្បាប់៕ សរស្មី

## ជនសង្ស័យម្នាក់ត្រូវចៅក្រមស៊ើបសួរសាលាដំបូងខេត្តត្បូងឃ្មុំ បានចេញដីកាបង្គាប់ឲ្យឃុំខ្លួនពាក់ព័ន្ធករណីជួញដូរមនុស្សទៅប្រទេសចិន

http://cambodiapolice.com/policekh/ 3:29 pm 5 កក្កដា 2018

**ត្បូងឃ្មុំ៖** លោក ហៃ ណៃហេង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តត្បូងឃ្មុំ បានចេញដីកាបង្គាប់ឲ្យឃុំជនសង្ស័យឈ្មោះ ម៉ូត សារ៉ែន ភេទស្រី អាយុ៦០ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីលំនៅបច្ចុប្បន្នភូមិប្រសិតថ្មី ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូឃ្មុំ ពីបទៈ ការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ប្រព្រឹត្តនៅភូមិត្របែក ឃុំទឹកជ្រៅ ស្រុកតំបែត ខេត្តត្បូងឃ្មុំ កាលពីខែមីនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពីជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ។

សូមបញ្ជាក់ថាៈកាលពីថ្ងៃអង្គារ៍ ០៦រោច ខែបឋមាសាឍ ឆ្នាំច សំរិទ្ធស័ក ព.ស ២៥៦២ ត្រូវនិងថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨ កម្លាំងជំនាញ នៃការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអតិនិជនដឹកនាំលោកស្រីស្នងការរងហៃ ឡាលីន សហការជាមួយប៉ុស្តិ៍នគរបាលរដ្ឋបាលក្រែក បានឃាត់ខ្លួនជនសង្ស័យឈ្មោះ មូត សារ៉ែន ភេទស្រី អាយុ៦០ឆ្នាំ មានទីលំនៅភូមិ ត្រសិតថ្មីឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ ពាក់ព័ន្ធករណីការនាំមនុស្សចេញ មិនស្របច្បាប់ដោយមានគោលដៅទៅប្រទេសចិន ៕

## តុលាការបង្គាប់ឲ្យនាំស្ត្រីខ្មែរ៣៣នាក់ពាក់ពន្ធ័ករណីស៊ីឈ្នួលពពោះជំនួសយកមកសួរនាំ

http://seatv24hours.com/ កក្កដា ០៦ ១០:០៧:៣៥ ព្រឹក២០១៨

ភ្នំពេញ ៖ ស្រ្តីខ្មែរចំនួន៣៣នាក់ ដែលពាក់ពន្ធ័រឿងស៊ីឈ្នួលពពោះជំនួស ត្រូវបានលោក កោ វណ្ណី ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ កោះហៅឲ្យចូលខ្លួនឆ្លើយបំភ្លឺ ដើម្បីបន្តនីតិវិធី នូវរឿងរ៉ាវដ៏កម្រមួយនេះសម្រាប់ ប្រទេស កម្ពុជា។ ស្ត្រីរងគ្រោះទាំង៣៣នាក់ ត្រូវបានដឹកទៅកាន់សាលាដំបូងរាជធានីភ្នំពេញ នារសៀលថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨នេះ តាមរយៈរថយន្តរបស់អង្គការមេត្រីអន្តរជាតិចំនួន៣គ្រឿង។

មានជនត្រូវចោទប្រុសស្រី៥នាក់ ក្នុងនោះ មានបុរសចិនម្នាក់ត្រូវបានលោក កោ វណ្ណី ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាសម្រេចឃុំខ្លួនកាលពីរសៀលថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨កន្លងទៅ ក្រោមការចោទប្រកាន់ពីបទ «ជួញដូរមនុស្សឆ្លងដែន និងបទអន្តរការីជាមួយស្ត្រីពពោះ» យោងតាមមាត្រា១៦ នៃច្បាប់ស្តីពី ការបង្ក្រាបការជួញដូរមនុស្ស និងការពារអនីតិជន និងយោងតាមមាត្រា៣៣២ នៃក្រមព្រហ្មទណ្ឌ។ ជនត្រូវចោទដែលត្រូវតុលាការសម្រេចឃុំខ្លួនចំនួន០៥នាក់៖

ទី១៖ ឈ្មោះ LIU QIANG ភេទប្រុស អាយុ៤៩ឆ្នាំ ជនជាតិចិន ជាមេការ

ទី២៖ ឈ្មោះ ស្វាយ ស៊ីណុច ហៅសី ភេទស្រី អាយុ៣៤ឆ្នាំ ជាមេការ

ទី៣៖ ឈ្មោះ នឿន ស្រីឡាង ភេទស្រី អាយុ២៧ឆ្នាំ ជាមេការ

ទី៤៖ ឈ្មោះ លឹម សុភាព ហៅស្តើង ភេទស្រី អាយុ១៩ឆ្នាំ ជាអ្នកបកប្រែ

ទី៥៖ ឈ្មោះ ថៃ ភាព ភេទស្រី អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ ជាមេការ។

ព្រះរាជអាជ្ញារង គុជ គីមឡុង បានចុះបង្ក្រាបទីតាំងជួលស្ត្រីខ្មែរពពោះជំនួសកាលពីយប់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ នៅចំណុចផ្ទះលេខ២អា និង៩អា ក្រុម៤ ភូមិ៤ សង្កាត់ច្បាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ នៅក្នុងប្រតិបត្តិការបង្ក្រាបនោះ សមត្ថកិច្ចបានឃាត់ខ្លួន បានជនត្រូវចោទទាំង៥នាក់ខាងលើ និងមនុស្សពាក់ព័ន្ធក្នុងរង្វង់ ប្រតិបត្តិការជិត៤០នាក់ និងដកហូតបានវត្ថុតាងមួយចំនួននិងឯកសារលិខិតឆ្លងដែន និងឯកសារពាក់ព័ន្ធផ្សេងៗមួយ ចំនួនធំ៕ ចាន់ ធឿន

## តុលាការចេញដីកាសម្រេចឃុំខ្លួនស្ត្រីខ្មែរ៣៣នាក់ ដែលពាក់ព័ន្ធសំណុំរឿងស៊ីឈ្នួលពពោះជំនួស យកកូនលក់ឲ្យជនបរទេស

http://www.freshnewsasia.com/ 2018-07-06

**(ភ្នំពេញ)៖** លោក កោ វណ្ណី អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ និងជាចៅក្រមស៊ើបសួរ នៅល្ងាច ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ បានសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួនស្ត្រីខ្មែរ៣៣នាក់ ជាបណ្តោះអាសន្ន ដាក់ពន្ធនាគារព្រៃស ពាក់ព័ន្ធសំណុំរឿងពពោះជំនួស យកកូនលក់ទៅបរទេស។ លោកចៅក្រម កោ វណ្ណី បានប្រាប់អ្នកសាព័ត៌មានប្រចាំសាលាដំបូងរាជធានីភ្នំពេញថា ស្ត្រីខ្មែរចំនួន៣៣នាក់ ត្រូវបានលោកសម្រេចឃុំខ្លួន ពីបទ «**ជួញដូរមនុស្សដោយឆ្លងដែន**» និងបទ «**អន្តរការរវាងអ្នកសុំកូន និងស្ត្រីពពោះ**» យោងតាមមាត្រា១៦នៃច្បាប់ ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការពារអនីតិជន និងយោងតាមមាត្រា៣៣២ នៃក្រមព្រហ្មទណ្ឌ។

លោកចៅក្រមបានបង្ហើបថា ស្ត្រីជនជាប់ចោទទាំង៣៣នាក់ ត្រូវបានសមត្ថកិច្ចបញ្ជូនទៅ ឃុំខ្លួនក្នុងមន្ទីរពេទ្យ ដើម្បីងាយស្រួលតាមដាន និងពិនិត្យសុខភាពពួកគេ។ ពាក់ព័ន្ធរឿងនេះដែរមន្ត្រីពន្ធនាគារព្រៃស បានឲ្យដឹងថា បច្ចុប្បន្នស្ត្រីទាំង៣៣នាក់ ស្ថិតនៅមន្ទីរពេទ្យ១៦៨ ក្នុងរាជធានីភ្នំពេញ។

គួរបញ្ជាក់ថា ស្ត្រីខ្មែរទាំង ៣៣នាក់ ត្រូវបានតុលាការបង្គាប់ឲ្យនាំខ្លួន ពីអង្គការមេត្រីអន្តរជាតិ ទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីសាកសួរ។

កាលពីរសៀលថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ កន្លងទៅលោក កោ វណ្ណី ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញធ្លាប់បានចេញដីកាសម្រេចឃុំខ្លួនជនត្រូវចោទប្រុសស្រី៥នាក់ ក្នុងនោះមានបុរសចិនម្នាក់ ពីបទ «ជួញដូរមនុស្សដោយឆ្លងដែន» និងបទ «អន្តរការីរវាងអ្នកសុំកូន និងស្ត្រីពពោះ» យោងតាមមាត្រា១៦នៃច្បាប់ ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការពារអនីតិជន និងយោងតាមមាត្រា ៣៣២ នៃក្រមព្រហ្មទណ្ឌ ដូចគ្នានេះដែរ។

**ជនត្រូវចោទ ដែលត្រូវតុលាការសម្រេចឃុំខ្លួនចំនួន ០៥នាក់៖**

**ទី១៖** ឈ្មោះ LIU QIANG ភេទប្រុស អាយុ ៤៩ឆ្នាំ ជនជាតិចិន ជាមេការ

**ទី២៖** ឈ្មោះ ស្វាយ ស៊ីណុច ហៅ សី ភេទស្រី អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ ជាមេការ

**ទី៣៖** ឈ្មោះ នឿន ស្រីឡាង ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិខ្មែរ ជាមេការ

**ទី៤៖** ឈ្មោះ លឹម សុភាព ហៅ ស្តើង ភេទស្រី អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ ជាអ្នកបកប្រែ

**ទី៥៖** ឈ្មោះ ថៃ ភាព ភេទស្រី អាយុ ៤៣ឆ្នាំ ជនជាតិខ្មែរ ជាមេការ។

គួររំលឹកថា កម្លាំងសមត្ថកិច្ចចំរុះ ដឹកនាំលោក លោកវរសេនីយ៍ឯក កែវ ធា ប្រធានការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងមានការសម្របសម្រួលដោយលោក ព្រះរាជអាជ្ញារង គុជ គឹមឡុង បានចុះបង្ក្រាបទីតាំង ជួលស្ត្រីខ្មែរពពោះជំនួស កាលពីយប់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ នៅចំណុចផ្ទះលេខ ២អា និង៩អា ក្រុម៤ ភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

**នៅក្នុងប្រតិបត្តិការបង្ក្រាបនោះ សមត្ថកិច្ចឃាត់ខ្លួនបាន ជនត្រូវចោទទាំង ៥នាក់ខាងលើ និងមនុស្សពាក់ព័ន្ធក្នុងរង្វង់ប្រតិបត្តិការជិត៤០នាក់ និងដកហូតបានវត្ថុតាងមួយចំនួន៖**

* រថយន្តម៉ាកស្តារិច ពណ៌ស ពាក់ស្លាកលេខ ព្រះសីហនុ 2A-6883 ចំនួន ០១គ្រឿង
* ម៉ូតូ ម៉ាកហុងដា Today ពណ៌ខ្មៅ ចំនួន០១គ្រឿង
* រថយន្តគ្រឿង ម៉ាក Lexus 470 ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ 2C-8863 ចំនួន០១គ្រឿង
* រួមនឹងឯកសារ លិខិតឆ្លងដែន និងឯកសារពាក់ព័ន្ធផ្សេងៗមួយចំនួនធំ៕

## ឯកអគ្គរាជទូតខ្មែរ នៅកូរ៉េ និងប្រធាន HRD-Korea ឯកភាពគ្នា បន្តលើកកម្ពស់ ស្ថានភាពការងារ របស់សហគមន៍ខ្មែរ

https://www.dap-news.com/kh/ សុក្រ, 06 កក្កដា ២០១៨ 11:14 ដោយ: ស៊ាន កុសល ID:112

ភ្នំពេញ ៖ នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨ ឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ លោក ឡុង ឌីម៉ង់ និងទីប្រឹក្សាការងារ បានជួបពិភាក្សាការងារ ជាមួយលោក KIM DONG MAN ប្រធានទីភ្នាក់ងារ អភិវឌ្ឍន៍ធនធានមនុស្ស នៃសាធារណរដ្ឋកូរ៉េ HRD-Korea ថ្មីដែលទើបទទួលមុខតំណែង ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការ អោយកាន់តែល្អប្រសើរ និងទទួលបានជោគជ័យ ជាពិសេសនៅក្នុង អណត្តិរបស់លោក។ ក្នុងនោះលោក ឡុង ឌីម៉ង់ បានស្នើរសុំដល់ HRD-Korea បន្តកិច្ចសហប្រតិបត្តិការគ្នា ដើម្បីលើកកំពស់ស្ថានភាពការងារ ក៏ដូចជាការរស់នៅរបស់បងប្អូនពលករខ្មែរ ឲ្យកាន់តែមាន លក្ខណៈប្រសើរឡើង។ ផ្តល់ការសម្របសម្រួល ដល់អង្គាធរកូរ៉េពាក់ព័ន្ធ ក្នុងការផ្តល់ឱកាស ពិនិត្យលើកទី២ ដល់ពលករខ្មែរ ដែលបានធ្វើតេស្តឃើញ សារធាតុហាមឃាត់។ និងបង្កើតមជ្ឈមណ្ឌលគាំពារ ពលករបរទេសនៅតាមតំបន់តូចៗ ដើម្បីឆ្លើយតបទៅនឹងតម្រូវ ការសេវារបស់ពលករខ្មែរ និងពលករបរទេស។

ជាលទ្ធផលប្រធានទីភ្នាក់ងារអភិវឌ្ឍន៍ធនធានមនុស្ស HRD ដែលជាស្ថាប័នគ្រប់គ្រងពលករបរទេសនៅកូរ៉េ និងឯកអគ្គរាជទូត បានឯកភាពគ្នាក្នុងការបន្តកិច្ច សហប្រតិបត្តិការ គ្នាដើម្បី លើកកំពស់ស្ថានភាពការងារ ក៏ដូចជាការរស់នៅរបស់បងប្អូនពលករខ្មែរ ឲ្យកាន់ តែមាន លក្ខណៈប្រសើរឡើង ហើយនិងដោះស្រាយបញ្ហាលំបាកមួយចំនួនដែលបងប្អូនជួបប្រទះ ហើយនឹងទទួលយកសំណើររបស់ឯកឧត្តមឯកអគ្គរាជទូត ដើម្បីពិនិត្យ និងចាត់ការបន្ត។

ករណីពេលដែលពិនិត្យសុខភាពពលករឃើញមានសារជាតុហាមឃាត់ ស្ថានទូតបានស្នើសុំឲ្យមានផ្តល់ឱកាសពិនិត្យលើកទី២ ជាមួយនឹងការយកថ្នាំ ដែលបងប្អូនលេបមុនចេញ ដំណើរមកធ្វើកោសល្យវិច្ច័យនៅមន្ទីរពេទ្យ។ ស្ថានទូតនឹងជម្រាបជូនបង ប្អូនប្រជាពលរដ្ឋ ពីការសម្រេចរបស់អជ្ញាធរអន្តោប្រវេសន៍កូរ៉េពេលទទួលបានលទ្ធផល ហើយក៏សូមឆ្លៀត ឱកាសនេះអំពាវនាវសូមឲ្យបងប្អូន ដែលត្រៀមចេញមកកូរ៉េក្រោយប្រលងជាប់ហើយ មេត្តាកុំប្រើប្រាស់ថ្នាំផ្តេសផ្តាស់ដែលមិនមានវេជ្ជបញ្ជាត្រឹមត្រូវ ព្រោះការផ្សំថ្នាំផ្តាសាយ ខ្លះវានឹងអាចមានសារជាតិខ្លះ ដែលនៅកូរ៉េគេហាមឃាត់៕

## មានសេរីភាពវិញហើយ សូមកុំយកខាសនាខ្លួនទៅធ្វើរឿងបែបហ្នឹងទៀត

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៨ ម៉ោង ១៤:៤៤ ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ ក្រុមអាជ្ញាធរថៃបានដោះលេងអ្នកទោសខ្មែរ៣នាក់ឱ្យមានសេរីភាពវិញនាំខ្លួនយកមកប្រគល់ឱ្យអាជ្ញាធរកម្ពុជាតាមមាត់ច្រកទ្វារអន្តរជាតិជាំ ស្ថិតក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីវេលាម៉ោង២រសៀល ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ ។ អ្នកទោសខ្មែរដែលជាប់ក្នុងពន្ធធនាគាក្នុងប្រទេសថៃនោះមានទី១-ឈ្មោះ ស៊ីវ ឡូច ភេទប្រុស អាយុ៥៩ឆ្នាំ, ទី២-ឈ្មោះ ង៉ែត ធិ ភេទប្រុស អាយុ៤០ឆ្នាំ និងទី៣-ឈ្មោះ ពោន ខេន ភេទប្រុស អាយុ៤៥ឆ្នាំ ទាំង៣នាក់នេះមានទីលំនៅក្នុងឃុំច្រេស ស្រុកជុំគីរី ខេត្តកំពត ត្រូវបានទាហានថៃចាប់ខ្លួនថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ចូលតាមច្រកអូរខ្សាច់ក្រុមអាជ្ញាធរថៃចោទពីបទកាប់ឈើក្រញូងខុសច្បាប់ ត្រូវជាប់គុកនៅស្រុកខាន់តាឡាក់ ខេត្តស៊ីសាកេត ប្រទេសថៃ ។ មន្ត្រីដែលបម្រើការងារនៅមាត់ច្រកទ្វារអន្តរជាតិជាំបានឱ្យដឹងថា ក្រោយពីបានទទួលអ្នកទោសខ្មែរពីក្រុមអាជ្ញាធរថៃរួចមក សមត្ថកិច្ចបានធ្វើការអប់រំ និងធ្វើកិច្ចសន្យាមិនឱ្យឆ្លងដែនខុសច្បាប់បន្តទៀតរួចឱ្យវិលត្រឡប់ទៅលំនៅឋានវិញនៅក្នុងថ្ងៃដដែល ៕

## ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៨

## ក្រសួងការបរទេស អន្តរាគមន៍ជួយពលរដ្ឋខ្មែរ១៦នាក់ឲ្យត្រឡប់មកស្រុកកំណើតវិញ ក្រោយចាញ់បោកមេខ្យល់ទៅរៀបការជាមួយបុរសចិន និងមិនទ្រាំទ្រជាមួយការងារបាន

http://www.freshnewsasia.com/ 2018-07-09

**(ភ្នំពេញ)៖** ពលរដ្ឋខ្មែរ ១៦នាក់ទៀតហើយ ត្រូវបានក្រសួងការបរទេសអន្តរាគមន៍ជួយឲ្យបានត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីពួកគេបានចាញ់បោកមេខ្យល់នាំទៅរៀបការជាមួយបរទេសចិន និងខ្លះទៀតមិនទ្រាំទ្រជាមួយការងារបាន។ នេះបើតាមការបញ្ជាក់របស់លោក ជុំ សុន្ទរី អ្នកនាំពាក្យក្រសួងបរទេស និងសហប្រតិបត្តិការអន្តរជាតិនាព្រឹកថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨នេះ។ លោក ជុំ សុន្ទរី បានបញ្ជាក់ថា ពលរដ្ឋដែលជួយអន្តរាគមន៍ឲ្យបានត្រឡប់មកស្រុកកំណើតវិញនេះរួមមាន៖

១. ស្ត្រីខ្មែរចំនួន ៧នាក់ មកពីខេត្តកំពង់ចាម កំពង់ឆ្នាំង ក្រចេះ តាកែវ បាត់ដំបង និងរាជធានីភ្នំពេញ ដែលត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅរៀបការដោយខុសច្បាប់នៅក្នុងប្រទេសចិន។ ស្ថានទូតខ្មែរនៅប្រទេស

ចិន បានជួយអន្តរាគមន៍ ផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគ ព្រមទាំងរៀបចំឯកសារធ្វើដំណើរដល់ស្ត្រីរងគ្រោះទាំង៧នាក់ ឲ្យត្រឡប់មកស្រុកកំណើតវិញ។ ស្ត្រីខ្មែរទាំង៧នាក់ បានមកដល់កម្ពុជាវិញនៅថ្ងៃទី០៤ និងទី០៥ ខែកក្កដា ឆ្នាំ២០១៨។

**២.** ស្ត្រីខ្មែរចំនួន ៤នាក់ ដែលត្រូវបានមេខ្យល់បោកបញ្ឆោតបម្រុងយកទៅរៀបការជាមួយបុរសជនជាតិចិន នៅប្រទេសចិន។ ស្ត្រីរងគ្រោះទាំងនោះ មកពីខេត្តកណ្តាល កំពង់ចាម និងត្បូងឃ្មុំ ត្រូវបានមេខ្យល់នាំធ្វើដំណើរពីកម្ពុជាទៅដល់វៀតណាម នៅចុងខែមិថុនា ហើយបម្រុងបន្តដំណើរឆ្លងកាត់ព្រំដែនទៅប្រទេសចិន តែត្រូវបានអាជ្ញាធរមានសមត្ថកិច្ចវៀតណាមជួយសង្គ្រោះទាន់ពេល។ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅនិងអាហារបរិភោគដល់ស្ត្រីទាំង៤នាក់ ហើយបានរៀបចំមាតុភូមិនិវត្តន៍មកកម្ពុជាវិញ នៅថ្ងៃទី០៤ និងថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ២០១៨ ។

**៣.** ស្ត្រីជាអនីតិជនខ្មែរចំនួន៣នាក់ មានអាយុពី១៣ឆ្នាំ ដល់១៦ឆ្នាំ មកពីខេត្តបន្ទាយមានជ័យ ដែលទទួលរងគ្រោះដោយការជួញដូរមនុស្ស តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត នៅថ្ងៃទី០៤ ខែ កក្កដា ឆ្នាំ២០១៨។

**៤.** ស្ត្រីបម្រើការជាមេផ្ទះខ្មែរ១នាក់ ដែលពុំអាចទ្រាំទ្រការងារនៅអារ៉ាប៊ីសាអូឌីត ត្រូវបានស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋអារ៉ាប់អេហ្ស៊ីប ជួយសម្របសម្រួលរៀបចំមាតុភូមិនិវត្តន៍ និងមកដល់កម្ពុជាវិញ នៅព្រឹកថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨។

**៥.** ស្ត្រីខ្មែរ ១នាក់ ដែលចាញ់បោកមេខ្យល់ និងត្រូវបានអាជ្ញាធរចិនឃាត់ខ្លួនពីបទរស់នៅខុសច្បាប់ ត្រូវបាស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងស៊ីអាន ប្រទេសចិន ជួយអន្តរាគមន៍ និងរៀបចំមាតុភូមិនិវត្តន៍។ ស្ត្រីរងគ្រោះបានមកដល់កម្ពុជាវិញ នៅថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០១៨៕

## ស្ត្រីស៊ីឈ្នួលពពោះ ៣២ នាក់ត្រូវបានឃុំខ្លួននៅមន្ទីរពេទ្យ

https://www.postkhmer.com/ ម៉ិច ដារ៉ា | Publication date 09 July 2018 | 09:52 ICT

**ភ្នំពេញៈ** ស្ត្រីចំនួន ៣២ នាក់ដែលត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនពាក់ព័ន្ធនឹងរឿងស៊ីឈ្នួលពពោះជំនួសនៅពេលនេះកំពុងត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅក្នុងមន្ទីរពេទ្យនគរបាល ១៦ ឧសភា ដើម្បីងាយស្រួលតាមដាន និងពិនិត្យសុខភាពពួកគេ ខណៈស្ត្រីទាំងនោះកំពុងតែមានផ្ទៃពោះ។

បើតាមអ្នកនាំពាក្យអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃលោក សន កែវ បានឲ្យដឹងកាលពីម្សិលមិញថា ស្ត្រីខ្មែរ ៣២ នាក់ដែលត្រូវបានចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីចោទប្រកាន់ពីបទជួញដូរមនុស្សដោយឆ្លងដែន និងអន្តរការរវាងអ្នកសុំកូន និងស្ត្រីពពោះកំពុងត្រូវបានឃុំខ្លួនក្នុងមន្ទីរពេទ្យ ដើម្បីងាយស្រួលតាមដាន។ លោកបញ្ជាក់ថា៖ «ស្ត្រី ៣២ នាក់គឺយើងយកគាត់ទៅដាក់នៅមន្ទីរពេទ្យនគរបាល ១៦ ឧសភា។ ចំពោះករណីនេះផែនការបន្តទៅមុខទៀត ខ្ញុំមិនទាន់ដឹងទេ ដោយសារខ្ញុំមិនទាន់បានទទួល (បទបញ្ជា) នៅឡើយ»។

លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានថ្លែងថា ការឃុំខ្លួនស្ត្រីទាំងនោះជាការសម្រេចរបស់តុលាការ ហើយថាស្ត្រីដែលអាជ្ញាធរចាប់ឃាត់ខ្លួនទាំងនោះគឺដោយសារតែពួកគាត់មានបំណងលក់កូនរបស់ខ្លួនដើម្បីប្រាក់។ លោកស្រីបញ្ជាក់ថា៖ «អ្វីដែលយើងគិតជាបឋមជនរងគ្រោះគឺជាទារកនៅក្នុងផ្ទៃ។ យើងបង្កើតគាត់មក បន្ទាប់មកយើងយកគាត់ទៅលក់ ដូច្នេះវាអមនុស្សធម៌ខ្លាំងណាស់។ ផ្លូវច្បាប់មានន័យថាអ្នកដែលពពោះហ្នឹង គាត់ផ្តល់ទីកន្លែង និងលាក់ខ្លួនជនរងគ្រោះនៅក្នុងពោះគាត់។ ទីបំផុតគាត់នាំចេញយកទៅឲ្យគេហើយដោះដូរជាលុយ ដូច្នេះវាមិនអាចរួចផុតពីការចោទប្រកាន់ទេ»។ លោកស្រីបានបន្ថែមថា ស្ត្រីទាំងនេះបានប្រព្រឹត្តបទល្មើសគឺត្រូវតែទទួលទោសដូចមនុស្សដទៃទៀតដែរ ហើយបើតាមសាសនាវិញការពពោះកូនដើម្បីលក់បែបនេះជាអំពើបាប។ លោកស្រីបន្តថា ប្រសិនបើពួកគាត់មិនត្រូវបានផ្តន្ទាទោសទេនោះស្ត្រីដទៃទៀតអាចនឹងយកតម្រាប់តាមពួកគាត់។ ប៉ុន្តែទោះយ៉ាងណាលោកស្រី ប៊ុនអេង បញ្ជាក់ថា៖

«យើងត្រូវតែថែទាំគាត់ ដើម្បីឲ្យគាត់ថែទាំកូនបន្តទៀត។ ទោះយ៉ាងណាស្ត្រីដែលកំពុងពពោះ គាត់ត្រូវឆ្លងកាត់ការលំបាកផ្នែកសុខភាពច្រើន ដូច្នេះយើងត្រូវការការថែទាំគាត់។ ជាការទទួលខុសត្រូវរបស់រដ្ឋាភិបាល យើងមិនធ្វើដូចអ្នកទោសទូទៅទេ ដោយសារគាត់ជាស្ត្រីពពោះ ហើយយើងបាននិងកំពុងថែទាំពួកគាត់យ៉ាងល្អ»។

កាលពីល្ងាចថ្ងៃទី ៥ ខែកក្កដា ឆ្នាំ ២០១៨ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញលោក កោ វណ្ណី បានសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួនស្ត្រីខ្មែរ ៣២ នាក់ជាបណ្ដោះអាសន្នដាក់ពន្ធនាគារពាក់ព័ន្ធសំណុំរឿងពពោះជំនួស យកកូនលក់ទៅបរទេស។

លោក អ៊ី រិន ប្រធានផ្នែករដ្ឋបាលនៅសាលាដំបូងរាជធានីបានឲ្យដឹងថា លោកចៅក្រម កោ វណ្ណី បានសម្រេចឃុំខ្លួនស្ត្រីខ្មែរទាំងនេះពីបទ «ជួញដូរមនុស្សដោយឆ្លងដែន» និងបទ «អន្តរការរវាងអ្នកសុំកូន និងស្ត្រីពពោះ» យោងតាមមាត្រា ១៦ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការពារអនីតិជន និងយោងតាមមាត្រា ៣៣២ នៃក្រមព្រហ្មទណ្ឌ។

ពាក់ព័ន្ធនឹងសំណុំរឿងនេះកាលពីរសៀលថ្ងៃទី ២៩ ខែមិថុនាឆ្នាំ ២០១៨ លោក កោ វណ្ណី ក៏បានចេញដីកាសម្រេចឃុំខ្លួន បុរសចិនម្នាក់ឈ្មោះ LIU QIANG អាយុ ៤៩ ឆ្នាំ ជាមេការ និងស្ត្រីខ្មែរចំនួន ៤ នាក់ទៀតដែលជាមេការនិងជាអ្នកបកប្រែពីបទ «ជួញដូរមនុស្សដោយឆ្លងដែន» និងបទ «អន្តរការរវាង អ្នកសុំកូន និងស្ត្រីពពោះ» យោងតាមមាត្រា ១៦ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការពារអនីតិជន និងយោងតាមមាត្រា ៣៣២ នៃក្រមព្រហ្មទណ្ឌដូចគ្នានេះដែរ។ បើយោងតាមមាត្រា ១៦ នៃច្បាប់ស្តីអំពីការបង្ក្រាបការជួញដូរមនុស្ស ពួកគេទាំង ៥ នាក់អាចប្រឈមនឹងទោសជាប់ពន្ធនាគាររហូតដល់ ២០ ឆ្នាំប្រសិនបើតុលាការរកឃើញថាមានទោស។ ពួកគេទាំង ៥ នាក់នេះត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួននៅក្នុងប្រតិបត្តិការមួយកាលពីថ្ងៃទី ២១ ខែមិថុនានៅក្នុងផ្ទះមួយនៅខណ្ឌឫស្សីកែវ ពីបទបង្កើតភ្នាក់ងារស៊ីឈ្នួលពពោះជំនួសខុសច្បាប់ ហើយក្នុងពេលចុះបង្ក្រាបនោះសមត្ថកិច្ចក៏បានរកឃើញស្ត្រីចំនួន ៣២ នាក់ ខណៈពួកគេកំពុងស្ថិតនៅក្នុងដំណាក់កាលមានផ្ទៃពោះ។

លោកស្រី រស់ សុភាពនាយិកាអង្គការយេនឌ័រ និងការអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) មិនគាំទ្រចំពោះការចាប់ឃុំខ្លួនស្ត្រីដែលស៊ីឈ្នួលពពោះក្នុងពន្ធនាគារនោះឡើយដោយលោកស្រីថ្លែងថាស្ត្រីទាំងនោះក៏ជាជនរងគ្រោះដែរ។ «នៅពេលដែលយើងយកជនរងគ្រោះ (ស្ត្រីស៊ីឈ្នួលពពោះ) ទៅដាក់ពន្ធនាគារដោយសារគាត់ចរចាជាមួយអ្នកដែលផ្តល់សេវាហ្នឹង ហើយដោយសារគាត់ក្រីក្រមែនទែនគាត់គ្មានជម្រើស ហើយគាត់មិនដឹងថាការពពោះនេះប៉ះពាល់ជីវិត និងសុខភាពរបស់គាត់...គាត់ធ្វើដើម្បីជីវភាពរបស់គាត់»។ លោកស្រីបានបន្ថែមថាស្ត្រីទាំងនោះគ្មានបំណងលក់កូនទេ គឺដោយសារតែភាពក្រីក្រ ហើយពួកគាត់មិនបានដឹងថា ការស៊ីឈ្នួលពពោះជំនួសនេះគឺជាអំពើខុសច្បាប់នោះទេ ពីព្រោះកម្ពុជាមិនទាន់មានច្បាប់នេះ។ លោកស្រីចោទសួរថា៖ «តើកន្លែងណា (ច្បាប់ណា) ដែលចែងថាអំពើនេះ (ស៊ីឈ្នួលពពោះជំនួស) វាខុសច្បាប់...គាត់ដឹងតែយកលុយហើយសម្រាប់ពួកគាត់លុយ ១ ម៉ឺនដុល្លារច្រើនណាស់»៕

## ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨

## ស្ត្រីខ្មែរ១៦នាក់ដែលរងការជួញដូរទៅធ្វើការនិងរៀបការនៅបរទេសត្រូវបានជួយសង្គ្រោះ

https://khmer.voanews.com/ 09 កក្កដា 2018 នៅ វណ្ណារិន

ក្រសួងការបរទេសកម្ពុជាបានរាយការណ៍មកថា ស្ត្រីខ្មែរយ៉ាងហោចណាស់១៦នាក់ ដែលចាញ់បោកមេខ្យល់ទៅរៀបការនិងធ្វើការតាមផ្ទះដោយខុសច្បាប់នៅបរទេស ត្រូវបានជួយសង្គ្រោះនិងបញ្ជូនមកកាន់ស្រុកកំណើតវិញ។ ប្រទេសកម្ពុជានៅតែជាប្រភពនៃការជួញដូរមនុស្សទៅកាន់ប្រទេសផ្សេងៗ ដែលនេះជាការបារម្ភដ៏

ធ្ងន់ធ្ងរពីអ្នកធ្វើការប្រយុទ្ធប្រឆាំងនឹងការជួយជួរមនុស្សនៅមនុស្សនៅកម្ពុជា ជាពិសេសការជួញដូរទៅកាន់ប្រទេសចិន។

ភ្នំពេញៈ យ៉ាងហោចណាស់ ស្ត្រីខ្មែរ១៦នាក់ត្រូវបានជួយសង្គ្រោះពីប្រទេសមួយចំនួនរួមទាំងប្រទេសចិន និងថៃ ក្រោយចាញ់បោកមេខ្យល់នាំទៅឱ្យរៀបការនិងធ្វើការតាមផ្ទះនៅក្នុងប្រទេសទាំងនោះ។ ក្រសួងការបរទេសកម្ពុជា បានឱ្យដឹងនៅថ្ងៃចន្ទនេះថា ស្ត្រីខ្មែរទាំង១៦រូបត្រូវបានបញ្ជូនមកកាន់ប្រទេសកំណើតវិញកាលពីសប្តាហ៍កន្លងទៅ។ យ៉ាងណាក៏ដោយ សង្គមស៊ីវិលធ្វើការក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សបានអំពាវនាវឱ្យមានការរឹតបន្តឹងការអនុវត្តច្បាប់ ជាពិសេសចំពោះមេខ្យល់ដែលនាំស្ត្រីខ្មែរទៅកាន់ប្រទេសចិន ដែលកំពុងមានការកើនឡើង។ ក្នុងសេចក្តីប្រកាសព័ត៌មានរបស់ខ្លួនដែលចេញផ្សាយនៅថ្ងៃចន្ទ ក្រសួងការបរទេសកម្ពុជាបានឱ្យដឹងថា ស្ត្រីខ្មែរចំនួន១៦នាក់ត្រូវបានជួយសង្គ្រោះដោយស្ថានតំណាងកម្ពុជាក្នុងប្រទេសផ្សេងៗ ចាប់តាំងពីចុងខែមិថុនាកន្លងទៅ។ ក្នុងនោះមានស្ត្រីខ្មែរ៧នាក់ដែលចាញ់បោកមេខ្យល់នាំទៅរៀបការនៅប្រទេសចិនដោយខុសច្បាប់ ៤នាក់ផ្សេងទៀតត្រូវបានមេខ្យល់បម្រុងនាំទៅប្រទេសចិនឆ្លងកាត់ប្រទេសវៀតណាម កុមារីខ្មែរ៣នាក់ត្រូវបានជួយសង្គ្រោះពីប្រទេសថៃ ម្នាក់ត្រូវបានជួយសង្គ្រោះក្នុងប្រទេសអេស៊ីប និងមួយរូបផ្សេងទៀតត្រូវបានអាជ្ញាធរចិនឃាត់ខ្លួនពីបទរស់នៅខុសច្បាប់ក្នុងប្រទេសនោះ។

ក្នុងសេចក្តីប្រកាសព័ត៌មានដែលចេញដោយអ្នកនាំពាក្យនៃក្រសួងការបរទេសបានសរសេរក្នុងន័យដើមថា «ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសចិន បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ចិន ធ្វើអន្តរាគមន៍ជួយសង្គ្រោះនិងរៀបចំមាតុភូមិនិវត្តន៍របស់ស្ត្រីខ្មែរចំនួន៧នាក់ មកពីខេត្តកំពង់ចាម កំពង់ឆ្នាំង ក្រចេះ តាកែវ បាត់ដំបងនិងរាជធានីភ្នំពេញ ដែលត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅរៀបការដោយខុសច្បាប់នៅក្នុងប្រទេសចិន។ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅនិងអាហារបរិភោគព្រមទាំងរៀបចំឯកសារធ្វើដំណើរដល់ស្ត្រីរងគ្រោះទាំង៧នាក់ ហើយពួកគេបានមកដល់កម្ពុជាវិញ នៅថ្ងៃទី០៤ និងទី០៥ ខែ កក្កដា ឆ្នាំ២០១៨»។

VOA មិនអាចទំនាក់ទំនងមន្ត្រីនិងអ្នកនាំពាក្យនៃក្រសួងការបរទេសកម្ពុជាដើម្បីសុំក្តីអធិប្បាយបន្ថែមបានទេនៅថ្ងៃចន្ទនេះ។ VOA ក៏មិនអាចសុំការអធិប្បាយពីអ្នកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សបានដែរ ដោយសារអ្នកស្រីជាប់ប្រជុំ។

ប្រទេសកម្ពុជាត្រូវបានដាក់ក្នុងក្រុមប្រទេស ដែលការទប់ស្កាត់ការជួញដូរមនុស្សមិនមានភាពប្រសើរឡើងក្នុងរយៈពេលបីឆ្នាំជាប់ៗគ្នាចាប់តាំងពីឆ្នាំ២០១៦។ ក្នុងរបាយការណ៍ស្តីពីការជួញដូរឆ្នាំ២០១៨ ដែលចេញដោយក្រសួងការបរទេសអាមេរិកកាលពីចុងខែមិថុនាកន្លងទៅ កម្ពុជាត្រូវបានដាក់ក្នុងចំណាត់ថ្នាក់ទី២ ឬ (Tier 2) ដែលការអនុវត្តច្បាប់និងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅមានកម្រិត ជាពិសេសការកាត់ទោសជនល្មើស និងការផ្តល់សេវាដល់ជនរងគ្រោះពីការជួញដូរមិនទាន់ពេញលេញ។ របាយការណ៍ដដែលក៏បានបញ្ជាក់ផងដែរថា ក្នុងឆ្នាំ២០១៧មានជនរងគ្រោះកម្ពុជាចំនួន៩៨៦នាក់ ត្រូវបានក្រសួងការបរទេសកម្ពុជាជួយធ្វើមាតុភូមិនិវត្តន៍ ដែលភាគច្រើនមកពីប្រទេសម៉ាឡេស៊ី ថៃ វៀតណាមនិងចិន។ ចំនួននេះច្រើនជាងឆ្នាំ២០១៦ដែលមានតែ ៨១៥នាក់ប៉ុណ្ណោះ។ រីឯក្រសួងសង្គមកិច្ចបានជួយធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋកម្ពុជាចំនួន២៤៣នាក់ដែរក្នុងឆ្នាំ ២០១៧ដដែល។

អ្នកស្រី ធន សុគន្ធា ប្រធានផ្នែកស្ត្រី កុមារ និងប្រឆាំងការជួញដូរនៃអង្គការការពារសិទ្ធិមនុស្សអាដហុក (ADHOC) បានប្រាប់ VOA នៅថ្ងៃចន្ទនេះថា ការជួយជនរងគ្រោះពីការជួញដូរមិនត្រូវបញ្ចប់ត្រឹមការបញ្ជូនពួកគាត់មកកាន់ស្រុកកំណើតវិញនោះទេ ជាពិសេសជនរងគ្រោះពីការជួញដូរឬបោកបញ្ឆោតទៅរៀបការនៅប្រទេសចិនដែលភាគច្រើនបានរងគំនាបផ្លូវចិត្តនិងទារុណកម្មផងដែរ។ ជាបទពិសោធន៍ជនរងគ្រោះដែលអង្គការអាដហុក

បានសង្គ្រោះ ត្រូវបានបញ្ជូនឱ្យសិក្សាជំនាញផ្សេងៗនិងទទួលការលើកទឹកចិត្តមុនពួកគាត់អាចចូលទៅរស់នៅក្នុងសង្គមវិញ។ «យើងមិនមែនគ្រាន់តែថា ជួយគាត់មកហើយ បោះបង់គាត់ចោលទេ! យើងត្រូវតែធ្វើម៉េច ដើម្បីកាត់បន្ថយ ដើម្បីជៀសវាងកុំឱ្យគាត់មានគំនិតចង់ធ្វើចំណាកស្រុកឬចង់ទៅក្រៅសារជាថ្មីទៀត។ ប៉ុន្តែពាក់ព័ន្ធហ្នឹងរឿងករណីចិន ដែលខ្ញុំបានធ្វើកន្លងមកហ្នឹងដោយសារគាត់បទពិសោធន៍ឈឺចាប់ គឺអ្នកដែលទៅរៀបការជាមួយជនជាតិចិន ហើយត្រឡប់មកវិញហ្នឹងគឺ ភាគច្រើនគាត់មានបញ្ហាឈឺចាប់ទាំងផ្លូវកាយទាំងផ្លូវចិត្ត»។ អ្នកស្រី ធន សុគន្ធា បានឱ្យដឹងដែរថា ការជួញដូរមនុស្សទៅកាន់ប្រទេសចិនគឺជារឿងដែលគួរឱ្យបារម្ភហើយមានភាព «រញ៉េរញ៉ៃនិងសាំញ៉ាំច្រើន» ជាពិសេសមេខ្យល់មិនត្រូវបានផ្តន្ទាទោសឱ្យបានត្រឹមត្រូវនោះទេ។ ជាងនេះទៀត មេខ្លោងនៃការជួញដូរមនុស្សបានបញ្ចុះបញ្ចូលជនរងគ្រោះ ទៅរៀបការនៅប្រទេសចិន តាមរូបភាពផ្សេងៗ និងនាំជនរងគ្រោះឆ្លងកាត់ទៅប្រទេសវៀតណាមឬឡាវ ខណៈស្ថានទូតចិននៅកម្ពុជាធ្វើការរឹតបន្តឹងទិដ្ឋាការដល់ពួកគាត់។ «ខ្ញុំឃើញថាការអន្តរាគមន៍ រឿងករណីចិនហ្នឹងគឺវាមានរឿងរញ៉េរញ៉ៃ ហើយនិងរឿងសាំញ៉ាំច្រើន។ ខ្ញុំមើលឃើញបញ្ហាដោយវានៅតែកើតមានច្រើន ហើយមិនមានការថយចុះនោះទេ។ គឺទី១ដោយសារបញ្ហាមេខ្យល់ ហើយទី២គឺថាការផ្តន្ទាទោសអ្នកដែលប្រព្រឹត្តឬអ្នកដែលនាំកូនក្រមុំឬស្ត្រីខ្មែរយើងទៅរៀបការនៅប្រទេសចិនហ្នឹង»។

យ៉ាងណាក៏ដោយ អ្នកស្រី ធន សុគន្ធា នៃអង្គការការពារសិទ្ធិមនុស្សអាដហុក(ADHOC) បញ្ជាក់ថា ដើម្បីប្រឆាំងនឹងការជួញដូរឱ្យមានប្រសិទ្ធភាព រដ្ឋាភិបាលកម្ពុជាពង្រឹងការអនុវត្តច្បាប់ ដោយបំបាត់នូវវប្បធម៌និទណ្ឌភាព ការកាត់ទោសមេខ្យល់នៃការជួញដូរមនុស្សឱ្យបានគ្រប់ៗគ្នា រួមទាំងការជួយស្តារនីតិសម្បទាឱ្យជនរងគ្រោះពីការជួញដូរផងដែរ៕

## ថៃចាប់ពលករខ្មែរ ១ ពាន់នាក់បញ្ជូនមកកម្ពុជាវិញ ក្រោយបិទការផ្តល់ឯកសារការងារស្របច្បាប់

https://www.postkhmer.com/ ឃុត សុភចរិយា and សុទ្ធ គឹមសឿន date 10 July 2018 | 09:16 ICT

**ប៉ោយប៉ែត:** ក្នុងរយៈពេលត្រឹមជាងមួយអាទិត្យកម្លាំងតម្រួតអន្តោប្រវេសន៍ថៃចាប់ពលករខ្មែរប្រមាណជាង ១០០០ នាក់ដែលបានចូលស្នាក់នៅ និងបម្រើការងារដោយខុសច្បាប់បញ្ជូនត្រឡប់មកកម្ពុជាវិញតាមច្រកប៉ោយប៉ែត នៃខេត្តបន្ទាយមានជ័យ បន្ទាប់ពីរដ្ឋាភិបាលនៃប្រទេសថៃបានប្រកាសបិទការផ្តល់សុពលភាពនូវឯកសារការងារ និងធ្វើដំណើរស្របច្បាប់សម្រាប់ពលករបរទេសទាំងអស់កាលពីចុងខែមិថុនា។

លោកស្រី ស៊ិន ណាំយ៉ុង អនុប្រធានគណៈកម្មការសម្របសម្រួលទទួលពលករពីប្រទេសថៃប្រចាំច្រកប៉ោយប៉ែតបានប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃម្សិលមិញថា កាលពីថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៨ កន្លងទៅនេះប្រមុខរដ្ឋាភិបាលថៃបានប្រកាសបិទការផ្តល់សុពលភាពនូវឯកសារស្របច្បាប់នានាដល់ពលករចំណាកស្រុកបរទេសទាំងអស់ដែលរួមបញ្ចូលទាំងពលករចំណាកស្រុកកម្ពុជាផងដែរ។ លោកស្រី ណាំយ៉ុង បានថ្លែងថា ចាប់ថ្ងៃទី ១-៩ ខែកក្កដា ឆ្នាំ ២០១៨ កម្លាំងតម្រួតអន្តោប្រវេសន៍ថៃបានចាប់បញ្ជូនពលករខ្មែរចំណាកស្រុកខុសច្បាប់សរុបជាង ១០០០នាក់ ឲ្យត្រឡប់មកកម្ពុជាវិញ។ ប៉ុន្តែសកម្មភាពនៃការចាប់បញ្ជូននោះពុំមានសភាពខ្លាំងក្លាដូចកាលពីប៉ុន្មានឆ្នាំកន្លងទៅនោះទេ។ លោកស្រីបានថ្លែងថា៖ «ប៉ុន្តែនៅក្នុងឯកសារបញ្ជូនពលកររបស់ក្រុមតម្រួតអន្តោប្រវេសន៍ថៃនោះបានព្រមានថា នឹងចាត់វិធានការតឹងរ៉ឹងបំផុតតាមផ្លូវច្បាប់ប្រឆាំងនឹងពលករចំណាកស្រុកទាំងនោះប្រសិនបើពួកគេត្រូវបានចាប់ខ្លួនសាជាថ្មីក្នុងបទល្មើសដូចគ្នានេះ»។

យោងតាមរបាយការណ៍របស់ក្រសួងការងារ ពលករខ្មែរប្រមាណ ១ លាន ៧ ម៉ឺននាក់បានស្នាក់នៅ និងបំពេញការងារនៅក្នុងប្រទេសថៃបានទទួលឯកសារស្របច្បាប់នៅតាមបណ្តារោងចក្រ សហគ្រាស លើវិស័យ

សំណង់ នេសាទ និង កសិកម្មត្រូវបានគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ចុះបំពេញបេសកកម្មការងារផ្តល់ភាពស្របច្បាប់ជូនពួកគេដល់ប្រទេសថៃ។ ប៉ុន្តែទន្ទឹមជាមួយគ្នានេះមានពលករខ្មែរចំណាកស្រុកមួយចំនួនទៀតនៅតែបន្តចូលទៅធ្វើការងារខុសច្បាប់នៅក្នុងប្រទេសថៃ តាមរយៈមេខ្យល់ដែលបង្កឲ្យមានការព្រមានចាត់វិធានការតឹងរ៉ឹងតាមផ្លូវច្បាប់ពីភាគីថៃ។

លោក ប៉ាវ ស៊ីណា ប្រធានសម្ព័ន្ធសហជីពចលនាកម្មករថ្លែងថា៖ «យើងមានក្តីព្រួយកង្វល់ខ្លាំងណាស់ ជុំវិញការព្រមានរបស់ភាគីថៃទៅលើពលករចំណាកស្រុករបស់យើង»។ លោកបន្តថា៖ «អាជ្ញាធរពាក់ព័ន្ធរដ្ឋាភិបាលកម្ពុជា គួរតែបង្កើតឱកាសការងារឲ្យបានច្រើននៅតាមព្រំដែន ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋខ្មែរយើង»។

បញ្ហាពលករនេះកាលពីម្សិលមិញក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចេញរបាយការណ៍មួយបានឲ្យដឹងដែរថា រាជរដ្ឋាភិបាលបានសង្គ្រោះស្ត្រីខ្មែរចំនួន ១៦ នាក់ឲ្យបានវិលត្រឡប់មកកម្ពុជាវិញនៅក្នុងខែកក្កដានេះ បន្ទាប់ពីស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅក្រៅប្រទេសបានធ្វើអន្តរាគមន៍ដើម្បីសង្គ្រោះឲ្យផុតពីគ្រោះថ្នាក់ដោយសារមេខ្យល់បោកបញ្ឆោតនាំទៅរៀបការដោយខុសច្បាប់ជាមួយបរទេស ការជួញដូរមនុស្ស និងពុំអាចទ្រាំការងារបាន។ លោក ជុំ សុន្ទរី អ្នកនាំពាក្យក្រសួងការបរទេសបានថ្លែងឲ្យដឹងនៅក្នុងរបាយការណ៍ដដែលនេះថា ស្ត្រីទាំង ១៦ នាក់នោះត្រូវបានសង្គ្រោះពីប្រទេសចិនថៃវៀតណាម អារ៉ាប៊ីសាអ៊ូឌីត។ ក្នុងនោះស្ថានទូតបានរៀបចំកន្លែងស្នាក់នៅ អាហារបរិភោគ ព្រមទាំងរៀបចំឯកសារធ្វើដំណើរ។ របាយការណ៍នេះបានឲ្យដឹងថា ស្ត្រីទាំងនោះមានស្រុកកំណើតនៅក្នុងខេត្ត តាកែវ ក្រចេះ កំពង់ឆ្នាំង កំពង់ចាម បាត់ដំបង រាជធានីភ្នំពេញ ត្បូងឃ្មុំ កណ្តាល បន្ទាយមានជ័យ។ ក្នុងនោះស្ត្រីខ្មែរចំនួន ១១ នាក់ត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅរៀបការខុសច្បាប់នៅប្រទេសចិន ស្ត្រីម្នាក់ចាញ់បោកមេខ្យល់ និងត្រូវអាជ្ញាធរចិនឃាត់ខ្លួនពីបទរស់នៅខុសច្បាប់។ ស្ត្រីជាអនីតិជនខ្មែរចំនួន ៣ នាក់មានអាយុពី ១៣ ឆ្នាំ ដល់ ១៦ ឆ្នាំទទួលរងគ្រោះដោយការជួញដូរមនុស្សតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត។ ចំណែកស្ត្រីបម្រើការជាមេផ្ទះខ្មែរម្នាក់ គឺពុំអាចទ្រាំទ្រការងារនៅអារ៉ាប៊ីសាអ៊ូឌីត។ កាលពីថ្ងៃទី ២ ខែកក្កដា ឆ្នាំ ២០១៨ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានឲ្យដឹងថា ពលរដ្ឋខ្មែរចំនួន ១៤ នាក់ផ្សេងទៀតត្រូវបានស្ថានទូតកម្ពុជាប្រចាំនៅប្រទេសម៉ាឡេស៊ី និងចិនបានជួយសង្គ្រោះឲ្យត្រឡប់មកកម្ពុជាវិញដែរ។

របាយការណ៍របស់ក្រសួងការបរទេសក៏បានឲ្យដឹងដែរថានៅឆ្នាំ ២០១៧ កន្លងទៅនេះអាជ្ញាធរបានជួយសង្គ្រោះពលរដ្ឋខ្មែរនៅក្រៅប្រទេសជិត ១ ពាន់នាក់មកពីបណ្តាប្រទេសចំនួន ៩ ឲ្យវិលត្រឡប់មកកម្ពុជាវិញ បន្ទាប់ពីពួកគេជួបការរំលោភសិទ្ធិ និងការលំបាកនៅកន្លែងធ្វើការ។ ពលរដ្ឋខ្មែរភាគច្រើន ត្រូវបានជួយសង្គ្រោះពីប្រទេសម៉ាឡេស៊ីមានចំនួនដល់ទៅ ៣៨២ នាក់ និងថៃ ១៧១ នាក់ព្រមទាំងបណ្តាប្រទេសនានានៅក្នុងតំបន់។

លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) កាលពីដើមខែកក្កដាបានអះអាងថា រដ្ឋាភិបាលនៅតែគ្មានវិធានការទប់ស្កាត់ចំពោះបញ្ហាដែលត្រូវបានមេខ្យល់បោកបញ្ឆោតចេញពីកម្ពុជា។ លោក តុលា ថ្លែងថា៖ «ការចាញ់បោកគេនេះគឺចេះតែចាញ់បោកបន្តបន្ទាប់គ្មានវិធានការទប់ស្កាត់ ហើយចំណែកការដាក់ទោសទណ្ឌទៅលើមេខ្យល់ក៏មិនសូវឃើញជាដុំកំភួនអ្វីដែរ។ គឺបានន័យថា ដាក់ទោសតែអ្នកដែលតូចតាច ហើយអ្នកដែលជាមេខ្យល់ធំៗមានអំណាចដូចជាមិនឃើញមានទោសទេ»។

យោងតាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្ហាញនៅក្នុងសន្និបាតបូកសរុបការងារកាលពីថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៨ កន្លងមកនេះបានឲ្យដឹងថា រាជរដ្ឋាភិបាលបានផ្តល់សេវាជួយស្វែងរកការងារធ្វើនៅក្រៅប្រទេសជូនប្រជាពលរដ្ឋបានជាង ១ លាន ២ សែននាក់នៅប្រទេសថៃ ប្រទេសកូរ៉េ

ប្រទេសជប៉ុន ប្រទេសម៉ាឡេស៊ី ប្រទេសសិង្ហបុរី និងតំបន់រដ្ឋបាលពិសេសហុងកុង ដោយមិនគិតពីពលរដ្ឋដែលទទួលសេវាខុសច្បាប់៕

## តុលាការ ឃុំខ្លួនថៅកែ ហាងម៉ាស្សា បង្កប់សេវាផ្លូវភេទ

http://www.freshnewsasia.com/ 2018-07-10

**(ភ្នំពេញ)៖** នៅរសៀល ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ លោក សេង រិទ្ធី ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួន ប្តី និងប្រពន្ធ ជាថៅកែហាងម៉ាស្សា បង្កប់សេវាផ្លូវភេទប្រចាំខណ្ឌទួលគោក ជាបណ្តោះអាសន្ននៅពន្ធនាគារ។

ការសម្រេចឃុំខ្លួននេះ ធ្វើឡើងបន្ទាប់ពី លោក សេង ហៀង ជាតំណាងអយ្យការ បានបើកការស៊ើបសួរ និងចោទប្រកាន់ លើឈ្មោះ លី វិសុទ្ធ ហៅម៉ាប់ ភេទប្រុស អាយុ ៤៣ឆ្នាំ ជនជាតិខ្មែរ ជាប្តី និងឈ្មោះ ជា សុធារី ភេទប្រុស អាយុ ៤៥ឆ្នាំ ជនជាតិខ្មែរ ជាប្រពន្ធ ពីបទសញ្ញារកម្មមានស្ថានទម្ងន់ទោស ប្រព្រឹត្តកាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ នៅចំណុចផ្ទះលេខ ៥៦A ផ្លូវ១៤៦ សង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ យោងតាមមាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

គួររំលឹកថា កម្លាំងនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ បានចុះបង្ក្រាបហាងធ្វើសសៃបែបខ្មែរបុរាណឃីហោ «**បាតដៃសំណាង**» កាលពីយប់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ នៅចំណុចផ្ទះលេខ៥៦A ផ្លូវ១៤៦ សង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ នៅក្នុងប្រតិបត្តិការនោះ សមត្ថកិច្ច បានឃាត់ខ្លួនជនត្រូវចោទទាំង ២នាក់ប្តីប្រពន្ធ ជួយសង្គ្រោះ បានស្ត្រីរងគ្រោះចំនួន ០៩នាក់៕

## ពលករខ្មែរធ្វើសំណង់នៅថៃប្រឈមគ្រោះថ្នាក់ខ្លាំង

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៨ ម៉ោង ១៦:២៧ ចន ណារិទ្ធ

រាជធានីភ្នំពេញ៖ ប្រជាពលរដ្ឋខ្មែរទៅធ្វើការជាកម្មករសំណង់នៅប្រទេសថៃបានអះអាងថា ក្រុមកម្មករទៅធ្វើការផ្នែកសំណង់នៅប្រទេសថៃ គឺប្រឈមជាមួយបញ្ហាគ្រោះថ្នាក់ខ្លាំងបំផុត ដោយសាតែមេការ ឬអ្នកម៉ៅការសំណង់នោះតម្រូវឲ្យធ្វើការងារណាដែលលំបាកៗ និងប្រថុយប្រថានជាមួយគ្រោះថ្នាក់ ។

កាលពីប៉ុន្មានសប្តាហ៍មុននេះនៅទីក្រុងបាងកកប្រទេសថៃ ភ្នាក់ងារសារព័ត៌មានកោះសន្តិភាពបានជួបផ្ទាល់ជាមួយកម្មករសំណង់មួយក្រុមដែលជាជនជាតិខ្មែរ ក្នុងពេលសម្រាកពីការងារសំណង់ កំពុងអង្គុយផ្ទាល់ដីហូបបាយជុំគ្នានៅក្បែរការដ្ឋានសំណង់មួយកន្លែងដែលកំពុងសាងសង់បានប្រមាណ៩០% របស់អគារព្រះរាមចិត្រ ឬក្បែរផ្សារទំនើបប៊ិចស៊ី ចំកណ្តាលទីក្រុងបាងកកតែម្តង ដោយមានទឹកមុខក្រៀមក្រំគួរឲ្យអាណិតអាសូរខ្លាំងណាស់ ។ នៅពេលភ្នាក់ងារកោះសន្តិភាពចូលទៅជួបក្នុងន័យសួរនាំសំណេះសំណាល និងសួរសុខទុក្ខធម្មតា ពួកគាត់បាននាំគ្នាផ្អាកហូបបាយ និងក្រោកឈររៀបរាប់ដោយមិនទាន់ទាំងសួរផងនោះ ។

កម្មករម្នាក់ឈ្មោះ ដារី បានឲ្យដឹងថា ពួកគាត់ពិតជាមានការលំបាកខ្លាំង ជាពិសេសក្នុងពេលការដ្ឋានសំណង់ណាដែលមានការលំបាក ដូចជា ពេលសំណង់បុកគ្រឹះ ឬការដ្ឋានហាលថ្ងៃ និងការងារឡើងខ្ពស់ៗ ឬប្រថុយជាមួយគ្រោះថ្នាក់ជាដើម គឺមេការឲ្យកម្មករខ្មែរធ្វើតែម្តង ដល់ពេលសាងសង់បានខ្ពស់ និងមានម្លប់ស្រួលហើយគេដេញកម្មករខ្មែរឲ្យទៅធ្វើសំណង់មួយទៀត ដើម្បីដាក់កម្មករថៃចូលជំនួសវិញ ដែលការងារបែបនេះ មានជាក់ស្តែងស្ទើរគ្រប់កន្លែងតែម្តង ។ ជាក់ស្តែងក្នុងពេលនេះ មេការសំណង់បានឲ្យពួកគាត់ជាកម្មករ ឡើងលាបថ្នាំជូតកញ្ចក់ និងសម្អាតជញ្ជាំងអគារផ្នែកខាងក្រៅដែលមានកំពស់ប្រមាណ២០ជាន់ ដោយគ្រាន់តែចងខ្សែរ៉ូតជាប់

ចង្កេះ គឺមិនមានកន្ត្រកយោងនោះទេ ទម្លាក់ខ្លួន ដើម្បីលាប ជូត និងសំអាតតាំងពីជាន់លើដល់ក្រោម ហើយនៅពេលធ្វើការងារណាដែលលំបាកៗរួច ត្រូវមេការថៃឲ្យទៅធ្វើសំណង់នៅទីតាំងមួយផ្សេងទៀត ។ ចំណែកកម្មករថៃពួកគេធ្វើការណាដែលស្រួលៗទេ ដូចជារៀបការ៉ូ បៀកឬបូកជញ្ជាំងផ្នែកខាងក្នុងអគារ ឬការងារក្នុងម្លប់តែប៉ុណ្ណោះ ។

ក្រុមកម្មករទាំងនោះបានរៀបរាប់ទាំងទឹកមុខក្រៀមក្រំទៀតថា ទោះការងារលំបាក និងប្រថុយប្រថានគ្រោះថ្នាក់បែបនេះក្តី ក៏ចេះតែស៊ូទ្រាំ មិនតែប៉ុណ្ណោះក្រុមហ៊ុនទទួលម៉ៅការសំណង់នោះ បើកប្រាក់ខែមិនទៀងទាត់ទៀតផង និងបើកឲ្យម្តងបន្តិចៗ ព្រោះខ្លាចកម្មកររត់នៅពេលដែលបើកលុយអស់ ។ កម្មករក្រុមនោះបានបញ្ជាក់ថាសម្រាប់ក្រុមរបស់គាត់ធ្វើការ បានប្រាក់ឈ្នួលក្នុងមួយថ្ងៃតែជាង២០០បាត បើជាកម្មករជំនាញ អាចទទួលបានពី៣០០ឬជាង៣០០បាត ចំណែកកម្មករជនជាតិថៃវិញ ទទួលបានពី៤០០ទៅ៥០០បាតក្នុងមួយថ្ងៃ និងធ្វើតែការងារណាដែលស្រួលៗទៀតផង ។ ក្រុមកម្មករដដែលបានឲ្យដឹងបន្តថា ពួកគេទៅធ្វើការនៅស្រុកថៃផ្នែកសំណង់នេះ ពិតជាមានការលំបាកខ្លាំង មានពេលខ្លះអត់លុយទៅស្រុកកំណើតដោយសារថៅកែមិនបើកប្រាក់ខែឲ្យ និងឲ្យធ្វើការថែមម៉ោងទៀត ភាគច្រើនកម្មករខ្ចីឬជំពាក់មេការដែលម៉ៅការសំណង់ គឺនៅពេលបើកប្រាក់ខែសងមេការវិញស្ទើរគ្មានសល់ ប៉ុន្តែក៏មានក្រុមហ៊ុនខ្លះបើកប្រាក់ខែទៀងទាត់ តែមានតិចណាស់ ។ កម្មករទាំងនោះបានរៀបរាប់ថាពួកគាត់បានចាញ់បោកមេខ្យល់ ដោយបានសន្យាថា ទៅធ្វើការសំណង់នៅប្រទេសថៃ បានប្រាក់ខែច្រើន គឺក្នុងមួយថ្ងៃ នឹងទទួលបានប្រាក់ពី៧០០ទៅ១ពាន់បាតឯណោះ ទើបពួកគាត់ បានសម្រេចចិត្តនាំគ្នាចាកចេញពីស្រុកកំណើតទៅធ្វើការនៅប្រទេសថៃក្នុងពេលនេះ ដឹងអីលំបាកយ៉ាងនេះ បើកម្មករក្រៅពីសំណង់គួរសមបន្តិច បើកម្មករធ្វើសំណង់ពិតជាពិបាកតែម្តង ៕

## ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨

### មន្ត្រីសិទ្ធិមនុស្សជំរុញឱ្យតុលាការស៊ើបអង្កេតឱ្យច្បាស់ករណីពពោះជំនួសរបស់ស្ត្រីខ្មែរ ៣៣នាក់

https://www.rfa.org/khmer/news/ ដោយ ជី វិតា 2018-07-09

មន្ត្រីសិទ្ធិមនុស្សជំរុញឱ្យតុលាការស៊ើបអង្កេតឱ្យបានច្បាស់លាស់ ជុំវិញសំណុំរឿងពពោះជំនួសរបស់ស្ត្រីខ្មែរចំនួន ៣៣នាក់ ដែលត្រូវបានតុលាការក្រុងភ្នំពេញសម្រេចចោទប្រកាន់ និងឃុំខ្លួនបណ្តោះអាសន្ននោះ។ មន្ត្រីសិទ្ធិមនុស្សយល់ឃើញថា ស្ត្រីទាំងនោះក៏អាចជាជនរងគ្រោះនៃអំពើជួញដូរមនុស្សដែរ ដូច្នេះការចោទប្រកាន់ ឬអាចឈានដល់ការដាក់ទោសទណ្ឌ គឺជារឿងប៉ះពាល់ដល់សិទ្ធិរបស់ពួកគាត់ធ្ងន់ធ្ងរ ខណៈកម្ពុជាមិនទាន់មានច្បាប់ស្តីពីសេវាពពោះជំនួសនៅឡើយ។

ប្រធានគ្រប់គ្រងការិយាល័យឃ្លាំមើលសិទ្ធិមនុស្សនៃអង្គការលីកាដូ (LICADHO) លោក អំ សំអាត ថ្លែងថាតុលាការគួរតែស៊ើបអង្កេតឱ្យបានច្បាស់លាស់ មុននឹងធ្វើការចោទប្រកាន់លើស្ត្រីខ្មែរមានផ្ទៃពោះចំនួន ៣៣នាក់ពាក់ព័ន្ធនឹងករណីពពោះជំនួស បើមិនដូច្នេះទេ ពួកគេអាចនឹងក្លាយជាជនរងគ្រោះ ក្នុងសំណុំរឿងព្រហ្មទណ្ឌមួយនេះ។ លោកបន្តថា តុលាការត្រូវតែរកឱ្យឃើញថា ស្ត្រីទាំងនោះ គឺជាអ្នកដែលបានទៅប្រមូលស្ត្រីដទៃទៀតឱ្យមកពពោះ ឬជាអ្នកដែលត្រូវបានគេបញ្ចុះបញ្ចូលឱ្យពពោះ ធ្វើបែបនេះទើបអាចកំណត់បានថា អ្នកណាជាជនល្មើសនិងអ្នកណាគឺជាជនរងគ្រោះពិតប្រាកដ៖ «បើយើងមើលទៅ គឺដោយសារតែភាពក្រីក្រ ខ្វះខាតជីវភាពទាំងអស់ហ្នឹងហើយ ទើបបានជាគាត់ស៊ីឈ្នួលពពោះ ដើម្បីទទួលកម្រៃទ្រទ្រង់ជីវភាពគ្រួសារជាដើម។ បើនិយាយឱ្យពិតទៅហាក់ដូចជាស្ត្រីទាំងអស់នេះ គឺជាអ្នករងគ្រោះដែរ ដូច្នេះអ្វីដែលសំខាន់គួរតែស្វែងរកឱ្យអស់នូវជនពាក់ព័ន្ធដែលកេងយកផលចំណេញ ពីស្ត្រីដែលពពោះជំនួសទាំងនេះ។ ខ្ញុំមើលថា ទង្វើបែបនេះ គឺវាហាក់ដូចជាការជួញដូរកុមារព្រោះពេលដែលក្មេងកើតមក គេនឹងអាចលក់ដូរក្មេងទាំងអស់ហ្នឹង ហើយមួយទៀតអាចអ្នកដែលមិនមានកូន គាត់ចង់បានការពពោះជំនួសដើម្បីបានកូនយកមកចិញ្ចឹម»។

កាលពីថ្ងៃទី៥ កក្កដា កន្លងទៅ ចៅក្រមស៊ើបសួរនៃតុលាការក្រុងភ្នំពេញបានចេញដីកាបង្គាប់ឱ្យឃុំខ្លួនស្ត្រីខ្មែរមានផ្ទៃពោះចំនួន ៣៣នាក់ ដាក់ពន្ធនាគារព្រៃសបណ្តោះអាសន្ន ពាក់ព័ន្ធនឹងករណីពពោះជំនួស ក៏ប៉ុន្តែមានតែ ៣២ នាក់ ប៉ុណ្ណោះ ដែលត្រូវស្ថិតក្នុងការឃាត់ខ្លួន ដោយស្ត្រីម្នាក់ទៀតអវត្តមានក្នុងកិច្ចពិភាក្សាដេញដោលចំពោះមុខចៅក្រមស៊ើបសួរ។ មន្ត្រីតុលាការបានប្រាប់សារព័ត៌មានក្នុងស្រុកថា ស្ត្រីទាំងនោះត្រូវបានសមត្ថកិច្ចបញ្ជូនទៅឃុំខ្លួនក្នុងមន្ទីរពេទ្យមួយកន្លែងក្នុងរាជធានីភ្នំពេញវិញ ដើម្បីងាយស្រួលតាមដានសុខភាពរបស់ពួកគេ។ ស្ត្រីទាំងនោះត្រូវបានចោទប្រកាន់ពីបទ "អំពើលក់-ដូរមនុស្សសម្រាប់នាំឆ្លងដែន" តាមមាត្រា ១៦ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលប្រឈមនឹងការជាប់ពន្ធនាគាររហូតដល់ ២០ឆ្នាំ ប្រសិនបើតុលាការសម្រេចថា ពួកគេពិតជាមានទោសមែននោះ។

ស្ត្រីមានផ្ទៃពោះទាំង ៣៣នាក់នោះ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនកាលពីយប់ថ្ងៃទី២១ មិថុនា កន្លងទៅ ក្នុងប្រតិបត្តិការបង្ក្រាបករណីស៊ីឈ្នួលពពោះជំនួសមួយកន្លែង នៅសង្កាត់ច្រាំងចម្រេះ ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។ សមត្ថកិច្ចក៏បានឃាត់ខ្លួនជនជាតិចិនម្នាក់ និងខ្មែរ ៤នាក់ ផងដែរ ដែលពួកគេគឺជាមេការ និងជាអ្នកបកប្រែនៃសេវាកម្មពពោះជំនួសនេះ។ ជនជាតិចិន និងខ្មែរ ទាំង ៥នាក់នោះ ត្រូវបានតុលាការចោទប្រកាន់ពីបទជួញដូរមនុស្សឆ្លងដែន និងអន្តរការីរវាងអ្នកសុំកូន និងស្ត្រីពពោះ ហើយកំពុងស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នក្នុងពន្ធនាគារព្រៃស។

មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់សមាគមអាដហុក (ADHOC) លោក សឹង សែនករុណា ថ្លែងថា បទចោទលើស្ត្រីមានផ្ទៃពោះទាំង ៣៣នាក់នោះ ជាបទចោទធ្ងន់ធ្ងរ ខណៈកម្ពុជាមិនទាន់មានច្បាប់ស្តីពីការពពោះជំនួសនៅឡើយ។ លោកយល់ថា ស្ត្រីខ្មែរទាំងនោះទំនងជាត្រូវបានបញ្ឆោះបញ្ឆូលឱ្យពពោះជំនួស ជាថ្នូរទទួលបានលុយកាក់ ហើយដោយសារជីវភាពក្រីក្រទើបពួកគាត់សម្រេចចិត្តស៊ីឈ្នួលពពោះជំនួសបែបនេះ។ លោកជឿជាក់ថា ស្ត្រីខ្មែរទាំងនោះប្រាកដជាមិនបានដឹងទេថា ការពពោះជំនួសនេះអាចប្រឈមនឹងបញ្ហាផ្លូវច្បាប់ធ្ងន់ធ្ងរបែបនេះនោះ៖ «ពេលដែលពួកគាត់ធ្វើតាមការបញ្ឆោះបញ្ឆូល ឬក៏ពួកបរទេសបញ្ឆោះបញ្ឆូលពួកគាត់ គាត់ក៏ធ្វើតាម ដោយគិតថាគ្មានទោស ប៉ុន្តែស្រាប់តែរឿងទាំងអស់នេះ ទៅជាមានការដាក់ទោសទណ្ឌពួកគាត់បែបនេះ។ វាធ្វើឱ្យមានការរំលោភសិទ្ធិរបស់ពួកគាត់ ហើយវាជារឿងមួយដែលគាត់រងនូវភាពអយុត្តិធម៌ផងដែរ»។

កាលពីអំឡុងឆ្នាំ២០១៦ កន្លងទៅ ស្ត្រីជនជាតិអូស្ត្រាលីម្នាក់ និងពលរដ្ឋខ្មែរ ២នាក់ ក៏ត្រូវបានសមត្ថកិច្ចចាប់ខ្លួនផងដែរពាក់ព័ន្ធនឹងសំណុំរឿងជួលស្ត្រីខ្មែរឱ្យពពោះជំនួសនេះ។ អ្នកទាំង ៣ ត្រូវបានតុលាការក្រុងភ្នំពេញសម្រេចផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ ១៨ ខែ ក្រោមបទចោទ "ធ្វើជាអន្តរការីរវាងអ្នកសុំកូន និងស្ត្រីពពោះ និងសុំឱ្យផ្តល់ឯកសារដោយទុច្ចរិត" កាលពីដើមខែសីហា ឆ្នាំ ២០១៧ កន្លងទៅ។ បន្ទាប់ពីផ្ទុះឡើងនូវករណីជួលស្ត្រីខ្មែរពពោះនេះ របបក្រុងភ្នំពេញក៏បានចាប់ផ្តើមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសេវាពពោះកូនជំនួស នៅដើមឆ្នាំ ២០១៨ ក៏ប៉ុន្តែកាលពីពេលថ្មីៗនេះ របបនេះបានប្រកាសពន្យារពេលដាក់សេចក្តីព្រាងច្បាប់នេះទៅគណៈរដ្ឋមន្ត្រីវិញ ដោយលើកហេតុផលថា ដើម្បីសិក្សាឱ្យកាន់តែលម្អិតថែមទៀត។

លោក អំ សំអាត សន្និដ្ឋានថា ការស៊ីឈ្នួលពពោះជំនួសនេះ អាចកើតមានច្រើនករណីនៅកម្ពុជា ខណៈប្រទេសមួយចំនួនបានចេញច្បាប់ហាមឃាត់សេវានេះរួចទៅហើយ ដូច្នេះរដ្ឋាភិបាលគួរតែពន្លឿនសេចក្តីព្រាងច្បាប់នេះ ដើម្បីយកទៅអនុវត្តឱ្យបានទាន់ពេលវេលា៖ «ខ្ញុំយល់ថាច្បាប់ប្រភេទនេះហើយ ជាច្បាប់ចាំបាច់ ដែលរដ្ឋាភិបាល ឬរដ្ឋសភាត្រូវតែគិតគូរ និងពិចារណាឱ្យបានឆាប់ ដើម្បីសង្គមជាតិ ដើម្បីការពារផលប្រយោជន៍ស្ត្រី និងកុមារ ឬក៏ការពារសិទ្ធិរបស់ពលរដ្ឋ។ នេះហើយជាការចាំបាច់ដែលយើងត្រូវការឆាប់នោះ»។

របាយការណ៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បង្ហាញថា បទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទក្នុងឆ្នាំ២០១៧ មានការកើនឡើង បើប្រៀបធៀបនឹងឆ្នាំ ២០១៦ កន្លងទៅ។ មូលហេតុសំខាន់ដោយសារឧក្រិដ្ឋជនមានល្បិចកលខ្ពស់ ការត្រួតពិនិត្យ និងគ្រប់គ្រងពលករចំណាកស្រុកមិនទាន់បានល្អ និងអសមត្ថភាពរបស់មន្ត្រីមួយចំនួនជាដើម។

ចំណែកក្រសួងការបរទេសអាមេរិកវិញ ក៏រកឃើញដែរថា របបលោក ហ៊ុន សែន នៅមិនទាន់អនុវត្តបានពេញលេញនូវបទដ្ឋានអប្បបរមាស្ដីពីការលុបបំបាត់ការជួញដូរមនុស្សនៅឡើយ ទោះបីជារបបនេះបានបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការផ្ដន្ទាទោសអ្នកជួញដូរមនុស្ស និងជួយសម្រួលក្នុងការបញ្ជូនជនរងគ្រោះឱ្យបានវិលត្រឡប់មកកម្ពុជាវិញច្រើនជាងមុនបែបណាក្ដី។ របាយការណ៍ស្ដីពីការជួញដូរមនុស្សឆ្នាំ ២០១៨ របស់ក្រសួងការបរទេសអាមេរិក ចេញផ្សាយកាលពីខែមុន បង្ហាញថា បញ្ហាសំខាន់ គឺការរីករាលដាលនៃអំពើពុករលួយ ដែលធ្វើឱ្យការពង្រឹងការអនុវត្តច្បាប់គ្មានប្រសិទ្ធភាព ប៉ះពាល់ដល់ដំណើរការនីតិវិធីតុលាការក្នុងការផន្ទាទោសជនល្មើស និងធ្វើឱ្យប៉ះពាល់ដល់ការផ្ដល់សេវាជូនជនរងគ្រោះផងដែរ។ ក្រៅពីនេះរបបលោក ហ៊ុន សែន ក៏មិនបានចេញគោលការណ៍ណែនាំជាផ្លូវការឱ្យប្រើប្រាស់បច្ចេកទេសស៊ើបការណ៍សម្ងាត់ ដើម្បីកម្ចាត់អំពើជួញដូរមនុស្សនេះដែរ ធ្វើឱ្យមន្ត្រីអនុវត្តច្បាប់មិនអាចចាប់ជនល្មើសមកផ្ដន្ទាទោសឱ្យបានច្រើនឡើយ។ លើសពីនេះទៅទៀត របបនេះបានមើលរំលង និងខ្វះការទទួលខុសត្រូវលើបញ្ហានេះ ទើបធ្វើឱ្យអ្នករកស៊ីទុច្ចរិតជាច្រើន បន្តកេងប្រវ័ញ្ចកម្លាំងពលកម្មពលរដ្ឋខ្មែរទូទាំងប្រទេស ធ្វើឱ្យពួកគេផុងខ្លួនកាន់តែជ្រៅទៅក្នុងបញ្ហាបំណុល គ្មានអ្នកជួយដោះស្រាយ។ ក្រសួងការបរទេសអាមេរិកស្នើឱ្យអាជ្ញាធរនៃរបបក្រុងភ្នំពេញ ស៊ើបអង្កេត និងផ្ដន្ទាទោសជនល្មើស និងមន្ត្រីណាដែលឃុបឃិតក្នុងអំពើជួញដូរមនុស្ស ជួញដូរផ្លូវភេទ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ឱ្យបានម៉ឺងម៉ាត់បំផុត៕

## សមត្ថកិច្ចថៃចាប់បញ្ជូនពលករខ្មែរធ្វើការខុសច្បាប់ត្រឡប់មកកម្ពុជាកាន់តែច្រើន

https://www.rfa.org/khmer/news/ ដោយ វ៉ែន សុមេធ 2018-07-10

អាជ្ញាធរថៃចាប់ផ្ដើមបញ្ជូនពលករខ្មែរដែលធ្វើការខុសច្បាប់តាមច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យជាបណ្ដើរៗហើយ ខណៈដែលពលករខ្លះកំពុងភ័យព្រួយខ្លាចត្រឡប់ទៅស្រុកកំណើតវិញ បណ្ដាលឲ្យគ្មានការងារធ្វើដោះស្រាយជីវភាពប្រចាំថ្ងៃ។ មន្ត្រីសង្គមស៊ីវិលនៅខេត្តបន្ទាយមានជ័យ លើកឡើងថា សមត្ថកិច្ចថៃចាប់បញ្ជូនពលករនៅពេលនេះ គឺមិនមែនជារឿងចម្លែកទេ ដោយសារតែនៅកម្ពុជាកំពុងតែដំណើរឃោសនារកសំឡេងឆ្នោត។

ពលករខ្មែរធ្វើការងារនៅប្រទេសថៃអះអាងថា បើទោះជាសព្វថ្ងៃសមត្ថកិច្ចថៃមិនទាន់អនុវត្តច្បាប់លើពលករដែលធ្វើការខុសច្បាប់ឲ្យខ្លាំងក្លាក៏ដោយ ក៏ពលករមួយចំនួនភ័យខ្លាច ហើយបាននាំគ្នាត្រឡប់ទៅកម្ពុជាវិញដោយខ្លួនឯងក៏មាន។ តំណាងពលករខ្មែរធ្វើការនៅប្រទេសថៃ លោក លី រតនរស្មី ឲ្យដឹងនៅថ្ងៃទី៩ កក្កដាថា ពលករធ្វើការខុសច្បាប់នៅទីក្រុងបាងកកជាច្រើននាក់ បានត្រឡប់ទៅខ្មែរយ៉ាងប្រញាប់ប្រញាល់ តាំងពីថ្ងៃទី២៩ មិថុនាមកដោយសារខ្លាចសមត្ថកិច្ចថៃចាប់ដាក់គុក មុននឹងបញ្ជូនត្រឡប់ទៅស្រុកកំណើត។

ចំណែកពលករដែលធ្វើការខុសច្បាប់នៅតំបន់មាត់សមុទ្រភាគខាងកើតរបស់ថៃម្នាក់ទៀត ថ្លែងថា កន្លែងធ្វើការរបស់ពួកគាត់មានពលករខ្មែរប្រមាណ ៤០នាក់ គឺសព្វថ្ងៃពួកគាត់ធ្វើការទាំងភិតភ័យ ហើយម្នាក់ៗមិនហ៊ានចេញដើរទៅណាឆ្ងាយពីកន្លែងធ្វើការនោះទេ។

មន្ត្រីទទួលបន្ទុកទទួលពលរខ្មែរដែលថៃចាប់បញ្ជូនត្រឡប់មកកម្ពុជា ប្រចាំច្រកទ្វារអន្តរជាតិប៉ោយប៉ែត អ្នកស្រី ស៊ិន ណាំយ៉ុង មានប្រសាសន៍ថា មួយរយៈចុងក្រោយនេះសមត្ថកិច្ចថៃ បានចាប់បញ្ជូនពលករត្រឡប់មកកម្ពុជាតាមច្រកប៉ោយប៉ែតមានចំនួនច្រើន ជាងកាលពីខែមិថុនា។ អ្នកស្រីអះអាងទៀតថា កាលពីថ្ងៃទី១ កក្កដា ថៃ

បញ្ជូនពលករប្រគល់ឲ្យអ្នកស្រីជាង៥០០នាក់ ហើយថ្ងៃក្រោយមកទៀតមាន ៧០នាក់ និងមួយរយនាក់ក្នុងមួយថ្ងៃ ជាដើម ដែលកាលពីខែមិថុនាភាគច្រើនថៃបញ្ជូនពលករមកប្រមាណពី៨ ទៅ២០នាក់ក្នុងមួយថ្ងៃប៉ុណ្ណោះ។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក(Adhoc) លោក ស៊ុំ ច័ន្ទគា លើកឡើងថា សមត្ថកិច្ចថៃបញ្ជូនពលករមកកម្ពុជានៅពេលនេះមិនមានអ្វីចម្លែកទេ ព្រោះដោយសារតែនៅកម្ពុជាគណបក្សនយោបាយកំពុងដំណើរឃោសនារកសំឡេងបោះឆ្នោត។ សព្វថ្ងៃពលករខ្មែរដែលកំពុងធ្វើការងារនៅប្រទេសថៃមានជាង ១ លាននាក់ ក្នុងនោះពលករមួយចំនួនធ្វើការងារខុសច្បាប់។

ច្បាប់របស់ក្រសួងការងារថៃ ដែលចាប់អនុវត្តន៍កាលពីថ្ងៃទី១ កក្កដា មកនោះ គឺពលករដែលធ្វើការមិនមានប័ណ្ណអនុញ្ញាតការងារ ឬធ្វើការក្រៅពីសិទ្ធិដែលអាចធ្វើបាន នឹងត្រូវទទួលការផាកពិន័យពី ៥ពាន់បាត ទៅ៥ម៉ឺនបាត ឬប្រមាណពី ១៧០ ទៅ១ពាន់ ៧០០ដុល្លារអាមេរិក ហើយពលករនឹងត្រូវបញ្ជូនត្រឡប់ទៅប្រទេសកំណើតវិញ ហើយហាមឃាត់មិនឱ្យធ្វើការនៅប្រទេសថៃ រយៈពេល ២ឆ្នាំ ដោយគិតចាប់ពីថ្ងៃទទួលពិន័យ។ ចំណែកពលករដែលមានបំណងចង់ទៅធ្វើការនៅប្រទេសថៃ ចាប់ពីថ្ងៃទី១ កក្កដា តទៅ គឺត្រូវទៅធ្វើការតាមរយៈក្រុមហ៊ុនដែលនាំពលករស្របច្បាប់ ដែលក្រសួងការងារកម្ពុជា - ថៃ បានឯកភាពគ្នា តាមរយៈការចុះអនុស្សរណៈយោគយល់គ្នា (MOU)ប៉ុណ្ណោះ។ ប៉ុន្តែសមត្ថកិច្ចថៃហាក់មិនទាន់ចុះអនុវត្តច្បាប់នេះមកលើពលករខ្មែរតឹងរ៉ឹងនៅឡើយទេ៕

## ពលរដ្ឋខ្មែរចំនួន៣នាក់ ឆ្លងដែនខុសច្បាប់កាប់ឈើក្រញូងក្នុងទឹកដី ត្រូវបាន អាជ្ញាធរថៃ បញ្ជូនមកឱ្យកម្ពុជាវិញ

http://cambodiapolice.com/policekh 9:46 pm 10 កក្កដា 2018

**ឧត្តរមានជ័យ៖**កាលពីព្រឹកថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ អាជ្ញាធរថៃបានបញ្ជូនប្រជាពលរដ្ឋខ្មែរចំនួន ៣នាក់មកឲ្យអាជ្ញាធរកម្ពុជាតាមច្រកអន្តរជាតិជាំ ដែលថៃចាប់ខ្លួនពីបទឆ្លងដែនចូលទៅកាប់ឈើក្រញូងខុសច្បាប់ក្នុងទឹកដីថៃ កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ ចូលតាមច្រកជាំផ្សារមឿងម៉ៃ ប្រទេសថៃ។ ប្រជាពលរដ្ឋដែលអាជ្ញាធរថៃបញ្ជូនមកវិញរួមមានទី១-ឈ្មោះ ក្រាយ ចិន្តា ភេទប្រុស អាយុ១៩ឆ្នាំ រស់នៅភូមិរំចេក ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ, ទី២-ឈ្មោះ ឡំ តូច ភេទប្រុស អាយុ១៨ឆ្នាំ រស់នៅភូមិជាមួយគ្នា និងទី៣-ឈ្មោះ ហេប ហិល ភេទប្រុស អាយុ២៣ឆ្នាំ រស់នៅភូមិជាមួយគ្នា។ បច្ចុប្បន្នត្រូវបានសមត្ថ កិច្ចធ្វើការអប់រំឲ្យត្រឡប់ទៅលំនៅដ្ឋានវិញរៀងៗ ខ្លួន៕

## មនុស្សជាង១៧០នាក់ត្រូវបានជួញដូរនៅមីយ៉ាន់ម៉ា ក្នុងពាក់កណ្ដាលឆ្នាំនេះ

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្ដិ៍ ចេញផ្សាយ ថ្ងៃទី 10 July, 2018

មីយ៉ាន់ម៉ា ៖ យោងតាមព័ត៌មាន គ្លូបលញូឡាយ របស់មីយ៉ាន់ម៉ា បានដកស្រង់សំដី ប៉ូលីស ប្រឆាំងការជួញដូរមនុស្ស ដោយនិយាយថា មនុស្សសរុបចំនួន ១៧៦ នាក់ ត្រូវបានជួញដូរនៅក្នុងប្រទេស មីយ៉ាន់ម៉ា ក្នុងរយៈពេលពាក់កណ្ដាល ឆ្នាំនេះ ។ ក្នុងចំណោមជនរងគ្រោះ មានជាង១០០នាក់ជាស្ត្រី ដែលនៅក្នុងរដ្ឋ សាន មានករណីជួញដូរ ខ្ពស់ បន្ទាប់មកគឺទីក្រុង យ៉ាងហ្គោន និងតំបន់ ម៉ាន ដាឡាយ។ ករណីទាំងអស់នេះ ជាប់ពាក់ព័ន្ធទៅនឹង ការរៀបការដោយ បង្ខំ ពេស្យាចារដោយបង្ខំ និងការកេងបវ័ញ្ចការងារ។ សភាប្រទេសមីយ៉ាន់ម៉ា ត្រូវ បានរំពឹងថា និងអនុម័តច្បាប់ប្រឆាំងការជួញដូរ នូវច្បាប់ដែលបាន ពិនិត្យឡើង វិញ ដោយផ្អែកលើ ច្បាប់ដែលបានអនុម័តកាលពីខែ កញ្ញា ឆ្នាំ២០០៥។ យោងតាមច្បាប់ប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០០៥ ជនណាដែល ជួញ ដូរស្ត្រី និងកុមារ និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ ជាអប្បបរិមា ១០ឆ្នាំនិងជា អតិបរិមា ជាប់ពន្ធនាគារមួយជីវិត៕

## ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨

## កម្ពុជាឲ្យពលករខ្មែរ រក្សាភាពស្ងៀមស្ងាត់ ខណៈជនខិលខូចថា សមត្ថកិច្ចថៃ កំពុងដេញចាប់ពលករខ្មែរ

https://www.dap-news.com/kh/ ថ្ងៃសុក្រ, ១៣ កក្កដា ២០១៨ 11:46 ដោយ: ខា ដា ID:114

ភ្នំពេញ៖ បន្ទាប់ពីមានជនខិលខូច និងក្រុមឆ្លៀតឱកាសមួយចំនួន បានយកឃ្លីបវីដេអូចាស់ៗ ដែលបានកន្លងហួសទៅជាច្រើនឆ្នាំ មកផ្សាយផ្ទាល់ឡើងវិញ តាមបណ្តាញសង្គមហ្វេសប៊ុកបំភាន់ថា ពលករខ្មែរនៅថៃ កំពុងត្រូវបានសមត្ថកិច្ចថៃដេញចាប់នោះ ស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ បានអំពាវនាវឲ្យពលករខ្មែរ ដែលស្នាក់នៅ និងធ្វើការ នៅថៃ រក្សាភាពស្ងៀមស្ងាត់ និងធ្វើការងារជម្មតា គ្មានរឿងអ្វីកើតឡើងនោះទេ ។

យោងតាមសេចក្តីប្រកាសព័ត៌មាន របស់ស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ ចេញនៅថ្ងៃទី១២ កក្កដា បានឲ្យដឹងថា ថ្មីៗនេះ មានក្រុមឆ្លៀតឱកាសមួយចំនួន បានយកឃ្លីបវីដេអូចាស់ៗ អំពីការចុះត្រួតពិនិត្យពលករបរទេសរបស់អាជ្ញាធរថៃមកផ្សព្វផ្សាយ ឡើងវិញតាមបណ្តាញសង្គមហ្វេសប៊ុក ក្នុងគោលបំណងបំពុលសង្គម បង្កការភ្ញាក់ផ្អើល និងកេងចំណេញផ្នែកនយោបាយ ។ ស្ថានទូតបញ្ជាក់ថា "សូមបងប្អូនពលករ និងសាធារណជន កុំជឿក្រុមជនខិលខូចបំផុសបំផុល តាមរយៈការយកឃ្លីបវីដេអូចាស់ៗ កន្លងហួសទៅជាច្រើនខែឆ្នាំ មកផ្សាយផ្ទាល់ឡើងវិញតាមបណ្តាញសង្គមហ្វេសប៊ុក បំភាន់ថា ពលករខ្មែរនៅថៃកំពុងត្រូវបាន សមត្ថកិច្ចថៃដេញចាប់ ។ ការពិត បច្ចុប្បន្នបងប្អូនពលករខ្មែរ កំពុងស្នាក់នៅនិងធ្វើការយ៉ាងល្អួនល្អ ក្នុងបរិយាកាសស្ងប់សុខ ពុំមានហេតុការណ៍អាក្រក់ ដូចការបំភាន់របស់ក្រុមជនខិលខូចឡើយ" ។ ស្ថានទូតបញ្ជាក់ទៀតថា ចំពោះពលករដែលមានឯកសារម្រាប់ស្នាក់នៅនិងធ្វើការនៅថៃ រក្សាភាពស្ងៀមស្ងាត់ និងបន្តអនុវត្តន៍ការងារជម្មតា ។ ដោយឡែកពលករ ដែលមិនមានឯកសារសម្រាប់ស្នាក់នៅ និងធ្វើការនៅថៃ ត្រូវរួសរាន់ទំនាក់ទំនង មកស្ថានទូតកម្ពុជា ដើម្បីដាក់ពាក្យស្នើសុំលិខិត ធ្វើដំណើរបណ្តោះអាសន្ន ទៅកម្ពុជាដើម្បីរៀបចំឯកសារស្របច្បាប់ និងត្រឡប់ចូលមកធ្វើការនៅថៃវិញ តាមរយៈប្រព័ន្ធ MOU ។

ចំពោះព័ត៌មានលំអិតបន្ថែម ពលករទាំងអស់អាចទាក់ទង មកមន្ត្រីស្ថានទូត កម្ពុជានៅទីក្រុងបាងកក តាមរយៈទូរស័ព្ទលេខ ០២ ៩៥៧ ៥៨៥១ / ០៩២ ៨០៥ ០៥៦១ / ០៩៤ ០៩២ ៥៩០៥ / ០៨៦ ៧៩៩ ៩៩៥៧ / ០៦៤ ៧៥៥ ៧៤០១។

សូមរំលឹកថា កាសែត The Nation របស់ថៃ បានចុះផ្សាយកាលពីថ្ងៃទី១០ កក្កដាថា ប្រជាជនកម្ពុជាប្រហែល១ពាន់នាក់ ត្រូវបានចោទប្រកាន់ថា ធ្វើការខុសច្បាប់ នៅក្នុងប្រទេសថៃ ហើយត្រូវបានចាប់ខ្លួន និងនិរទេស បន្ទាប់ពីរដ្ឋាភិបាលថៃ បានប្រកាស ពីការបញ្ចប់ រយៈពេលអនុគ្រោះដល់កម្មករ៕

## ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨

## នាវាដឹកទំនិញបុកទូកនេសាទត្រីលិច,សំណាងល្អពលករខ្មែរ០៨នាក់ត្រូវទូកផ្សេងចូលជួយទាន់

http://www.khmerlabour.com/ July 16, 2018

កាលពីពេលម៉ោង០៤:៤៥នាទី ទៀបភ្លឺថ្ងៃច័ន្ទទី១៦ ខែកក្កដា ឆ្នាំ២០១៨ កើតហេតុការណ៍នាវាដឹកទំនិញធំមួយគ្រឿងបានបង្កគ្រោះថ្នាក់បុកទូកនេសាទត្រីមួយគ្រឿងឈ្មោះកិតចាក់រើន១ពាក់ស្លាកលេខ៣០៩៤០០៤៥១ ហេតុការណ៍នេះឲ្យទូកនេសាទខាងលើងលិចក្នុងសមុទ្រក្បែរកោះសាម៉េតក្នុងខេត្តរ៉ាក់យ៉ង ។ យោងតាមរបាយការណ៍របស់អគ្គនាយកសមាគមនេសាទខេត្តសាមុតប្រាកានប្រទេសថៃបានប្រាប់អោយដឹងថា ទូកនេសាទត្រីដែលជួបគ្រោះថ្នាក់លើមានកម្មករធ្វើការចំនួន០៨នាក់ ក្នុងនោះមានពលករកម្ពុជាចំនួន០៥នាក់ និងជនជាតិថៃចំនួន

០៣នាក់ បច្ចុប្បន្នពលករទាំងអស់ជួយសង្គ្រោះដោយសុវត្ថិភាពអស់ហើយ។ ប្រភពដដែលបានបញ្ជាក់អោយថា ក្នុងហេតុការណ៍នេះមិនមានពលកររងគ្រោះថ្នាក់ឡើយ ប៉ុន្តែធ្វើឲ្យទូកនេសាទត្រីខាងរងការខូចខាតទាំងស្រុង ចំណែកឯនាវាដឹកទំនិញបង្កបានបើកគេចខ្លួនបាត់។

## ទូតកម្ពុជាប្រចាំកូរ៉េខាងត្បូងបានចុះផ្តល់សេវាបន្តសុពលភាពលិខិតឆ្លងដែនដោយឥតគិតថ្លៃជូនពលករខ្មែរបាន១៦០នាក់

http://www.rasmeinews.com/ July 16, 2018, 1:45 PM ដោយៈរ៉ាម៉ន

ភ្នំពេញៈ លោក ឡុង ឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជាប្រចាំនៅសាធារណរដ្ឋកូរ៉េ កាលពីថ្ងៃអាទិត្យទី១៥ ខែកក្កដា ឆ្នាំ២០១៨បានដឹកនាំសហការី សហការជាមួយ អង្គភាពអភិវឌ្ឍន៍ធនធានមនុស្សកូរ៉េប្រចាំទីក្រុងថេហ្គូ ចុះផ្តល់សេវាបន្តសុពលភាពលិខិតឆ្លងដែនដោយឥតគិតថ្លៃ បានចំនួន ១៦០នាក់។ លោក ឡុង ឌីម៉ង់ បានឱ្យដឹងតាមប្រព័ន្ធតេឡេក្រាមនៅព្រឹកថ្ងៃ១៦ ខែកក្កដានេះថា អនុវត្តន៍កំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តយន្តការបម្រើសេវាឱ្យកៀកជិត និងមានប្រសិទ្ធភាពជូនប្រជាពលរដ្ឋ ចូលរួមកាត់បន្ថយចំណាយ និងពេលវេលារបស់បងប្អូន នៅថ្ងៃអាទិត្យទី១៥ ខែកក្កដា នេះលោក បានដឹកនាំសហការី សហការជាមួយ អង្គភាពអភិវឌ្ឍន៍ធនធានមនុស្សកូរ៉េប្រចាំទីក្រុងថេហ្គូ ចុះផ្តល់សេវាបន្តសុពលភាពលិខិតឆ្លងដែនដោយឥតគិតថ្លៃ ប្រឹក្សាយោបល់ផ្នែកច្បាប់ការងារ និងផ្សព្វផ្សាយកម្មវិធីវិលត្រឡប់វិញក្រោយចប់អាណត្តិការងារ នៅអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សកូរ៉េប្រចាំទីក្រុងថេហ្គូជូនប្រជាពលរដ្ឋ បានចំនួន ១៦០នាក់។ ក្នុងនោះលោកទូតបានបញ្ជាក់ទៀតថាៈ ក្រុមការងារស្ថានទូតពិតជាពេញចិត្តនឹងបំពេញការងារដើម្បីបំរើផលប្រយោជន៍ជូនបងប្អូនខ្មែរជានិច្ច បើទោះបីនៅក្នុងថ្ងៃសម្រាកចុងសប្តាហ៍ក៏ដោយ៕

## ការរំលោភបំពានកម្លាំងពលកម្មលើទូកនេសាទថៃបន្តកើតមានចំពោះកម្មករខ្មែរ និងភូមា"

https://www.rfa.org/khmer/news/human-rights/ វ៉ែន សុមេធ 2018-07-16

អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ យូមែន រ៉ៃត៍ វ៉ច្ឆ (Human Rights Watch) អះអាងថា ការរំលោភបំពានកម្លាំងពលកម្មនៅតែបន្តកើតមានលើទូកនេសាទថៃ ហើយជនរងគ្រោះនៃការរំលោភបំពាននោះ គឺជាកម្មករខ្មែរ និងភូមា។ អង្គការអន្តរជាតិមួយនេះបន្តថា រដ្ឋាភិបាលថៃបានបន្តលាក់លៀមការរំលោភសិទ្ធិការងារនៅលើទូកនេសាទ ដែលទាមទារឱ្យសហភាពអឺរ៉ុបត្រូវពិនិត្យមើលឡើងវិញលើសម្ពាធដែលគួរដាក់លើប្រទេសថៃ ខណៈមន្ត្រីសិទ្ធិមនុស្សកម្ពុជាស្នើឱ្យរដ្ឋាភិបាលបង្កើនកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីជួយដល់ពលរដ្ឋរបស់ខ្លួនដែលរងគ្រោះដោយសារការរំលោភបំពាន និងកេងប្រវ័ញ្ចកម្លាំងពលកម្មលើទូកនេសាទរបស់ថៃ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ បានផ្ញើលិខិតមួយច្បាប់ទៅគណៈកម្មការជំនាញរបស់សហភាពអឺរ៉ុបថ្មីៗនេះ ដើម្បីទាមទារឱ្យមានការដាក់សម្ពាធលើប្រទេសថៃ អោយបញ្ឈប់ការប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំ និងការរំលោភបំពានផ្សេងទៀតដែលកើតមានលើកម្មករនេសាទ។

នាយកប្រតិបត្តិទទួលបន្ទុកកិច្ចការតំបន់អាស៊ីនៃអង្គការ យូមែន រ៉ៃត៍ វ៉ច្ឆ (Human Rights Watch) លោក ប្រ៉ែដ អាដាម (Brad Adams) ថ្លែងនៅក្នុងលិខិតនោះថា កំណែទម្រង់របស់រដ្ឋាភិបាលថៃលើវិស័យនេសាទ នៅតែមិនទាន់ដោះស្រាយបាននៅឡើយ ចំពោះបញ្ហានៃការរំលោភសិទ្ធិការងារ។ លោកបានជំរុញឱ្យសហភាពអឺរ៉ុបប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនក្នុងនាមជាអ្នកនាំចូលគ្រឿងសមុទ្រដ៏ធំរបស់ថៃ ទាមទារឱ្យមានការកែទម្រង់បន្ថែមទៀត ដើម្បីជួយឱ្យជីវិតកម្មករទូកនេសាទមានភាពប្រសើរឡើង។ យូមែន រ៉ៃត៍ វ៉ច្ឆ អះអាងថា កម្មករទូកនេសាទនៅតែត្រូវជំពាក់បំណុលគេវ័ណ្ឌក មិនត្រូវបានគេអនុញ្ញាតឱ្យប្តូរថៅកែ ទទួលបានប្រាក់ខែមិនទាន់ពេលវេលា ប្រាក់ខែទាបជាងប្រាក់ឈ្នួលអប្បបរមា មិនទទួលបានការការពារពីច្បាប់របស់ប្រទេសថៃ និងគ្មានសិទ្ធិបង្កើត

សហជីពការងារជាដើម។ លើសពីនេះ ពួកគេនៅតែត្រូវបានថៅកែ និងមេការទូក បង្ខំឱ្យធ្វើការលើសម៉ោង គំរាមកំហែង និងវាយធ្វើបាប ព្រមទាំងត្រូវបានដកហូតឯកសារទាំងអស់ដែលពួកគេមាននៅជាប់នឹងខ្លួនទៀតផង។ ជនរងគ្រោះទាំងនោះ សុទ្ធសឹងតែជាជនជាតិខ្មែរ និងភូមា ដែលបានធ្វើចំណាកស្រុកទៅធ្វើការងារនៅប្រទេសថៃតាមរយៈមេខ្យល់ ហើយត្រូវបានគេលក់ ឬជួញដូរកម្លាំងពលកម្មលើទូកនេសាទរបស់ថៃ។

អាស៊ីសេរីមិនទាន់អាចទាក់ទងអាជ្ញាធរថៃ ដើម្បីឆ្លើយតបរឿងនេះបានទេនៅថ្ងៃទី១៦ កក្កដា ប៉ុន្តែកាលពីខែមករាកន្លងទៅ អាជ្ញាធរថៃធ្លាប់បានបដិសេធការរកឃើញរបស់អង្គការឃ្យូមែន រ៉ៃត៍ វ៉ច្ឆ ដែលថា ឧស្សាហកម្មនេសាទថៃនៅតែជាសំបុកនៃការរំលោភបំពានសិទ្ធិការងារ និងការជួញដូរកម្លាំងពលកម្មដោយខុសច្បាប់នោះ។ អាជ្ញាធរថៃអះអាងថា ខ្លួនបានដាក់ចេញនូវកំណែទម្រង់ និងធ្វើបច្ចុប្បន្នភាពច្បាប់នេសាទ ហើយបានអនុវត្តយន្តការទាំងនេះយ៉ាងតឹងរ៉ឹង ដោយបានដកហូតអាជ្ញាប័ណ្ណទូកនេសាទជាង ៤ពាន់ អាជ្ញាប័ណ្ណ កាត់ទោសជនសង្ស័យជាង ១០០នាក់ និងជួយសង្គ្រោះជនរងគ្រោះ ១៦០នាក់ ចាប់តាំងពីទទួលរងការព្រមានពីសហភាពអឺរ៉ុប កាលពីឆ្នាំ២០១៥ នោះ។

ទោះបីជាយ៉ាងណា លោក ប្រ៊ែដ អាដាម (Brad Adams) អះអាងថា កំណែទម្រង់របស់រដ្ឋាភិបាលយោធាថៃនេះ មានតែនៅលើក្រដាសប៉ុណ្ណោះ ឯការអនុវត្តជាក់ស្តែងវិញ គ្មានអ្វីវិវឌ្ឍគួរឱ្យកត់សម្គាល់ឡើយ។ លោកអំពាវនាវដល់សហភាពអឺរ៉ុបដាក់សម្ពាធលើរដ្ឋាភិបាលថៃបន្ថែមទៀត ដើម្បីការពារសិទ្ធិ សុខភាព និងសុវត្ថិភាពជូនកម្មករទូកនេសាទ និងស្នើឱ្យអតិថិជនគ្រឿងសមុទ្រនៅអឺរ៉ុបទាំងអស់ត្រូវប្រាកដក្នុងចិត្តថា គ្រឿងសមុទ្ររបស់ពួកគេដែលនាំចូលពីប្រទេសថៃនោះ មិនមានជាប់ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច ឬជួញដូរកម្លាំងពលកម្មជាដាច់ខាត។

ប្រទេសថៃមានចំនួនកម្មករចំណាកស្រុកខ្ពស់ជាងគេក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺជិត៤លាននាក់ (៣.៧៦) នៅក្នុងឆ្នាំ ២០១៥ ក្នុងនោះ ៥៣ ភាគរយមកពីប្រទេសភូមា ២៦ ភាគរយមកពីប្រទេសឡាវ និង ២១ ភាគរយមកពីកម្ពុជា។ គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៧ កម្មករចំណាកស្រុកកម្ពុជា ឡាវ និងភូមាដែលបានចុះឈ្មោះរួចរាល់មានចំនួនជិត ២លាននាក់ (១,៧២៦,៤១៥) ក្នុងនោះជិត ៥ម៉ឺននាក់ ចុះឈ្មោះធ្វើការក្នុងឧស្សាហកម្មនេសាទ។ នេះបើយោងតាមទិន្នន័យរបស់ធនាគារពិភពលោក និងទិន្នន័យរបស់អាជ្ញាធរថៃ ដែលត្រូវបានអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ ឃ្យូមែន រ៉ៃត៍ វ៉ច្ឆ ដកស្រង់បញ្ជាក់ក្នុងរបាយការណ៍ស៊ើបអង្កេតរបស់ខ្លួនដែលមានចំណងជើងថា "ការកេងប្រវ័ញ្ចកម្លាំងពលកម្មដោយអាថ៌កំបាំង" ចេញផ្សាយកាលពីខែមករា កន្លងទៅ។ ដោយសារជនរងគ្រោះនៃការកេងប្រវ័ញ្ចកម្លាំងពលកម្មនេះ គឺជាជនជាតិខ្មែរ មន្ត្រីសិទ្ធិមនុស្សក្នុងស្រុកស្នើឱ្យរដ្ឋាភិបាលកម្ពុជា បង្កើនកិច្ចខិតខំបន្ថែមទៀតដើម្បីជួយដល់ពលរដ្ឋរបស់ខ្លួនដែលធ្លាក់ខ្លួនជាកម្មករទូកនេសាទរបស់ថៃ។

ប្រធានគ្រប់គ្រងការិយាល័យឃ្លាំមើលសិទ្ធិមនុស្សនៃអង្គការលីកាដូ (LICADHO) លោក អំ សំអាត ថ្លែងថា ការធ្លាក់ខ្លួនក្លាយជាកម្មករទូកនេសាទរបស់ថៃនេះ ដោយសារមូលហេតុច្រើនយ៉ាង ដូចជា ការធ្វើចំណាកស្រុកដោយខុសច្បាប់ ការចាញ់បោកមេខ្យល់ កង្វះខាតព័ត៌មានមុននឹងសម្រេចចិត្ត និងភាពក្រីក្រជាដើម។ លោកស្នើឱ្យរដ្ឋាភិបាលកម្ពុជាពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីថៃបន្ថែមទៀត ដើម្បីតាមដាន និងឃ្លាំមើលស្ថានភាពរបស់កម្មករខ្មែរដែលធ្វើការលើទូកនេសាទរបស់ថៃ ចៀសវាងការបាត់ដំណឹងពួកគាត់ដោយមិនដឹងមូលហេតុ។ លោកក៏ស្នើឱ្យរដ្ឋាភិបាលផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីរឿងកេងប្រវ័ញ្ចកម្លាំងពលកម្មនេះ ព្រមទាំងចាត់វិធានតាមផ្លូវច្បាប់ទៅលើក្រុមមេខ្យល់ដែលអូសទាញពលរដ្ឋខ្មែរឱ្យទៅធ្វើការដោយខុសច្បាប់នៅប្រទេសថៃនោះ ឱ្យបានតឹងរ៉ឹងបំផុត។ «»

មន្ត្រីសិទ្ធិមនុស្សរូបនេះ ក៏ស្នើដល់ប្រជាពលរដ្ឋឱ្យគិតគូរឱ្យបានម៉ត់ចត់មុននឹងសម្រេចចិត្តធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ ជាពិសេសត្រូវប្រុងប្រយ័ត្នចំពោះការអូសទាញរបស់មេខ្យល់ដែលល្បួងនាំទៅធ្វើការនៅ

ប្រទេសថៃ ដោយប្រាប់ថា ទទួលបានប្រាក់ខែច្រើននោះ។ ក្នុងករណីសម្រេចចិត្តថាត្រូវទៅធ្វើការនៅប្រទេសថៃមែន លោកស្នើឱ្យពលរដ្ឋទៅដោយស្របច្បាប់ និងត្រូវរក្សាអត្តសញ្ញាណរបស់ខ្លួនកុំផ្លាស់ប្តូរពេលទៅដល់ប្រទេសថៃ។ ជាពិសេសលោកស្នើឱ្យពលរដ្ឋខ្មែរដែលចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ ត្រូវចៀសវាងការងារជាកម្មករទូកនេសាទ ដ្បិតនេះជាការងារប្រឈមនឹងការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងជាការងារគ្រោះថ្នាក់បំផុត បើប្រៀបធៀបនឹងការងារផ្សេងទៀត៕

## សហភាពអឺរ៉ុបផ្តល់ជំនួយជាង២៩លានដុល្លារដើម្បីការពារសិទ្ធិពលករចំណាកស្រុកជាស្ត្រី

https://wmc.org.kh/ ថ្ងៃសៅរ៍ ទី១៤ ខែកក្កដា ឆ្នាំ២០១៨ ធូ វីរៈ

ភ្នំពេញ៖ សហភាពអឺរ៉ុបបានផ្តល់ជំនួយឥតសំណងជាង ២៩ លានដុល្លារ ដើម្បីការពារសិទ្ធិនិងសុវត្ថិភាពរបស់ពលករចំណាកស្រុកជាស្ត្រីនៅក្នុងតំបន់អាស៊ាន។ ចំពោះពលករចំណាកស្រុកជាស្ត្រីខ្មែរនូវមិនទាន់មានសុវត្ថិភាព និងការគោរពសិទ្ធិពេញលេញទេ ព្រោះពួកគេងាយរងគ្រោះពីការជួញដូរ និងអំពើហិង្សាផ្លូវភេទ និងផ្លូវកាយ។

យោងតាមសេចក្តីជូនដំណឹងរបស់សហភាពអឺរ៉ុប(EU)ចេញផ្សាយនៅថ្ងៃទី ១២ ខែ កក្កដានេះ សម្រេចផ្តលជំនួយឥតសំណងជាង ២៥ លានអឺរ៉ូ ឬស្មើនឹងជាង ២៩ លានដុល្លារអាមេរិក ក្នុងកម្មវិធី«សុវត្ថិភាព និងយុត្តិធម៌»សម្រាប់ស្ត្រីចំណាកស្រុកនៅក្នុងតំបន់អាស៊ាន។ ចំពោះស្ថានភាពពលករចំណាកស្រុកខ្មែរជាស្ត្រីនូវពុំទាន់ទទួលបានសុវត្ថិភាពក្នុងការធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេស ពិសេសការចំណាកស្រុកដោយខុសច្បាប់។

លោកវរសេនីយ៍ឯក គឹម ចិន្តា នាយកការិយល័យឆ្លងដែននៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សរបស់ក្រសួងមហាផ្ទៃបានបង្ហាញរបាយការណ៍ក្នុងឆ្នាំ ២០១៧ថា រាជរដ្ឋាភិបាលបានជួយសង្គ្រោះស្ត្រីខ្មែររងគ្រោះទៅក្រៅប្រទេសបានចំនួន ២៦២ នាក់។ អង្គការUN Women អង្គការពលកម្មអន្តរជាតិ( ILO) អង្គការសង្គមស៊ីវិល និងសហភាពអឺរ៉ុបធ្វើការជាមួយរាជរដ្ឋាភិបាល និងអាជ្ញាធរថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវានានាក្នុងការកែលម្អច្បាប់ការងារ ការទទួលបានព័ត៌មាន និងសេវាកម្ម ដើម្បីបង្ការទប់ស្កាត់បញ្ចប់អំពើហិង្សា និងការជួញដូរស្ត្រី និងកុមារី។ លោកវរសេនីយ៍ឯក គឹម ចិន្តា បន្ថែមថា ស្ត្រីរហូតដល់ ៥៨ នាក់ ត្រូវបានចាញ់បោកមេខ្យល់លក់ទៅឱ្យជនជាតិចិន ដើម្បីរៀបការជាមួយបុរសជនជាតិចិនពីម្នាក់ទៅម្នាក់ទៀត ហើយស្ត្រីទាំងនោះរងគ្រោះដោសារអំពើហិង្សាផ្លូវភេទ និងផ្លូវកាយធ្ងន់ធ្ងររហូតដល់២៨នាក់។

សហភាពអឺរ៉ុបប៉ាន់ប្រមាណថា ពលករចំណាកស្រុកប្រមាណ ១០ លាននាក់នៃជនន្តោប្រវេសន៍ ២០,២ លាននាក់ នៅលើសកលលោកជាស្ត្រីមកពីតំបន់អាស៊ាន។ ស្ត្រីមានចំនួនច្រើនបម្រើការងារតាមផ្ទះនិងការថែទាំ ប៉ុន្តែពួកគេក៏មាននៅក្នុងវិស័យសំណង់ រោងចក្រ កសិកម្ម និងសេវាកម្ម។ ពលករចំណាកស្រុកកម្ពុជាមានប្រមាណ ១ លាន ២ សែន ដែលកំពុងបម្រើការងារនៅប្រទេសថៃ ម៉ាឡេស៊ី កូរ៉េខាងត្បូង ប្រទេសជប៉ុន ហុងកុង និងប្រទេសមួយចំនួនទៀត។ នេះបើរបាយការណ៍របស់ក្រសួងការងារ។ ក្របខ័ណ្ឌការងារ និងចំណាកស្រុកជាទូទៅក្លាយជាបញ្ហាយេនឌ័រនៃអំពើហិង្សារាងកាយ និងផ្លូវភេទមានអត្រាខ្ពស់ចំពោះស្ត្រីនៅក្នុងតំបន់អាស៊ាន។ ពេលចំណាកស្រុកស្ត្រីងាយរងគ្រោះចំពោះអំពើហិង្សា និងការជួញដូរពីតំបន់ទៅតំបន់មួយទៀត។

យោងតាមសេចក្តីជូនដំណឹងរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកាលពីថ្មីនេះ ឲ្យដឹងថា រាជរដ្ឋាភិបាលជួយសង្គ្រោះស្ត្រីខ្មែរចំនួន ១៦ នាក់ ត្រឡប់មកកម្ពុជាវិញ។ ក្នុងនោះស្ត្រីខ្មែរចំនួន ១១ នាក់ ត្រូវបានមេខ្យល់នាំយកទៅរៀបការជាមួយប្តីជនជាតិចិនដោយខុសច្បាប់ ហើយស្ត្រីខ្មែរ ៣នាក់ ជាអនីតិជន មានអាយុ

ពី ១៣ ដល់ ១៦ ឆ្នាំ ត្រូវបានគេជួញដូរទៅប្រទេសថៃដែលត្រូវបានបញ្ជូនមកកម្ពុជាវិញតាមច្រកទ្វារអន្តរជាតិ ប៉ោយប៉ែត។

កម្មវិធី«សុវត្ថិភាព និងយុត្តិធម៌»សម្រាប់ស្ត្រីចំណាកស្រុកនៅក្នុងតំបន់អាស៊ានមានរយៈពេល៥ឆ្នាំដោយចាប់ពីខែ មករា ឆ្នាំ ២០១៨។ កម្មវិធីនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនៅទិន្នន័យ និងចំណេះដឹងអំពីសិទ្ធិ និងការចូលរួមរបស់ពលករចំណាកស្រុក។ តាមរយៈកម្មវិធីនេះ នឹងជួយផ្លាស់ប្តូរឥរិយាបថរបស់អ្នកពាក់ព័ន្ធនានា ដើម្បីធានាសុវត្ថិភាព ការអនុវត្តច្បាប់ប្រកបដោយយុត្តិធម៌ដល់ពលករចំណាកស្រុកនៅក្នុងតំបន់។

បើតាមរបាយការណ៍ក្រសួងការបរទេសអាមេរិកស្តីពី«ការជួញដូរមនុស្សឆ្នាំ ២០១៨» បង្ហាញថា កម្ពុជាស្ថិតនៅក្នុងចំណាត់ថ្នាក់ទី២ក្នុងទប់ស្កាត់ការជួញដូរមនុស្ស៣ឆ្នាំជាប់គ្នាចាប់តាំងពីឆ្នាំ ២០១៦ ដែលមានន័យថា ការទប់ស្កាត់អំពើជួញដូរមនុស្សមានស្ថានភាពល្អប្រសើរ។ ក្នុងរបាយការណ៍នេះ បញ្ជាក់ថា ក្រសួងការបរទេសកម្ពុជាធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែររងគ្រោះចំនួន ៩៨៦ នាក់ ពីប្រទេសចិន ថៃ វៀតណាម និងម៉ាឡេស៊ី ខណៈឆ្នាំ ២០១៦ ពលរដ្ឋខ្មែររងគ្រោះមានចំនួន ៨១៥ នាក់។ ដោយឡែកក្រសួងសង្គមកិច្ចជួយសង្គ្រោះពលរដ្ឋខ្មែររងគ្រោះចំនួន ២៤៣ នាក់។

លោក Neven Mimica ស្នងការសហភាពអឺរ៉ុបសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍អន្តរជាតិមានប្រសាសន៍ថា«យើងត្រូវលុបបំបាត់ឫសគុលអំពើហិង្សាគ្រប់រូបភាពនិងគ្រប់ទម្រង់នៃអំពើហិង្សាលើរាងកាយរហូតដល់អំពើហិង្សាផ្លូវសេដ្ឋកិច្ច និងអំពើហិង្សាសង្គមប្រឆាំងនឹងស្ត្រីនិងកុមារី»៕

## អាជ្ញាធរថៃចាប់ពលករខ្មែរបញ្ជូនមកវិញប្រមាណ៥០ទៅ១០០នាក់ក្នុង១ថ្ងៃ

http://ppd-news.net/ July 17, 2018

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរខុសច្បាប់ប្រមាណ៥០ទៅ១០០នាក់ក្នុង១ថ្ងៃត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនមកត្រឡប់មកកម្ពុជាវិញ ខណៈដែលរាជរដ្ឋាភិបាលថៃរឹតបន្តឹងច្បាប់ការងារ។ នេះជាការលើកឡើងលោក សួន បវរ អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាខេត្ត កាលពីម្សិលមិញនៅសាលាប្រជុំសាលាខេត្តបន្ទាយមានជ័យ។

លោក សួន បវរ អភិបាលខេត្តបន្ទាយមានជ័យ បានមានប្រសាសន៍ថា ដោយមានលិខិតពីក្រសួងមហាផ្ទៃជូនដំណឹងរដ្ឋបាលសាលាខេត្តបន្ទាយមានជ័យ គឺរដ្ឋាភិបាលថៃបានរឹតបន្តឹងច្បាប់ការងារនៅប្រទេសថៃ និងចាប់ពលករដែលធ្វើការគ្មានច្បាប់ និងចាប់បញ្ជូន ដាក់ស្តែង រយៈពេល២ទៅ៣ថ្ងៃនេះ ភាគីថៃបានចាប់បញ្ជូនពលករខ្មែរខុសច្បាប់១ថ្ងៃមានប្រមាណ៥០ទៅ១០០នាក់ដូចធម្មតា។ លោកបញ្ជាក់ថា មូលហេតុដែលភាគីថៃចាប់បញ្ជូនពលករខ្មែរខុសច្បាប់ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យដូចធម្មតា គឺមន្ត្រីច្រកចេញចូលតែមួយ រដ្ឋបាលសាលាខេត្តបន្ទាយមានជ័យ បានទទួលធ្វើប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋបានចំនួន១៧.៥០០នាក់ និងផ្តល់ជូនបានចំនួន១៥.០០០ប័ណ្ណ ។

យោងតាមរបាយការណ៍ប្រចាំខែមិថុនា ឆ្នាំ២០១៨ ការងារប្រឆាំងការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទគ្រប់គ្រងទេសន្តប្រវេសន៍ពលករខ្មែរ ដែលត្រូវភាគីថៃចាប់បញ្ជូនមកតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត មានចំនួន ១.៨៩៣នាក់ ស្រី៦១៧នាក់ និងកុមារ១៧៣នាក់ ៕ ប្រភព ៖ អគ្គស្នងការនគរបាលជាតិ

## ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨
## នេះហើយឬជីវិតពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់

https://www.facebook.com/ ទឹកចិត្ត ពលករ ឆ្លងដែន ថ្ងៃទី18 ខែកដ្កា ឆ្នាំ2018

នៅថ្ងៃម្សិលមិញនេះត្រូវនឹងថ្ងៃអង្គារ៍ ទី17 ខែកក្កដា ឆ្នាំ2018 សមត្ថកិច្ចប៉ូលីសថៃ ចាប់បានពលរដ្ឋជនជាតិខ្មែរចំនួន៥នាក់ ពលរដ្ឋខ្មែរទាំង៥នាក់នេះត្រូវបានប៉ូលីសថៃចាប់ខ្លួនក្នុងករណីលួចឆ្លងដែនចូលក្នុងប្រទេសថៃដោយខុសច្បាប់។ សមត្ថកិច្ចប៉ូលីសថៃ នៅក្នុងខេត្តស្រះកែវ នឹងចាប់បញ្ជូនពលរដ្ឋខ្មែរទាំង៥នាក់នេះយកទៅដំណើរការតាមផ្លូវច្បាប់ ។ សូមបងប្អូនពលរដ្ឋខ្មែរដែលឆ្លងដែនចូលក្នុងប្រទេសថៃខុសច្បាប់ សូមបងប្អូនប្រយ័ត្នខ្លួនផង រាល់ថ្ងៃនេះថៃកាន់តែរិតបន្តឹងច្បាប់ចាប់អ្នកឆ្លងដែនខុសច្បាប់ខ្លាំងណាស់ សូមបងប្អូនខ្មែរប្រយ័ត្នខ្លួនផង (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន) 18-7-2018។

**ទូតកម្ពុជា ប្រចាំប្រទេសថៃ អន្តរាគមន៍ ជួយពលករខ្មែរ២៤នាក់ ដែលចាញ់បោកមេខ្យល់**

https://www.dap-news.com/kh/ ថ្ងៃពុធ, ១៨ កក្កដា ២០១៨ 10:44 ដោយ: ដើមអម្ពិល ID:112

ភ្នំពេញ៖ ស្ថានទូត ព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសថៃ បានធ្វើអន្តរាគមន៍ ជួយពលករ ខ្មែរចំនួន ២៤ នាក់ ដែលចាញ់បោកមេខ្យល់ ចូលមកធ្វើការ និងស្នាក់នៅក្នុងប្រទេសថៃ ដោយមិនមាន ឯកសារស្របច្បាប់។ យោងតាមបណ្តាញ ទំនាក់ទំនងសង្គមហ្វេសប៊ុក របស់ស្ថានទូត ព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសថៃ បានឲ្យដឹងថាកាលពីថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៨ ក្រុមទីប្រឹក្សាទទួល បន្ទុកពលករបាន ចុះទៅជួបផ្ទាល់ជាមួយពលករខ្មែរ ចំនួន ២៤ នាក់ កន្លែងស្នាក់នៅ របស់ពលករ ស្ថិតក្នុង ខេត្តសាមុត្រប្រាកាន ប្រទេសថៃ ហើយបានទទួលព័ត៌មានថា ពលករខ្មែរទាំងនោះ បានចំណាយប្រាក់ទៅឱ្យមេខ្យល់នៅក្នុងប្រទេសថៃ ចំនួន ១៨,០០០បាត ក្នុងម្នាក់ សម្រាប់ដំណើរការធ្វើលិខិតឆ្លងដែន ស្នើសុំទិដ្ឋាការស្នាក់នៅ និងទិដ្ឋាការការងារ ដោយស្របច្បាប់ ក៏ប៉ុន្តែរហូតដល់ថ្ងៃនេះ ពលករទាំងអស់ពុំបានទទួលលិខិតឆ្លងដែន ពីមេខ្យល់នៅឡើយ។

កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ ស្ថានទូតបានចេញលិខិតធ្វើដំណើរបណ្តោះអាសន្ន (Laissez-Passer) ជូនពលករទាំង២៤នាក់ និងក្រុមទីប្រឹក្សាទទួលបន្ទុកពលករ តំណាងឯក អគ្គរាជទូត សហការជាមួយស្ថានអគ្គកុងស៊ុលប្រចាំខេត្តសាកែវ បានជូនពលករទាំង២៤នាក់ ត្រឡប់ទៅប្រទេសកម្ពុជាវិញប្រកដោយសុវត្ថិភាពតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត និងបានណែនាំពួកគាត់ឱ្យទៅរៀបចំឯកសារស្របច្បាប់ និងចូលមកធ្វើការក្នុងប្រទេសថៃវិញ តាមរយៈប្រព័ន្ធ MOU ហើយកុំឱ្យចាញ់បោកមេខ្យល់ទៀត។

សូមរំលឹកថាលោក សួន បវរ អភិបាល ខេត្តបន្ទាយមានជ័យបានឲ្យដឹងថាក្រោយ បញ្ចប់ការ បញ្ជាក់អត្តសញ្ញាញ ជូនពលករអាជ្ញាធរថៃ បានចាប់ពលករខ្មែរខុសច្បាប់ បញ្ជូនមក១ថ្ងៃប្រមាណ៥០ទៅ១០០នាក់ ខណៈរាជរដ្ឋាភិបាលថៃផ្តើម រឹតបន្តឹងច្បាប់ការងារ ។

យោងតាមរបាយការណ៍ ប្រចាំខែមិថុនា ឆ្នាំ២០១៨ ការងារប្រឆាំងការជួញដូរ មនុស្ស និងអាជីវកម្មផ្លូវភេទគ្រប់គ្រងទេសន្ត ប្រវេសន៍ពលករខ្មែរ ដែលត្រូវភាគីថៃចាប់បញ្ជូនមកតាមច្រកទ្វារអន្តរជាតិ ប៉ោយប៉ែត មានចំនួន ១.៨៩៣នាក់ ស្រី៦១៧នាក់ និងកុមារ១៧៣នាក់ ៕

## ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨

## ឯកអគ្គរាជទូតកម្ពុជា ស្នើអាជ្ញាធរ និងថៅកែរោងចក្រនៅកូរ៉េ បន្ថយកចិត្តទុកដាក់ និងជ្រើសរើសពលករខ្មែរបន្ថែម

https://www.dap-news.com/kh ថ្ងៃពុធ, ១៨ កក្កដា ២០១៨ 15:46 ដោយ: ស៊ាន កុសល ID:113

**ភ្នំពេញ៖** ឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ លោក ឡុង ឌីម៉ង់ បានស្នើរដល់អាជ្ញាធរ និងថៅកែរោងចក្រនៅកូរ៉េ សូមឲ្យបន្តយកចិត្តទុក្ខដាក់ និងជ្រើសរើសពលករខ្មែរ បន្ថែមទៀត ទៅធ្វើការនៅកូរ៉េ ។ ការស្នើរសុំរបស់លោក ឡុង ឌីម៉ង់ ធ្វើឡើង នារសៀលថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ ខណៈលោក និងក្រុមការងារទីប្រឹក្សាការងារ ទទួលបន្ទុកពលករ បានសហការជាមួយមជ្ឈមណ្ឌល ប្រឹក្សាយោបល់ជនបរទេស នាទីក្រុងអានសាន បានចុះទស្សនៈកិច្ច និងសួរសុខទុក្ខបងប្អូន ពលករខ្មែរចំនួន ១០នាក់ នៅរោងចក្រ Changdae Metal (រោងចក្រផលិតតួម៉ាស៊ីនរបស់រថយន្ត) នាតំបន់អានសាន ។ ជាមួយគ្នានោះដែរ ឯកអគ្គរាជទូត សូមថ្លែងអំណរគុណជាអនេកដល់សាលាក្រុងអានសាន និងមជ្ឈមណ្ឌលប្រឹក្សាយោបល់ ជនបរទេសនាទីក្រុងអានសាន ដែលតែងតែសហការបង្កលក្ខណៈ ដល់ស្ថានទូតកម្ពុជាក្នុងការ ជួយដោះស្រាយបញ្ហានានា របស់ប្រជាពលរដ្ឋខ្មែរ នៅទីក្រុងអានសាន និងសូមថ្លែងអំណរគុណ ដល់ម្ចាស់រោងចក្រ Changdae Metal លោក ស៊ុង ក្វាងស៊ង ដែលបានស្រលាញ់ថែទាំពលករកម្ពុជាទាំង១០នាក់ ដែលកំពុងបម្រើការងារ នៅរោងចក្ររបស់លោក និងស្នើដល់លោកថៅកែ សូមបន្តជ្រើសរើសពលករកម្ពុជា បន្ថែមទៀតនៅពេល ដែលពង្រីករោងចក្រ ហើយសូមលើកទឹកចិត្ត ឱ្យមកបណ្តាក់ទុនបើករោងចក្រ នៅកម្ពុជាដើម្បីជ្រើសរើស អតីតពលករដែលបាន ចប់អាណត្តិធ្វើការដើម្បី បន្តជំនាញវិជ្ជាជីវៈរបស់ពួកគេ ៕

## ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៨

### GMAC **សហជីព បារម្ភថា កម្មករ កម្មការិនី នឹងចំណាកស្រុក** បើ EU **មិនការអនុគ្រោះពន្ធ**

https://wmc.org.kh/ ថ្ងៃសុក្រ ទី២០ ខែកក្កដា ឆ្នាំ២០១៨ លៀ ស៊ីណា

ភ្នំពេញ ៖ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា សហជីពតំណាងកម្មករ និងអ្នកវិភាគ បង្ហាញក្តីព្រួយបារម្ភដូចគ្នាថា កម្មករ កម្មការិនី នឹងបាត់បង់ការងារ ហើយនឹងអាចឈានដល់ការធ្វើចំណាកស្រុកថែមទៀតផង បើសិនជាសភាអឺរ៉ុប សម្រេចបិទការអនុគ្រោះពន្ធនាំទំនិញពីកម្ពុជា។

លោក លៀ ស៊ីណា រាយការណ៍ ៖ រហូតមកដល់ចុងខែកក្កដា នេះ សេចក្តីសម្រេចរបស់សភាពអឺរ៉ុប ស្តីពីប្រព័ន្ធអនុគ្រោះពន្ធ លើទំនិញរបស់កម្ពុជា នៅ មិនទាន់ត្រូវបានប្រកាសជាសាធារណៈនៅឡើយទេ។ តែបែបនេះក្តី មានការព្រួយបារម្ភថា សហភាពអឺរ៉ុប អាចនឹងបិទការអនុគ្រោះ លើទំនិញគ្រប់ប្រភេទពីកម្ពុជា។ ទាំងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា សហជីពតំណាងកម្មករ និងអ្នកវិភាគ សុទ្ធតែបង្ហាញពីក្តីព្រួយបារម្ភដូចៗគ្នា ពីការបាត់បង់ការងាររបស់ពលរដ្ឋខ្មែរដ៏ច្រើនលើសលប់ និងការធ្វើចំណាកស្រុករបស់ពលការិនីខ្មែរ ទៅក្រៅប្រទេស ប្រសិនបើពិតជាមានការបិទ ការអនុគ្រោះពន្ធ សម្រាប់ទំនិញកម្ពុជា នៅក្នុងទីផ្សារអឺរ៉ុបពិតមែន។

លោក កេន លូ អគ្គលេខាធិការសមាគមរោងចក្រកាត់ដេរនៅកម្ពុជា មានប្រសាសន៍ថា វិស័យវាយនភណ្ឌនេះ បានផ្តល់ការងារ ដល់ប្រជាពលរដ្ឋខ្មែរយ៉ាងច្រើន បើទោះជាមិនមែនទូទាំងប្រទេសក្តី ក៏ប៉ុន្តែជាចំនួនដ៏ច្រើនមួយ។ លោកបន្តថា ក្នុងករណីដែលមានការបិទ ការអនុគ្រោះពន្ធនាំទំនិញពីកម្ពុជា ទៅកាន់ទីផ្សារសហភាពអឺរ៉ុបពិតមែន ច្បាស់ណាស់ ពលរដ្ឋខ្មែរច្រើនសិបម៉ឺននាក់ នឹងត្រូវអត់ការងារធ្វើ ៖«វិស័យពួកយើងមានកម្មករ ជាង ៧០ម៉ឺននាក់ ដែលកំពុងធ្វើការនៅវិស័យកាត់ដេរសម្លៀកបំពាក់ អញ្ចឹងបើសិនបាត់ការអនុគ្រោះពន្ធពីសហគម និយាយរួមវាប៉ះពាល់ខ្លាំងណាស់ អាចឈានដល់កម្មករ ប្រជាជនយើងបាត់បង់ការងារមួយចំនួន»។ បន្ថែមពីនេះ លោកអគ្គលេខាធិការសមាគមរោងចក្រកាត់ដេរនៅកម្ពុជា មើលមិនឃើញថា មានវិស័យណាដែលធំទូលាយ ហើយអាចទទួលយកកម្មករ កម្មការិនី ក្នុងចំនួនដ៏ច្រើនបែបនេះ ទៅធ្វើការ ក្រៅពីវិស័យវាយនភណ្ឌនោះទេ។ ជាងនេះ ព្រោះតែការអនុគ្រោះពន្ធរបស់សហភាពអឺរ៉ុប បានធ្វើឲ្យកម្ពុជា មានការអភិវឌ្ឍយ៉ាងច្រើន។ លោក កេន លូ សង្ឃឹមថា

សភាពអឺរ៉ុប នឹងពិចារណា ពីកត្តាគ្រោះថ្នាក់សម្រាប់កម្មករ កម្មការិនី ខ្មែរ រាប់សិបម៉ឺននាក់នេះ នឹងនៅតែបន្ត ផ្តល់ការអនុគ្រោះពន្ធសម្រាប់កម្ពុជាជាបន្តទៀត ៖«នៅពេលដែលខាងសហគមអឺរ៉ុប អនុគ្រោះឲ្យរួចពន្ធ ពិតជាជួយប្រទេសខ្មែរអភិវឌ្ឍន៍ច្រើន អញ្ចឹងសុំឲ្យគាត់វិលទៅពិចារណាពីបញ្ហា ហើយប្រសិនបើគាត់ដកចេញ អាចប៉ះពាល់ខ្លាំងដល់វិស័យកាត់ដេរ សម្លៀកបំពាក់នៅស្រុកខ្មែរ»។

ដូចគ្នាដែរលោកស្រី យ៉ាង សុភ័ណ្ឌ ប្រធានសម្ព័ន្ធសហជីពកម្ពុជា មានប្រសាសន៍ថា វិស័យវាយនភណ្ឌ គឺបានជួយដល់កម្មករ កម្មការិនី រាប់ម៉ឺននាក់ ហើយវិស័យនេះក៏បានជួយផ្តល់ការងារ និងប្រាក់ចំណូលដល់កម្មករពិសេសស្ត្រីយ៉ាងច្រើនផងដែរ ដោយមិនចាំបាច់ចំណាកស្រុក បើទោះជាក្នុងវិស័យនេះ ពេលខ្លះមានបញ្ហាចម្រូងចម្រាស់មួយចំនួនក្តី។ ប្រធានសម្ព័ន្ធសហជីពកម្ពុជា បន្តថា ប្រសិនជាមិនមានវិស័យវាយនភណ្ឌនេះទេ ស្ត្រីខ្មែរដ៏ច្រើនលើសលប់ នឹងធ្វើចំណាកស្រុកជាក់ជាមិនខាន ហើយលោកស្រីជឿជាក់ថា មានស្ត្រីតិចតែប៉ុណ្ណោះ ដែលត្រឡប់ទៅធ្វើស្រែចម្ការវិញ ដោយសារតែបច្ចុប្បន្ននេះ លោកស្រីមើលឃើញថា ផលិតផលកសិកម្ម ហាក់ពុំសូវមានទីផ្សារសមស្របសម្រាប់កសិករឡើយ ៖«ក្នុងករណីដែលអត់មានវិស័យហ្នឹង ១០០ភាគរយ គាត់ប្រាកដជាធ្វើចំណាកស្រុកហើយ ហើយមនុស្សភាគតិចណាស់ដែលត្រឡប់ទៅធ្វើស្រែចម្ការវិញ ដោយសារតែស្រែចម្ការជាទូទៅយើងដឹងហើយថា នៅពេលដែលគាត់ទៅធ្វើ គាត់អត់មានទីផ្សារលក់ដូរ នៅផលិតផលដែលគាត់ដាំ អញ្ចឹងគាត់គឺភាគតិចណាស់ដែលត្រឡប់ទៅធ្វើស្រែចម្ការវិញ»។ អ្វីដែលជាការមើលឃើញ របស់ស្ត្រី មេដឹកនាំកម្មករ កម្មការិនី រូបនេះ លោក សាស្ត្រាចារ្យ ឯម សុវណ្ណារ៉ា អ្នកវិភាគបញ្ហាសង្គម យល់ស្រប។ លោកមានប្រសាសន៍ថា នៅពេលនេះគ្មានអ្នកណាដឹងនោះទេ ថា សហភាពអឺរ៉ុប នឹងបិទ ឬក៏បន្តផ្តល់ការអនុគ្រោះពន្ធសម្រាប់ទំនិញកម្ពុជា។ ក៏ប៉ុន្តែក្នុងករណីដែលសហភាពអឺរ៉ុប បិទការអនុគ្រោះពន្ធមែន កម្មករ យ៉ាងច្រើន នឹងគ្មានការងារធ្វើ ហើយពួកគេមួយចំនួនអាចនឹងត្រូវចំណាកស្រុក ។ លោកថា វិស័យកាត់ដេរនេះទាក់ទងនឹងស្ត្រីច្រើនជាងគេ ៖«មនុស្សជាង ៧០ម៉ឺននាក់ហ្នឹង អ្នកទៅវិញប្រហែល ៣០ម៉ឺននាក់ចុះ ឬក៏ ៥០ម៉ឺនាក់ចុះ ៣៥ម៉ឺន ហើយ ៣៥ម៉ឺនទៀត ១៥ម៉ឺនទៅខាងក្រៅចុះ ២០ម៉ឺននៅធ្វើអី ហ្នឹងជាបញ្ហាសង្គមមួយដែលរដ្ឋាភិបាលត្រូវតែដោះស្រាយ ហើយបើមិនដោះស្រាយ»។

បន្ថែមលើនេះលោក ឯម សុវណ្ណារ៉ា បន្តទៀតថា ប្រសិនបើវិស័យវាយនភណ្ឌមានបញ្ហា មិនមែនប៉ះពាល់តែវិស័យនេះទេ ពោលគឺវិស័យផ្សេងៗទៀត ដែលពឹងផ្អែកលើវិស័យមួយនេះ ក៏នឹងត្រូវដួល ព្រោះសេដ្ឋកិច្ចបានជាប់គាំង ៖«*កម្ពុជាយើងអាចប្រឈមបញ្ហាច្រើន ដោយសារតែកម្ពុជាអាចបាត់ចំណូល បាត់កម្លាំងពលកម្ម អាចអត់ការងារធ្វើជាង ៧០ម៉ឺននាក់ ហើយវិស័យផ្សេងៗក៏អាចដួលដែរ។ ពលរដ្ឋផ្សេងៗដែលរស់ដោយសារចំណូល នៃវិស័យវាយនភណ្ឌហ្នឹង ដូចជា កម្មករ អ្នកលក់ដូរ ជួលផ្ទះអីហ្នឹង វាពាក់ព័ន្ធជាមួយកម្មករ ដែលធ្វើការងារនៅខាងវិស័យកាត់ដេរហ្នឹង។ អញ្ចឹងវាអាចបាត់បង់ចំណូលកំណើនសេដ្ឋកិច្ចកម្ពុជាដែរ*»។

ចំណែក លោក អាត់ ធន់ មេដឹកនាំសហភាពការងារកម្ពុជា ដែលធ្វើការងារដើម្បីប្រយោជន៍កម្មករ កម្មការិនី ជាច្រើនឆ្នាំមកហើយ ជឿជាក់ថា ប្រសិនបើគ្មានវិស័យវាយនភណ្ឌនេះទេ ជម្រើសទីមួយរបស់កម្មករ ពិសេសកម្មការិនី ច្បាស់ជានឹងធ្វើចំណាកស្រុក។ លោកបន្តថា បើកាលណាពួកគេឈានដល់ការធ្វើចំណាកស្រុកទៅក្រៅប្រទេស បញ្ហាប្រឈមនានា នឹងកើតឡើងទ្វេដង ដែលមានជាអាទិ៍ ការរំលោភសិទ្ធិការងារ ការបៀតបៀនកេរ្តិ៍ភេទ ការចាប់រំលោភ ឬក៏ការញៀនថ្នាំជាដើម ៖«ទោះជាការចំណាកស្រុកទាំងក្នុងស្រុកនិងក្រៅស្រុកហ្នឹងបញ្ហាវាតែងតែកើតមានហើយ គ្រាន់តែថា នៅក្នុងស្រុកបញ្ហាវាមានតិចតួច។ បើចំណាកស្រុក្រៅប្រទេសហ្នឹង យើងដឹងហើយថា សម្ពាធការងារ ការកេញប្រវ័ញ្ចការងារ នៅក្នុងស្រុកក៏មានដែរ ទម្រាំនៅក្រៅប្រទេស ការចាប់រំលោភ ការបោកប្រាស់បៀតបៀនផ្លូវភេទ ឬក៏ការកេញប្រវ័ញ្ចកម្លាំងពលកម្ម រួមទាំង បរិយាកាសសង្គមដែលគេនៅទីនោះមានជំងឺអេដស៍ ឬក៏ប្រើថ្នាំប្រើអីហ្នឹងវាមានបញ្ហាទាំងអស់ហ្នឹងហើយ ដែលធ្វើឲ្យបន្ទុកគ្រួសារគាត់កាន់តែលំបាកថែមទៀត»

។ លើសពីនេះប្រធានសហភាពការងារកម្ពុជា យល់ថា បើពលរដ្ឋខ្មែរ គ្មានការងារធ្វើចំនួនច្រើន នោះកំណើននៃការជំពាក់បំណុលធនាគារ ក៏នឹងកើនឡើងផងដែរ។ តែយ៉ាងលោក អាត់ ធន់ ចង់ឃើញដំណោះស្រាយសមស្របមួយរវាងអន្តរជាតិ ជាមួយរដ្ឋាភិបាលកម្ពុជា ជាជាងការបិទការអនុគ្រោះពន្ធ លើវិស័យវាយណនភណ្ឌពីកម្ពុជា ៖« ចំពោះខាងសហជីពយើង ក៏ដូចជាខាងកម្មករ យើងយល់ថា ជម្លោះផ្ទៃក្នុងពាក់ព័ន្ធទៅនឹង លទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោត ការប្រកួតប្រជែងក្នុងបក្សទាំងពីរហ្នឹង CPP និង CNRP រហូតដល់បាត់ការគាំទ្រពីសហគមអន្តរអឺរ៉ុប រហូតដល់ផ្តាច់អីហ្នឹង ខ្ញុំគិតថា បើអាចទៅរួចរដ្ឋាភិបាល សហគមអឺរ៉ុប សហរដ្ឋអាមេរិកអីហ្នឹង គួរជជែកគ្នាក្នុងក្របខណ្ឌណាមួយ កុំដាក់បញ្ហា ការផ្តាច់ការនាំចេញជាបញ្ហាទី១ អីអញ្ចឹងព្រោះវាប៉ះពាល់ខ្លាំងដល់កម្មករ និយោជិត»។

រយៈពេលចុងក្រោយនេះប្រមុខដឹកនាំរាជរដ្ឋាភិបាលកម្ពុជា បានបង្កើតឲ្យមានយន្តការផ្សេងៗ ក្នុងការគាំទ្រដល់កម្មករ ពិសេសកម្មការិនី ដែលកំពុងបម្រើក្នុងវិស័យវាយនភណ្ឌកាត់ដេរ និងស្បែកជើងនេះ។ ក្រុមសហជីព និងអ្នកវិភាគ មើលឃើញថា ប្រសិនបើមានការបិទ ការអនុគ្រោះពន្ធ ពីកម្ពុជាពិតមែន អ្វីដែលជាការខិតខំប្រឹងប្រែងរបស់ ប្រមុខដឹកនាំរាជរដ្ឋាភិបាល ច្បាស់ជាស់មិនអាចដល់ដៃកម្មករ កម្មការិនី ជាង ៧០ម៉ឺននាក់នេះទេ។

កម្ពុជា បានចំណេញប្រាក់ពន្ធ ពីការនាំទំនិញទៅកាន់ទីផ្សារអឺរ៉ុប ជាង ៦៧៦លានដុល្លារ ក្នុងមួយឆ្នាំៗ។ ប្រទេសកម្ពុជា បានទទួលគម្រោងអនុគ្រោះពន្ធនាំចូលទៅកាន់ទីផ្សារអឺរ៉ុប លើផលិតផលគ្រប់យ៉ាងលើកលែងតែអាវុធ (Everything But Arms) តាំងតែពីកម្ពុជា មានកិច្ចព្រមព្រៀងសន្តិភាព នៅឆ្នាំ១៩៩១ ដែលជាឧបករណ៍អន្តរជាតិមួយ ជួយបញ្ចប់សង្គ្រាមស៊ីវិល ជិត២ទសវត្សរ៍នៅកម្ពុជា៕

## មូលនិធិ LPN បើកវគ្គបណ្តុះបណ្តាលអប់រំដល់ពលករកម្ពុជាធ្វើការនៅក្រុមហ៊ុនCPF

http://www.khmerlabour.com/ July 20, 2018

មូលនិធិLPNប្រទេសថៃសហការជាមួយក្រុមហ៊ុនCPFក្នុ ងខេត្តសារ៉ាក់បុរីប្រទេសថៃបើកវគ្គបណ្តុះបណ្តាលអប់រំផ្តល់ចំណេះដឹងអំពីការទប់ស្កាត់អំពើជួញដូរមនុស្សចំនួនពីរវគ្គ ដល់បុគ្គលិកជនជាតិថៃនិងពលករកម្ពុជាព្រមទាំងបុគ្គលិកមើលការ ។ ក្នុងខ្លឹមសារអប់រំមានដូចជា៖ការជួយអន្តរាគមន៍ពលកររងគ្រោះ,ការទទួលពាក្យបណ្តឹងពីពលករ,ការអប់រំអំពីស្តង់ដារពលករ និងច្បាប់ទាក់ទងនឹងបញ្ហាការងារ,ការអប់រំបណ្តុះបណ្តាលផ្តល់ចំណេះដឹងនេះប្រព្រឹត្តទៅកាលពីថ្ងៃសុក្រទី២០ខែកក្កដាឆ្នាំ២០១៨ នៅវេលាម៉ោង០៨:៣០នាទី -១៦:៣០នាទីល្ងាច ដោយមានការធ្វើតេស្តសាកល្បងមុននិងឈានចូលដល់វគ្គអប់រំផងដែរ។ ជាចុងបញ្ចប់ក្រុមការងារមូលនិធិLPNប្រទេសថៃសូមថ្លែងអំណរគុណដល់ក្រុមហ៊ុន CPF និងបុគ្គលិកបម្រើការងារនៅទាំងដែលយកចិត្តទុកដាក់ស្តាប់ការបកស្រាយពន្យល់ណែនាំនិងការផ្តល់មតិយោបល់គ្នាទៅវិញទៅមកដើម្បីជាពិសោធន៍នៅពេលអនាគត។

## ពលរដ្ឋខ្មែរ21នាក់ត្រូវបានមេខ្យល់បោកទុកចោលនៅក្នុងព្រៃទឹកដីថៃ

https://www.facebook.com/permalink.php ទឹកចិត្ត ពលករ ឆ្លងដែន July 21 at 11:33 PM

កាលនៅថ្ងៃទី 20 ខែកក្កដា ឆ្នាំ 2018 នៅវេលាម៉ោង7 30នាទីពេលព្រឹកសមត្ថកិច្ចប៉ូលីសនឹងទាហានថៃចាប់បានពលរដ្ឋខ្មែរ21នាក់ ពលរដ្ឋខ្មែរទាំងអស់នេះបានឆ្លងដែនពីច្រកឡែម ខេត្តច័ន្ទបុរី ប្រទេសថៃ ។ ក្នុងករណីនេះបានអោយដឹងថា ពលរដ្ឋខ្មែរទាំង21នាក់នេះ បានលួចចូលឆ្លងដែនចូលតាមច្រកឡែមតាមផ្លូវតាក់ដើរកាត់អូរកាត់ព្រៃបានដើរចូលដល់ក្នុងទឹកដីថៃ បានស្នាក់នៅបានឡែម7 ថ្ងៃទៅ 8 ថ្ងៃ រួចធ្វើដំណើរទៅនៅខេត្តឈៀងរ៉ាយណ៍បាន3 ថ្ងៃ រួចហើយបានធ្វើដំណើរទៅនៅខេត្តឡាំងភូន បាន1យប់ ដល់ព្រឹកឡើងមេខ្យល់ដែលបាននាំពលរដ្ឋខ្មែរទាំង21នាក់បានរត់គេចខ្លួនបាត់ ក្រោយមកសមត្ថកិច្ចថៃក៏ចាប់បានពលរដ្ឋខ្មែរទាំង21នាក់នេះ ដោយមានពលរដ្ឋខ្មែរម្នាក់គាត់ចេះថៃ គាត់បាននិយាយថា ចាញ់បោកមេខ្យល់ មេខ្យល់បានយកលុយពីពលរដ្ឋខ្មែរក្នុងម្នាក់5,000

បាត ពលរដ្ឋខ្មែរទាំងអស់នេះត្រូវបានសមត្ថកិច្ចថៃចាប់បញ្ជូនយកទៅធ្វើប្រវត្តរូបរួចរាល់ហើយនឹងបញ្ជូនយកទៅតាមផ្លូវច្បាប់ ។ នេះគឺជាឈ្មោះពលរដ្ឋខ្មែរទាំង21នាក់:

1.ឈ្មោះ វ៉ែងលីន ភេទស្រី អាយុ 25 ឆ្នាំ នៅក្រចេះ
2.ឈ្មោះ ម៉ៅណាត ភេទស្រី អាយុ 40ឆ្នាំ នៅប្រវែល
3.ឈ្មោះ ចាន់រាប ភេទស្រី អាយុ19 ឆ្នាំ នៅប្រវែល
4.ឈ្មោះ វៀបចាន់ ភេទស្រីអាយុ 30ឆ្នាំ នៅកំពុងចាម
5.ឈ្មោះ កៀប ភេទស្រីអាយុ 37 ឆ្នាំនៅកំពុងចាម
6.ឈ្មោះ មុំ ភេទស្រីអាយុ 33 ឆ្នាំ នៅតាកែវ
7.ឈ្មោះ មិនធី ភេទស្រីអាយុ 28 ឆ្នាំ នៅបាត់ដំបង
8.ឈ្មោះ សៃគៀវ ភេទស្រីអាយុ22 ឆ្នាំ នៅកំពុងចាម
9.ឈ្មោះ រិមណា ភេទស្រីអាយុ 22 ឆ្នាំ នៅបាត់ដំបង
10.ក្មេងស្រីអាយុ 2 ឆ្នាំ មានឈ្មោះ មីនត្រា ជាកូនស្រីរបស់អ្នកម្តាយមានឈ្មោះ រិមណា
11.ឈ្មោះ វ៉ងសុថេប ភេទប្រុស អាយុ 28 ឆ្នាំ នៅកំពុងចាម
12.ឈ្មោះ ផលសុផៃ ភេទប្រុស អាយុ 33ឆ្នាំ នៅបាត់ដំបង
13.ឈ្មោះ រីចំរើន ភេទប្រុស អាយុ 32 ឆ្នាំ នៅកំពុងចាម
14.ឈ្មោះ ចាប់ភី ភេទប្រុស អាយុ 24 ឆ្នាំ នៅកំពុងចាម
15.ឈ្មោះ សុវ៉ាន់ណា ភេទប្រុសអាយុ 41ឆ្នាំ នៅកំពុងចាម
16.ឈ្មោះ ឆេមនឹង ភេទប្រុស អាយុ18 ឆ្នាំ នៅកំពុងចាម
17.ឈ្មោះ ចោះសំណាង ភេទប្រុស អាយុ 29 ឆ្នាំ នៅកំពត
18.ឈ្មោះ ធីបតូ អាយុ35 ឆ្នាំ នៅសះដៅ
19.ឈ្មោះ ថាប ភេទប្រុសអាយុ 44 ឆ្នាំ នៅស្រុកម៉ង
20.ឈ្មោះ ប្រុស អាយុ 38 ឆ្នាំ នៅបាត់ដំបង
21.ឈ្មោះ វី អាយុ 32 ឆ្នាំ នៅកំពុងចាម ម្នាក់នេះអាចនិយាយថៃបាន

នេះគឺជាឈ្មោះប្រជាពលរដ្ឋខ្មែរទាំង21នាក់ដែលត្រូវសមត្ថកិច្ចថៃចាប់ចខ្លួនបាន

សូមពុកម៉ែបងប្អូនខ្មែរកុំលួចចូលប្រទេសថៃខុសច្បាប់អោយសោះ ព្រោះរាល់ថ្ងៃនេះច្បាប់ថៃកាន់តែរិតបន្តឹងច្បាប់ពលករឆ្លងដែនខុសច្បាប់ខ្លាំងណាស់និងមានការចុះត្រួតចាប់ពលករខុសច្បាប់ទូទាំងប្រទេសថៃផងដែរ ។ សូមបងប្អូនខ្មែរជ្រាបជាដំណឹង (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន)

## ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨

## សាធារណរដ្ឋឆេក បញ្ឈប់ការចេញវីសាការងារសម្រាប់ជនជាតិវៀតណាម

http://kleykley.sabay.com.kh/ ថ្ងៃ ទី២៤ ខែកក្កដា ឆ្នាំ២០១៨ ម៉ោង ២០:០៧ ប្រែសម្រួល៖ អ៊ឹម ម៉េងស៊ាង

ប្រជាជនវៀតណាម មិនអាចស្នើសុំទិដ្ឋាការសម្រាប់ការស្នាក់នៅរយៈពេលវែង ឬការចូលរួមក្នុងសកម្មភាពជំនួញណាមួយបន្តទៀតទេ នៅសាធារណរដ្ឋឆេក។ រដ្ឋមន្ត្រីការបរទេសស្តីទីសាធារណរដ្ឋឆេក លោក Jan Hamacek បាននិយាយថា ចំនួនស្នើសុំទិដ្ឋាការការងារ ដែលបានដាក់ស្នើដោយប្រជាជនវៀតណាម ទៅកាន់ស្ថានទូតឆេកប្រចាំវៀតណាម គឺច្រើនលើសលប់ និងពុំមានសញ្ញាណនៃការថមថយសោះឡើយ។ ការណ៍នេះ អាចនាំឲ្យមានបញ្ហាសន្តិសុខផងដែរ។ នេះបើយោងតាមការចុះផ្សាយរបស់ភ្នាក់ងារសារព័ត៌មានវៀតណាម នៅថ្ងៃទី២៣ ក

ក្ដដានេះ។ បច្ចុប្បន្ននេះ ស្ថានទូតឆេកប្រចាំវៀតណាម នឹងផ្ដល់អាទិភាពតែមួយគត់ សម្រាប់ពលរដ្ឋវៀតណាមរូបណា ដែលចង់ស្នើសុំទិដ្ឋាការសម្រាប់ការជួបជុំគ្រួសារឡើងវិញប៉ុណ្ណោះ។

ជុំវិញរឿងនេះ អគ្គរដ្ឋទូតវៀតណាមប្រចាំសាធារណរដ្ឋឆេក លោក Ho Minh Tuan បាននិយាយថា រដ្ឋាភិបាលវៀតណាម បានព្យាយាមចាត់វិធានការដើម្បីដោះស្រាយបញ្ហានេះ តាមរយៈការចរចាការទូត។ គួរបញ្ជាក់ថា សព្វថ្ងៃនេះ ប្រជាជនវៀតណាមច្រើនជាង ៦៥ ០០០ នាក់ កំពុងរស់នៅក្នុងសាធារណរដ្ឋឆេក ដែលក្លាយជាក្រុមភាគតិចដ៏ធំបំផុតលំដាប់ទី ៣ ក្នុងប្រទេសនេះ។ យោងតាមការឲ្យដឹងពីក្រសួងការងារវៀតណាម ប្រជាជនវៀតណាមប្រមាណកន្លះលាននាក់ កំពុងរស់នៅ និងធ្វើការ នៅក្រៅប្រទេស។ ជាមធ្យម ពលករវៀតណាមច្រើនជាង ៩ ម៉ឺននាក់ ចាកចេញពីប្រទេសជារៀងរាល់ឆ្នាំ ជាពិសេសពលករខាងផ្នែក អតិពលកម្ម និងការងារមានជំនាញកម្រិតទាប។ កម្លាំងពលកម្មសរុបរបស់វៀតណាម មានចំនួនប្រមាណជាង៥០ លាននាក់៕ ប្រភព៖ Vietnam Express

## មនុស្សជាង៦០០នាក់ ត្រូវបានចាប់ខ្លួនពីបទរត់ពន្ធមនុស្ស ចូលអូស្ត្រាលី

http://www.rasmeinews.com/ July 24, 2018, 12:45 PM

មន្ត្រីជាន់ខ្ពស់ម្នាក់បាននិយាយនៅថ្ងៃអង្គារទី២៤ខែកក្កដាថា អ្នករត់ពន្ធមនុស្សជាង៦០០នាក់ត្រូវបានចាប់ខ្លួននៅប្រទេសចំនួន៦ ចាប់តាំងពីប្រទេសអូស្ត្រាលីបានដាក់ចេញវិធានការការពារព្រំដែនដ៏តឹងរឹងរបស់ខ្លួនដោយទូកដឹកជនស្វែងរកសិទ្ធិជ្រកកោនចំនួន៣០គ្រឿង ត្រូវបានបញ្ជូនត្រឡប់ទៅវិញ។

លោក Peter Dutton រដ្ឋមន្ត្រីក្រសួងអន្តោប្រវេសន៍អូស្ត្រាលី បាននិយាយថា "ប្រតិបត្តិការអេធិបតេយ្យភាពនេះ " បានជួយសង្គ្រោះជីវិតមនុស្សទាំងនេះ ។ប្រតិបត្តិការយោធានេះ បានចាប់ផ្តើមកាលពីខែកញ្ញាឆ្នាំ២០១៣ ហើយបានបញ្ឈប់ការមកដល់នៃទូកដឹកជនអន្តោប្រវេសន៍ជាច្រើន។ នៅមុនពេល រដ្ឋាភិបាលអភិរក្សនិយមនេះ បានឡើងកាន់អំណាចនិងបានប្រកាន់យកជំហរអត់ធ្មត់នោះជនស្វែងរកសិទ្ធិជ្រកកោនចំនួន ៥០.០០០នាក់ បានចូលមកដល់ប្រទេសអូស្ត្រាលីតាមទូកជាង៨០០គ្រឿង ក្នុងរយៈពេលជាង៥ឆ្នាំមកនេះ។ ជនអន្តោប្រវេសន៍រាប់រយនាក់បន្ថែមទៀត ដែលភាគច្រើនមកពីប្រទេសអាហ្វហ្គានីស្ថានដែលមានសង្គ្រាម និងមកពីប្រទេសស្រីលង្កា ព្រមទាំងមកពី តំបន់មជ្ឈិមបូព៌ាបានស្លាប់នៅសមុទ្រក្នុងអំឡុងធ្វើដំណើរតាមទូកដ៏គ្រោះថ្នាក់នេះ។ លោក Peter Dutton បាននិយាយថា ការប៉ុនប៉ងរត់ពន្ធមនុស្សចំនួន២.៥០០នាក់ ត្រូវបានបញ្ឈប់ ដោយទូកដឹកជនអន្តោប្រវេសន៍ចំនួន៣៣គ្រឿងត្រូវបានបញ្ជូនត្រឡប់ទៅវិញ គឺភាគច្រើននៃទូកដឹកជនអន្តោប្រវេសន៍ទាំងនេះ ត្រូវបានបញ្ជូនទៅប្រទេសឥណ្ឌូនេស៊ីវិញ៕ដោយ៖សុខា/sn

## ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៨
## អាសូរជីវិតពលករខ្មែរឆក់ខ្សែភ្លើងស្លាប់ម្តង3នាក់

https://www.facebook.com/matemohachunnews/ សារព័ត៌មាន មតិមហាជន 25-07-2018

បន្ទាយមានជ័យ៖សពពលករខ្មែរ3នាក់ត្រូវបានភាគីថៃបញ្ជូនត្រឡប់ក្នុងពេលតែមួយតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតនៅព្រឹកថ្ងៃទី25 ខែកក្កដា 2018នេះ ក្រោយពីស្លាប់ដោយឆក់ចរន្តអគ្គិសនីនៅខេត្តឧប៊ុន រាជធានីប្រទេសថៃ កាលពីរសៀលថ្ងៃទី24។ ជនរងគ្រោះជាបងប្អូនជីដូនមួយនឹងគ្នាជាកម្មករផ្នែកខាងធ្វើឡហ្គោឲ្យជនជាតិថៃក្នុងខេត្តកើតហេតុខាងលើ និងមានទីលំនៅស្រុកមោងឫស្សី ខេត្តបាត់ដំបង។ សាច់ញាតិសពនិយាយថា ជនរងគ្រោះកំពុងធ្វើការឈ្មោះ ស៊ុនឈិន ភេទប្រុស ជាអ្នកបញ្ជាគ្រឿងស្ទូចលើកតាំងឡហ្គោត្រូវចរន្តឆក់មុនគេព្រោះតែដាក់ដងស្ទូចចុះវិញប៉ះចំខ្សែភ្លើង ហើយជនរងគ្រោះ2នាក់ទៀតដែលជាបងប្អូនជីដូនមួយរត់ទៅជួយក៏ឆក់ស្លាប់ទាំងអស់គ្នាតែម្តង៕ដោយកុសល់ប៉ោយប៉ែត

## កាត់ទោសដាក់គុក១៨០ឆ្នាំពីបទរត់ពន្ធជនភៀសខ្លួន

http://nokorwatnews.com/ 24-07-2018

ក្រុមអ្នករត់ពន្ធជនភៀសខ្លួនកំពុង ប្រឈម ចំពោះមុខច្បាប់ពីទង្វើរបស់ខ្លួន ដែលពិភពលោកស្អប់ខ្ពើម និងក្នុងពេល ដែលអឺរ៉ុបកំពុងតែទប់ស្កាត់ ការហូរចូល នៃជនភៀសខ្លួន ។ ភាគច្រើនក្រុមជួញ ដូរមនុស្ស បាននាំទៅកាន់អឺរ៉ុប ។ កន្លងមកថ្មីៗ ជនទុច្ចរិតពីរនាក់ ជាជនជាតិអ៊ុយក្រែនត្រូវបានតុលាការប្រទេសក្រិកកាត់ទោសដាក់គុកម្នាក់១៨០ឆ្នាំពីបទ រត់ពន្ធជនភៀសខ្លួន។ សារព័ត៌មាន Sputnik នៅព្រឹកថ្ងៃអង្គារ ទី២៤ ខែកក្កដា ឆ្នាំ២០១៨បានផ្សាយថា ជនជាប់ចោទជាបុរសទាំង២នាក់ខាងលើ ឈ្មោះ សែហ៊ីវ សាវ៉ាយុគ (Serhiy Shvayuk) និង ផេត្រូ លីតវីនជុក (Petro Lytvynchuk) ត្រូវបានតុលាការក្នុងទីក្រុង ភីរ៉ាអឺស (Piraeus) ប្រទេសក្រិក កាត់ ទោសដាក់ពន្ធនាគារម្នាក់ៗ ១៨០ឆ្នាំ កាលពីថ្ងៃសុក្រសប្តាហ៍មុន បន្ទាប់ពីពួកគេត្រូវបានចាប់ខ្លួននៅលើទូកពោងកៅស៊ូមួយគ្រឿងមានដឹកជនភៀសខ្លួន ៦០នាក់។ ពួកគេទាំងពីរនាក់ត្រូវបានតុលាការរកឃើញថា បានប្រព្រឹត្តបទល្មើសជាច្រើន ករណី ទាក់ទិននឹងជនភៀសខ្លួនក្នុងនោះមានដូចជា បទឆ្លងដែនចូលប្រទេសមួយ ក្នុងសហភាពអឺរ៉ុបដោយខុសច្បាប់ បង្កហានិភ័យដល់អាយុជីវិតជនភៀសខ្លួន មិន មានបរិក្ខារសង្គ្រោះបន្ទាន់ និងអាជ្ញាប័ណ្ណ អនុញ្ញាតការធ្វើចរាចរណ៍ទូក ឬនាវា៕ ម៉ែវ សាធី

## ជប៉ុន ចង់ចាប់ផ្តើមទទួល យកពលករបរទេស កាន់តែច្រើន នៅខែ មេសា ឆ្នាំក្រោយ

https://www.dap-news.com/kh/ ថ្ងៃពុធ, ២៥ កក្កដា ២០១៨ 13:46 ប្រែសម្រួល: ឈូក បូរ៉ា ID:11

តូក្យូៈ លោកនាយករដ្ឋមន្ត្រីជប៉ុន ស៊ីនហ្សូ អាបេ (Shinzo Abe) បានឱ្យដឹងថា ជប៉ុន ចង់ចាប់ផ្តើម ទទួលយកពលករបរទេសកាន់តែច្រើនពីខែមេសា ឆ្នាំក្រោយ ខណៈប្រទេសនេះប្រឈមនឹងកង្វះកម្លាំង ពលកម្មធ្ងន់ធ្ងរនៅក្នុងវិស័យឧស្សាហកម្មជាច្រើន នេះបើយោងតាមការចុះផ្សាយរបស់ទីភ្នាក់ងារ សារ ព័ត៌មាន ក្យូដូជប៉ុន នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨។ នៅក្នុងកិច្ចប្រជុំជាមួយសមាជិកគណៈរដ្ឋមន្ត្រីលោកអាបេ បានណែនាំពួកគេឱ្យពន្លឿនការរៀបចំ ចាំបាច់សម្រាប់ផែនការ ដែលត្រូវអនុវត្តស្របតាមចំណុចចាប់ផ្តើម ដែលនឹងកំណត់ឱ្យមានប្រសិទ្ធិភាពដល់ជនបរទេស ដែលមានជំនាញខ្ពស់។ ជាមួយនឹងផែនការនេះ រដ្ឋាភិបាលជប៉ុន កំពុងពិចារណាការរៀបចំឡើងវិញការិយាល័យអន្តោប្រវេសន៍ និងការបង្កើតភ្នាក់ងារ ដែលមានជាប់ទាក់ទងនឹងការទទួលខុស ត្រូវដោះស្រាយពលករបរទេស ដែល គ្មានជំនាញផងដែរ៕

# ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៨

## ពលករខ្មែរម្នាក់ត្រូវជនមិនស្គាល់មុខចាក់សម្លាប់នៅប្រទេសថៃ

http://ppd-news.net/ July 30, 2018 admin

ខេត្តបន្ទាយមានជ័យ ៖ បុរសជាពលករខ្មែរម្នាក់ត្រូវបានជនមិនស្គាល់អត្តសញ្ញាណចាក់សម្លាប់យ៉ាងព្រៃផ្សៃស្លាប់យ៉ាងអណោចអធម៌នៅប្រទេសថៃនៅវេលាម៉ោង១២យប់ឈានចូលថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៨ នៅក្នុងបរិវេណការដ្ឋានសំណង់មួយកន្លែង ត្រង់ចំណុចផ្លូវរោងចក្រផលិតប្រហិតណងប៉ម ស្ថិតនៅភូមិ៨ សង្កាត់ថាផា ស្រុកបានប៉ុង ខេត្តរ៉ាតបុរី ។

សមត្ថកិច្ចរបស់ថៃបានប្រាប់សមត្ថមិច្ចខ្មែរថាជនរងគ្រោះមាន ឈ្មោះ ណាក់ អាយុ២៩ឆ្នាំជាពលកររស់នៅក្នុងបន្ទប់ស្នាក់នៅក្នុងបរិវេណការដ្ឋានសំណង់មួយកន្លែង ត្រង់ចំណុចផ្លូវរោងចក្រផលិតប្រហិតណងប៉ម ស្ថិតនៅមូ8 សង្កាត់ថាផា ស្រុកបានប៉ុង ខេត្តរ៉ាតបុរី ។ សមត្ថកិច្ចរបស់ថៃបានបញ្ជាក់ឲ្យដឹងទៀតថា ក្រោយពីកើតហេតុហើយជនសង្ស័យបានរត់គេចបាត់តម្រួតថៃកំពង់ស្វែងរកតាមចាប់យកមកផ្តន្ទាទោសហើយ។ សពជនរងគ្រោះត្រូវបានអាជ្ញាធរថៃបញ្ជូនទៅរក្សាទុកនៅមន្ទីរពេទ្យដើម្បីធ្វើការកោសល្យវិច័យតាមនីតិវិធីច្បាប់ហើយបានធ្វើការទំនាក់ទំនង

អគ្គកុងសុលខ្មែរប្រចាំនៅស្រុកថៃដើម្បីធ្វើការទំនាក់ទំនងយកសពមកស្រុកកំណើតវិញ និងចាត់ចែងធ្វើបុណ្យតាមប្រពៃណី៕

## អ្នកនេសាទគ្រោងធ្វើកូដកម្មពាក់ព័ន្ធនឹងពលករអន្តោប្រវេសន៍

https://kohsantepheapdaily.com.kh/ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៨ ម៉ោង ០៧:២០ ណៃ ដាលីន

ខេត្ត Phang Nga ៖ វិស័យនេសាទរបស់ប្រទេសថៃបានស្នើទៅកាន់រដ្ឋាភិបាលម្តងទៀត ពាក់ព័ន្ធនឹងរយៈពេលនៃការជួលពលករអន្តោប្រវេសន៍ធ្វើការផ្នែកនេសាទ ។ លោក Boonchu Phaeyai ប្រធានសមាគមនេសាទប្រចាំខេត្ត បាននិយាយកាលពីថ្ងៃសៅរ៍ថា ៖« ក្រុមអាជីវករទាមទារការអនុញ្ញាតឲ្យពួកគេជួលពលករអន្តោប្រវេសន៍ដូចដែលបានចែងនៅក្នុងច្បាប់ ដើម្បីចៀសវាងបញ្ហាកង្វះខាតកម្លាំងពលកម្ម » ។ ពួកគេក៏ទាមទារឲ្យក្រុមពលករទាំងនេះអាចធ្វើការនៅលើទូកនេសាទបានរយៈពេល២ឆ្នាំផងដែរ និងអះអាងថា ពួកគេត្រូវការពលករប្រមាណ៥ម៉ឺននាក់ឯណោះ ។ យោងតាមអាជីវករទាំងនេះ រដ្ឋា ភិបាលថៃគួរតែធ្វើកំណែទម្រង់វិធានការមួយចំនួន ពីព្រោះវិធានការទាំងនេះបានប៉ះពាល់ដល់ការប្រកបអាជីវកម្មរបស់ពួកគេ ។ ក្រុមនេះក៏មានគម្រោងដាក់ស្នើការទាមទាររបស់ពួកគេទៅកាន់មន្ត្រីជាប់ពាក់ព័ន្ធតាមខេត្ត នៅថ្ងៃទី១ ខែសីហា ខាងមុខនេះ ។ សមាជិករបស់ពួកគេនឹងធ្វើកូដកម្ម ប្រសិនបើមិនទទួលបានការឆ្លើយតបពីរដ្ឋាភិបាល ក្នុងរយៈពេល៧ថ្ងៃទេនោះ ។ ជាមួយគ្នានេះ នាយកដ្ឋានការងារប្រទេសថៃ បានស្នើសុំយោបល់ពីនាយកដ្ឋានកាន់បញ្ជីទូទៅ ទាក់ទងនឹងការប្រើប្រាស់ម៉ាស៊ីនស្កេន (iris scanners) សម្រាប់ការបញ្ជាក់អត្តសញ្ញាណពលករអន្តោប្រវេសន៍ រួមមានពលករនៅក្នុងវិស័យនេសាទផងដែរ ៕